**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **នុត សុវណ្ណរតនា**

**ឃឹម លាងស៊ីម**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់ **បរិញ្ញាបត្រ**

ជំនាញ **នីតិសាស្ត្រ** ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **នុត សុវណ្ណរតនា** និង នាងខ្ញុំឈ្មោះ **ឃឹម លាងស៊ីម** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្រ្ត ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទសាស្ត្រនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងនូវសេចក្តីកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតៈ

- សូមលើកអញ្ជលីលំឱនកាយវាចារចិត្តគោរពដល់ លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានរៀនសូត្ររហូតដល់ពេលបច្ចុប្បន្ននេះ។
- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាតអោយយើងខ្ញុំចូលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- លោកសាស្រ្តាចារ្យ **ជួន ម៉ុនធី** ជាសាស្រ្តាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹកក្នុងការបង្ហាត់បង្រៀនផ្តល់ការណែនាំ ថែមទាំងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។
- ថ្នាក់ដឹកនាំ សាស្រ្តាចារ្យ និងបុគ្គលិកសិក្សា នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវក្នុងពេលកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងអំពីយើងខ្ញុំ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្រ្តាចារ្យទាំងអស់ សូមបានប្រកបដោយជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

ជាបឋម ខ្ញុំបាទ **នុត សុវណ្ណរតនា** និង នាងខ្ញុំ **យឹម លាងស៊ីម** សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស និស្សិត ជាទីរាប់អាន ព្រមទាំងសាស្ត្រាចារ្យជាទីគោរព។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី **ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង** ដែលត្រូវបានទទួលនូវការគាំទ្រ និងការជួយលើកទឹកចិត្តបង្ហាត់បង្ហាញកែតម្រូវយ៉ាងពេញទំហឹង ពីសំណាក់លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងក្នុងគោលបំណង គឺដើម្បីចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាបច្ចុប្បន្ន ហើយក៏ទុកជាឯកសារសម្រាប់បំពេញនូវតម្រូវការរបស់និស្សិតជំនាន់ក្រោយៗ និងជួយដល់លោកអ្នកទាំងអស់ ដែលបានធ្វើការសិក្សាស្រាវជ្រាវ ជំនាញវិជ្ជាជីវៈនីតិសាស្ត្រ ជាពិសេសពួកយើងខ្ញុំផ្ទាល់ក៏ចង់ដឹង និងចង់សិក្សាឲ្យបានស៊ីជម្រៅច្បាស់លាស់បន្ថែមទៀត អំពីខ្លឹមសារ និងអត្ថន័យ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាក់ស្តែងទាក់ទងនឹងប្រធានបទនេះផងដែរ។

ម្យ៉ាងវិញទៀត នៅក្នុងការស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំនុចខ្វះខាតខាងផ្នែកខ្លឹមសារ និងកំហុសឆ្គងខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន។ ដូច្នេះយើងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងក្នុងឯកសារនេះនឹងទទួលបាននូវការអធ្យាស្រ័យ និងការអភ័យទោស ពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានជាក់ជាមិនខាន។

យើងខ្ញុំសូមទទួលរង់ចាំនូវការរិះគន់ និងកែតម្រូវ ក្នុងន័យស្ថាបនា ពីសំណាក់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់គ្រប់ពេលវេលា។

ជាទីបញ្ចប់នេះ សូមជូនពរដល់ អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូបឲ្យជួបប្រទះតែនឹងភាពសុខដុមរមនារុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិច្ចនិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ០១

**ជំពូកទី១**

**សញ្ញាណទូទៅនៃអយ្យការអមសាលាដំបូង**

**ផ្នែកទី១ សមាសភាពនៃអយ្យការអមសាលាដំបូង** ............................................................ ០៥

**ក. ព្រះរាជអាជ្ញា** ............................................................ ០៥

**ខ. ព្រះរាជអាជ្ញារង** ............................................................ ០៥

**គ. ក្រឡាបញ្ជី** ............................................................ ០៦

**ផ្នែកទី២ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ** ............................................................ ០៦

**ក. គោលការណ៍ឯកភាព** ............................................................ ០៦

**ខ. គោលការណ៍អវិភាគ** ............................................................ ០៧

**គ. គោលការណ៍ឯករាជ្យ** ............................................................ ០៧

**ឃ. គោលការណ៍នៃការមិនទទួលខុសត្រូវ** ............................................................ ០៨

**ង. គោលការណ៍មិនអាចប្តឹងជំទាស់** ............................................................ ០៨

**ផ្នែកទី៣ សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា** ............................................................ ០៩

**ក. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា** ............................................................ ០៩

**ខ. តួនាទីរបស់ព្រះរាជអាជ្ញា** ............................................................ ០៩

**គ. ភារកិច្ចរបស់ព្រះរាជអាជ្ញា** ............................................................ ១០

**ឃ. អំណាចរបស់ព្រះរាជអាជ្ញា** ............................................................ ១០

**ជំពូកទី២**

**ការចោទប្រកាន់របស់ព្រះរាជអាជ្ញា**

**ផ្នែកទី១ ការបើកការស៊ើបសួរ** ............................................................ ១៣

**ក. លក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ** ............................................................ ១៣

**ខ. នីតិវិធីនៃការបើកការស៊ើបសួរ** ............................................................ ១៥

**១. ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងបញ្ជូនមកដោយផ្ទាល់** ............................................................ ១៥

**២. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌** .... ១៥

គ. ទម្រង់ការចាំបាច់ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ..... ១៦

ឃ. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ..... ១៨

ផ្នែកទី២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់..... ១៩

ក. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនទៅជំនុំជម្រះផ្ទាល់..... ២០

១. លក្ខខណ្ឌនៃបទល្មើស ..... ២០

២ .លក្ខខណ្ឌសាវតាជាតិរបស់ជនល្មើស..... ២១

ខ. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់..... ២១

គ. ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ..... ២៣

ឃ. អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់..... ២៤

ផ្នែកទី៣ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម..... ២៦

ក. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ..... ២៦

ខ. នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ..... ២៧

១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា..... ២៨

២ .នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ..... ២៩

គ. អានុភាពនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម..... ៣០

## ជំពូកទី៣

## ការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា

ផ្នែកទី១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ..... ៣២

ក. នត្ថិភាពនៃបទល្មើស..... ៣២

១. អវត្តមានបទល្មើស ..... ៣២

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់..... ៣២

ខ. មូលហេតុគតិយុត្ត ..... ៣៣

១. ការរលត់នៃបណ្តឹងអាជ្ញា ..... ៣៤

២. មូលហេតុគតិយុត្តផ្សេងទៀត..... ៣៨

គ. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍..... ៤១

ផ្នែកទី២ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ..... ៤២

ក. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ..... ៤២

ខ. ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ..... ៤៣

គ. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........................................ ៤៤
ផ្នែកទី៣ យន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ ........................................ ៤៤
ក. ការសើរើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ........................................ ៤៥
ខ. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ........................................ ៤៦
គ. អំណាចអធិបញ្ជាដោយឋានានុក្រមនៃអង្គការអយ្យការ ........................................ ៤៧
ឃ. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ........................................ ៤៩
សន្និដ្ឋាន និងអនុសាសន៍ ........................................ ៥១
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

នៅក្នុងការគ្រប់គ្រងប្រទេសមួយ ដើម្បីឲ្យមានសន្តិសុខ សណ្តាប់ធ្នាប់ យុត្តិធម៌ តម្លាភាព និង ការអភិវឌ្ឍជឿនលឿនលើគ្រប់វិស័យ ប្រទេសនោះទាមទារឲ្យមានការបង្កើតវិធានច្បាប់ និង បទដ្ឋានគតិយុត្តនានា ព្រមទាំងធានាប្រសិទ្ធិភាពនៃការអនុវត្តច្បាប់នៅក្នុងប្រទេសនោះផងដែរ។ លើសពីនេះទៅទៀត ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ច្បាប់ទាំងនោះត្រូវតែ អនុវត្តដោយត្រឹមត្រូវមិនលំអៀង និងឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស ជាពិសេសក្រុមងាយ រងគ្រោះដូចជាប្រជាជនស្លូតត្រង់ជាដើម។ ដូចនេះ ត្រូវមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ ដើម្បីពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។ ជាក់ស្តែងប្រទេសកម្ពុជា ជា ប្រទេសមួយដែលមានអាយុកាលដ៏យូរលង់ណាស់មកហើយ។ តាមការសិក្សាស្រាវជ្រាវប្រវត្តិ សាស្ត្ររបស់ប្រទេសកម្ពុជាយើង បានបង្ហាញឲ្យឃើញថា នៅតាមសម័យកាលនីមួយៗ គឺមាន ប្រព័ន្ធយុត្តិធម៌ទៅតាមរបបគ្រប់គ្រងប្រទេស។ បើក្រឡេកមកមើលយុគ្គសម័យទំនើបវិញ ប្រព័ន្ធ យុត្តិធម៌នៅប្រទេសកម្ពុជាត្រូវបានគេបែងចែកជាជាន់ថ្នាក់ ទន្ទឹមនឹងការបែងចែកប្រព័ន្ធយុត្តិធម៌នេះ ដើម្បីដំណើរការដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌនោះ អ្នកតាក់តែងវិធាន ច្បាប់ បានតាក់តែងនូវវិធានដើម្បីឲ្យមន្ត្រីមានសមត្ថកិច្ចនៅតាមតុលាការអនុវត្តទៅតាមលំហូរនៃ នីតិវិធី ដែលមានប្បញ្ញត្តិទុកជាស្រេចក្នុងច្បាប់ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ជនដែលត្រូវ ទទួលរងនូវការចោទប្រកាន់ ឬជនរងគ្រោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

ជាការពិតណាស់ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យ ប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មុននឹងត្រូវបានរំលេចឡើងជារូបរាង ត្រូវចំណាយរយៈពេល អស់ជាង ១០ឆ្នាំ ហើយក្រមនេះត្រូវបានក្លាយជាអត្ថបទច្បាប់ដ៏ចម្បង និងជាមធ្យោបាយដ៏សំខាន់ របស់តុលាការព្រហ្មទណ្ឌក្នុងការអនុវត្តឲ្យស្របទៅតាមនីតិវិធីជាក់លាក់។ តួយ៉ាងដំណើរការនៃ រឿងក្តីព្រហ្មទណ្ឌ ដោយផ្អែកទៅលើក្រមនីតិវិធីនេះ បានបែងចែកជាបួនដំណាក់កាលធំៗ គឺ ដំណាក់កាលនៃការស៊ើបអង្កេត ដំណាក់កាលនៃការចោទប្រកាន់ ដំណាក់កាលនៃការស៊ើបសួរ និង ដំណាក់កាលនៃការជំនុំជម្រះ។ ដំណាក់កាលទាំងបួនសុទ្ធតែជាធាតុដ៏សំខាន់ ដែលមានលក្ខណៈ ស៊ីសង្វាក់គ្នា ហើយមិនអាចខ្វះ ឬរំលងដំណាក់កាលមួយណាបានទេ។ ដោយឡែក ដំណាក់កាល ចោទប្រកាន់ គឺជាដំណាក់កាលមួយដ៏សំខាន់មុននឹងមានវត្តមានដំណាក់កាលស៊ើបសួរ និងជំនុំ ជម្រះ ដែលត្រូវបានអនុវត្តដោយស្ថាប័នអយ្យការ។ ស្ថាប័នអយ្យការ គឺជាតំណាងរបស់អង្គការនីតិ ប្រតិបត្តិ ស្ថិតនៅអមសាលាជម្រះក្តីដោយមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង សន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។ នៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង មានតែអង្គការ

អយ្យការតែមួយគត់ដែលបំពេញតួនាទីដោយព្រះរាជអាជ្ញា ជាអ្នកធ្វើបណ្តឹងអាជ្ញាតំណាងឲ្យផលប្រយោជន៍សង្គមជាតិទាំងមូល។ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់លើគ្រប់បទល្មើសដែលបញ្ជូនមកឲ្យខ្លួនតាមរយៈពាក្យបណ្តឹងផ្ទាល់របស់ជនរងគ្រោះ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌។ ប៉ុន្តែអ្វីដែលគួរឲ្យសម្គាល់ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧នេះ បានផ្តល់ជម្រើសដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែង ក៏ដូចជាប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់ ពីព្រោះមិនមែនគ្រប់បទល្មើស ឬអង្គហេតុដែលកើតឡើងសុទ្ធតែអាចធ្វើការចោទប្រកាន់បានទាំងអស់នោះទេ។

ជាគោលការណ៍នៅក្នុងស្ថាប័នអយ្យការ គឺមានចៅក្រមអយ្យការជាតំណាងដែលមានមុខងារ និងតួនាទីខុសគ្នាទៅតាមឋានានុក្រមនៃសាលាជម្រះក្តី។ ក្នុងន័យនេះដែរ សារណាដែលបានតាក់តែងមកនេះ គឺកំណត់ទំហំនៃប្រធានបទ ក្នុងព្រំដែនមួយនៃអង្គការអយ្យការអមសាលាដំបូងតែប៉ុណ្ណោះ ពោលគឺ បកស្រាយអំពី ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលជាសិទ្ធិអំណាចរបស់អយ្យការអមសាលាដំបូង ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ម្យ៉ាងវិញទៀត ចំពោះសារៈសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ នឹងផ្តល់ឲ្យមានការយល់ឃើញកាន់តែច្បាស់ និងស៊ីជម្រៅអំពីនីតិវិធីនៃការចោទប្រកាន់ ក៏ដូចជាផ្តល់ផលប្រយោជន៍មួយក្នុងការវិភាគ និងវែកញែកឲ្យបានលម្អិតនៅក្នុងការប្រើប្រាស់នីតិវិធីនីមួយៗ។ មិនត្រឹមតែប៉ុណ្ណោះ ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌនេះ នឹងឆ្លុះបញ្ចាំងឲ្យឃើញថា តួនាទីរបស់ព្រះរាជអាជ្ញាមានសារៈសំខាន់យ៉ាងណាក្នុងការចូលរួមស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះក្នុងការបង្ក្រាបបទល្មើស ក៏ដូចជាធានាសិទ្ធិរបស់ជនល្មើសក្នុងការទទួលបាននូវការជំនុំជម្រះផងដែរ។

ដោយយល់ឃើញពីសារៈសំខាន់នៃប្រធានបទនេះ ជាបឋមយើងត្រូវសិក្សាឲ្យបានស៊ីជម្រៅថាតើស្ថាប័នអយ្យការមានសមាសភាព តួនាទី ភារកិច្ច និងអំណាចយ៉ាងដូចម្តេច? ហើយអំណាចរបស់ព្រះរាជអាជ្ញាដែលជាតំណាងអយ្យការ អាចធ្វើការចោទប្រកាន់អំពីចំណាត់ការលើបណ្តឹងដែលខ្លួនបានទទួលដោយស្វែងតាមនីតិវិធីអ្វីខ្លះ? តើមានមូលហេតុអ្វីខ្លះដែលព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់?

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ សារណានេះត្រូវបានសរសេរ និងចងក្រងឡើងជា ៣ជំពូក ដែលជំពូកនីមួយៗបានបញ្ជាក់អំពីខ្លឹមសារនៃប្រធានបទទាំងស្រុង។ ជំពូកទី១ "សញ្ញាណទូទៅនៃអយ្យការអមសាលាដំបូង" រៀបរាប់អំពី៖ សមាសភាព គោលការណ៍ សមត្ថភាព តួនាទី

ភារកិច្ច និងអំណាចនៃអយ្យការអមសាលាដំបូង។ ជំពូកទី២ "ការចោទប្រកាន់របស់ព្រះរាជអាជ្ញា" ដែលបកស្រាយអំពី៖ នីតិវិធីទាំងបី ក្នុងការចោទប្រកាន់ដែលមានដូចជា ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ ចំណែកឯ ជំពូកទី៣ "ការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា" នឹងពិភាក្សាអំពី៖ មូលហេតុ នីតិវិធី ទម្រង់ការ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ និងយន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ។

# ជំពូកទី១

# សញ្ញាណទូទៅនៃអយ្យការអមសាលាដំបូង

តាមរយៈមាត្រា៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជារួមមាន តុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង។ សាលាដំបូង គឺជាសាលាជម្រះក្តី ដែលមាននៅគ្រប់រាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។ សាលាដំបូង គឺជាសាលាជម្រះក្តីជាន់ទាប ដែលអមដោយអង្គការអយ្យការមួយហៅថា អយ្យការអមសាលាដំបូង[១]។ អយ្យការអមសាលាដំបូង គឺជាស្ថាប័នតំណាងរបស់អង្គការនីតិប្រតិបត្តិ ដើម្បីការពារសណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងផលប្រយោជន៍ទូទៅ។ អយ្យការអមសាលាដំបូងមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀត តាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន[២]។ តាមន័យនេះ អង្គការនេះមានមុខងារចំបងក្នុងការធ្វើបណ្តឹងអាជ្ញា ឬជាម្ចាស់នៃបណ្តឹងអាជ្ញា មានន័យថា ជាអ្នកធ្វើការចោទប្រកាន់នៅពេលមានអំពើបង្កចលាចលដល់សង្គមណាមួយបានកើតឡើង ដែលអំពើនោះច្បាប់បានប្បញ្ញត្តិទុកជាមុនថាជាបទល្មើសព្រហ្មទណ្ឌ ហើយស្នើសុំឲ្យយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះអនុវត្តច្បាប់ថែមទៀតផង។ ដូចនេះ អយ្យការអមសាលាដំបូង គឺជាយុត្តាធិការមួយដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងវិស័យព្រហ្មទណ្ឌ ដោយជម្រុញឲ្យរឿងក្តីព្រហ្មទណ្ឌមួយអាចដំណើរការទៅមុខបាន ដើម្បីឈានទៅដល់ការបង្ក្រាបបទល្មើស ផ្តន្ទាទោសជនល្មើស និងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើល្មើសនោះផងដែរ។ ប៉ុន្តែមុនពេលឈានដល់ការស្វែងយល់ពីតួនាទីចំបងក្នុងការចោទប្រកាន់ គួរគប្បីស្វែងយល់ជាមុនអំពីសញ្ញាណទូទៅស្ថាប័ននេះ ថាតើស្ថាប័ននេះត្រូវបានបំពេញតួនាទីដោយអ្នកណា? ហើយការបំពេញតួនាទីឈរលើគោលការណ៍អ្វីខ្លះ? ហើយសមាសភាពនៃអង្គការនេះមានសមត្ថកិច្ច តួនាទី និងអំណាចយ៉ាងដូចម្តេច?។ ដើម្បីស្រាយបំភ្លឺនូវសំណួរទាំងអស់នេះ ខ្លឹមសារទាំងអស់ត្រូវបានបកស្រាយតាមផ្នែកនីមួយៗដែលមានដូចជា៖

**ផ្នែកទី១ សមាសភាពនៃអយ្យការអមសាលាដំបូង**

**ផ្នែកទី២ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ**

**ផ្នែកទី៣ សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា**

[១] មាត្រា៨ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[២] មាត្រា១០ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## ផ្នែកទី១ សមាសភាពនៃអយ្យការអមសាលាដំបូង

តាមរយៈប្បញ្ញត្តិនៃមាត្រា២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ សមាភាពនៃអយ្យការអមសាលាដំបូងមានដូចជា៖ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។

### ក. ព្រះរាជអាជ្ញា

អង្គការអយ្យការអមសាលាដំបូង ត្រូវបានដឹកនាំដោយ ព្រះរាជអាជ្ញាមួយរូប។ ព្រះរាជអាជ្ញា គឺជាប្រមុខដឹកនាំរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗ។ ព្រះរាជអាជ្ញា ប្រើប្រាស់សិទ្ធិអំណាចទាំងអស់ ដែលទទួលស្គាល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធ្វើសកម្មភាពរបស់ខ្លួនក្នុងនាមជាតំណាងអយ្យការ។

ដូចនេះ ព្រះរាជអាជ្ញា មានតួនាទីទទួលខុសត្រូវចំពោះការប្រព្រឹត្តទៅរបស់អង្គការអយ្យការទាំងមូល ដែលនាំឲ្យព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវចំពោះការងាររបស់ខ្លួនឯងផង និងការងាររបស់ព្រះរាជអាជ្ញារងទាំងអស់ផង។

### ខ. ព្រះរាជអាជ្ញារង

អង្គការអយ្យការអមសាលាដំបូង ត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាមួយរូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់[៣]។ មានន័យថា តាមអយ្យការអមសាលាដំបូងនីមួយៗអាចមានព្រះរាជអាជ្ញារងច្រើនរូប ដែលមិនអាចកំណត់ចំនួនមួយជាក់លាក់បាន ដោយអាស្រ័យលើតម្រូវការនៃការងារ និងភាពចាំបាច់។ ព្រះរាជអាជ្ញារង ត្រូវបានចាត់តាំង និងបែងចែកការងារដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញារង ប្រើប្រាស់សិទ្ធិអំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។ រាល់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងត្រូវតែធ្វើការបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយព្រះរាជអាជ្ញារងដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាម ព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តង[៤]។

ដូចនេះ ថ្វីត្បិតតែព្រះរាជអាជ្ញារង អាចប្រើប្រាស់សិទ្ធិអំណាចទាំងអស់របស់ព្រះរាជអាជ្ញាប៉ុន្តែសិទ្ធិអំណាចមួយចំនួននោះ ស្ថិតនៅក្រោមការត្រួតពិនិត្យ និងសម្រេចរបស់ព្រះរាជអាជ្ញា។

---

[៣] មាត្រា៧៤ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[៤] មាត្រា៣១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

**គ. ក្រឡាបញ្ជី**

ក្រឡាបញ្ជី ជាសមាសភាពមួយ ដែលអនុវត្តមុខងាររបស់ខ្លួនក្នុងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ នៅក្នុងអង្គការអយ្យការអមសាលាដំបូង ក៏មិនខុសពីសាលាដំបូងដែរ គឺមានក្រឡាបញ្ជីជាច្រើនរូបជាជំនួយដល់ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដើម្បីបំពេញការងារឲ្យបានងាយស្រួល ទាំងកិច្ចការរដ្ឋបាល និងចំណាត់ការលើសំណុំរឿង។ ក្រឡាបញ្ជីស្ថិតនៅក្រោមការបង្គាប់ និងដឹកនាំរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលខ្លួនស្ថិតនៅអមសម្រាប់កិច្ចការផ្នែកយុត្តាធិការ ហើយបំពេញតួនាទីលើផ្នែករដ្ឋបាល និងចំណាត់ការលើសំណុំរឿងដូចជាៈ ការធ្វើកំណត់ហេតុ ការធ្វើសេចក្តីព្រាងដីកា ឬសំណុំលិខិតផ្សេងៗសម្រាប់ព្រះរាជអាជ្ញា ការចុះលេខសំណុំឯកសារ ការរក្សាទុកសំណុំរឿង និងស្រាវជ្រាវរកឯកសារផ្សេងៗ។ល។ ក្រឡាបញ្ជី មិនអាចបំពេញកិច្ចការ ឬធ្វើការសម្រេច និងសន្និដ្ឋានណាមួយ ដែលជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងព្រះរាជ្ញារងបានឡើយ។

## ផ្នែកទី២ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

ដើម្បីធានាបាននូវយុត្តិធម៌ លុបបំបាត់ចោលនូវទិដ្ឋភាពនិទណ្ឌភាព ភាពអសកម្ម និងដំណើរការប្រព្រឹត្តទៅនៃអង្គការអយ្យការមានភាពរលូន គោលការណ៍សំខាន់ៗមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់អង្គការអយ្យការ ដោយគោលការណ៍ទាំងនោះមានដូចជាៈ គោលការណ៍ឯកភាព គោលការណ៍អវិភាគ គោលការណ៍ឯករាជ្យ គោលការណ៍នៃការមិនទទួលខុសត្រូវ និង គោលការណ៍មិនអាចប្តឹងជិតចិត្ត។

**ក. គោលការណ៍ឯកភាព**

គោលការណ៍ឯកភាព គឺជាគោលការណ៍មួយដែលតម្រូវឲ្យព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន[៥]។ តាមន័យនេះ តំណាងអយ្យការត្រូវអនុវត្តមុខងាររបស់ខ្លួនក្នុងនាម និងតាមការបង្គាប់របស់អ្នកដែលមានឋានានុក្រមខ្ពស់ជាង។ ដោយឋានានុក្រម នៃអង្គការអយ្យការត្រូវបានកំណត់ដូចជាៈ

**-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ៈ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមដែលខ្ពស់ជាងគេ នៃអង្គការអយ្យការ។ ច្បាប់បានផ្តល់អំណាចក្នុងការធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់ មានន័យថា ទាំងមហាអយ្យការអមតុលាការកំពូល មហាអយ្យការអមសាលាឧទ្ធរណ៍ និងអយ្យការអមសាលាដំបូង។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងការបំពេញមុខងារនេះ។

[៥] មាត្រា៧៥ កថាខណ្ឌទី១ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

**-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល៖** អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយហានានុក្រម នៃមហាអយ្យការអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ អគ្គព្រះរាជអាជ្ញា ដែលជានាយហានានុក្រមរបស់ខ្លួន។

**-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយហានានុក្រម នៃមហាអយ្យការអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយហានានុក្រមរបស់ខ្លួន។

**-ព្រះរាជអាជ្ញាអមសាលាដំបូង៖** ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយហានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយហានានុក្រមរបស់ខ្លួន។

**ខ. គោលការណ៍អវិភាគ**

គោលការណ៍អវិភាគ គឺជាគោលការណ៍ដែលតម្រូវឲ្យព្រះរាជអាជ្ញា ត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយ មានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះ តំណាងអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយហានានុក្រម[៦]។ រាល់លិខិតស្នាមទាំងអស់ដែលបានធ្វើដោយសមាជិកណាម្នាក់នៃអង្គការអយ្យការមួយ មានតម្លៃជាលិខិតស្នាមរបស់អង្គការអយ្យការទាំងមូល។ តាមគោលការណ៍នេះ នៅមហាអយ្យការអមតុលាការកំពូល និងអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញា ទោះបីជានៅពេលមានវត្តមាន ឬអវត្តមានអគ្គព្រះរាជអាជ្ញាក៏ដោយ។ ឯនៅអយ្យការអមសាលាដំបូង ព្រះរាជអាជ្ញារងធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា ទោះបីជានៅពេលមានវត្តមាន ឬអវត្តមានព្រះរាជអាជ្ញាក៏ដោយ។

**គ. គោលការណ៍ឯករាជ្យ**

អង្គការអយ្យការ គឺជាអង្គឯករាជ្យ ទោះបីស្ថិតនៅអមសាលាជម្រះក្តីក៏ដោយ ក៏មិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះដែរ ពោលអង្គការអយ្យការជាស្ថាប័នឯករាជ្យមិនចំណុះឲ្យសាលាជម្រះក្តី។ សាលាជម្រះក្តី ក៏គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញា

[៦] មាត្រា៧៥ កថាខណ្ឌទី២ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ឡើយ។ នៅពេលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារ សាលាជម្រះក្តីមិនអាចចុះសេចក្តីសម្រេចរបស់ខ្លួនឬ ធ្វើការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅនាយកឋានានុក្រមរបស់ព្រះរាជអាជ្ញា ដើម្បីឲ្យធ្វើចំណាត់ការអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញានោះ[៧]។

### ឃ. គោលការណ៍នៃការមិនទទួលខុសត្រូវ

ព្រះរាជអាជ្ញាក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ អាចធ្វើការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណា ដែលខ្លួនយល់ថាជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីខ្លះ អង្គហេតុដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នោះ អាចនឹងត្រូវច្រានចោល ដោយចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ ប្រសិនបើអង្គហេតុនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬមិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ជាអាទិ៍។ ប្រសិនបើមានករណីនេះកើតឡើង ព្រះរាជអាជ្ញាមិនអាចត្រូវបានតម្រូវឲ្យមានការទទួលខុសត្រូវនូវរាល់ការខូចខាតទាំងឡាយ ដែលកើតចេញពីការសម្រេចរបស់ខ្លួនលើភាគីនៃរឿងក្តីជាពិសេស ជនត្រូវចោទ ឬជនជាប់ចោទនៅក្នុងសំណុំរឿងចោទប្រកាន់របស់ខ្លួនឡើយ។ ប៉ុន្តែចំពោះគោលការណ៍នៃការមិនទទួលខុសត្រូវនៃអង្គការអយ្យការនេះ មិនអាចនាំឲ្យព្រះរាជអាជ្ញារួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលដែលមានការប្រព្រឹត្តកំហុសព្រហ្មទណ្ឌ ដែលកើតចេញពីឆន្ទៈទុច្ចរិតក្នុងការបំពេញមុខងាររបស់ខ្លួនបានទេ ឧទាហរណ៍៖ ការទទួលសំណូក ដើម្បីជាថ្នូរនឹងការសម្រេចមិនធ្វើការចោទប្រកាន់ជាអាទិ៍។ ហេតុនេះហើយ ប្រសិនបើព្រះរាជអាជ្ញាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយនៅក្នុងការអនុវត្តកិច្ចចោទប្រកាន់របស់គាត់ នោះព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្តជានិច្ច។

### ង. គោលការណ៍មិនអាចប្តឹងជំទាស់

ជាទូទៅ តុលាការដែលមានតួនាទីស្វែងរកយុត្តិធម៌ឲ្យកូនក្តី មិនត្រូវមានភាពលម្អៀងទៅលើភាគីណាមួយឡើយ ហើយបើភាគីណាយល់ឃើញថា សមាសភាពជំនុំជម្រះមិនអាចរកយុត្តិធម៌ឲ្យខ្លួនបានដោយសារមូលហេតុណាមួយ នោះភាគីនោះមានសិទ្ធិសុំផ្លាស់ប្តូរសមាសភាពជំនុំជម្រះនោះបាន។ ដោយឡែកនៅក្នុងរឿងព្រហ្មទណ្ឌ អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលជាតំណាងអយ្យការនៅអមសាលាដំបូងរាជធានី-ខេត្ត មិនអាចត្រូវភាគីពាក់ព័ន្ធណាមួយអាចប្តឹងជំទាស់បានទេ ទោះបីជាព្រះរាជអាជ្ញាមានពាក់ព័ន្ធជាសាច់ញាតិ ឬមានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយ ក៏ភាគីមិនអាចប្តឹងជំទាស់បានដែរ ព្រោះព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ក្នុង

[៧] មាត្រា៧៥ កថាខណ្ឌទី៣ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

នាមជាអ្នកតំណាងឲ្យរដ្ឋ ហើយគាត់មិនតំណាងឲ្យខ្លួនឯងទេ។ម្យ៉ាងវិញទៀតការចោទប្រកាន់នេះ មិនមែនមានន័យថា បុគ្គលដែលជាជនត្រូវចោទ ឬជនជាប់ចោទនឹងត្រូវរងការផ្តន្ទាទោសដូចទៅនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញាឡើយ។ ដូចនេះ ព្រះរាជអាជ្ញាមិនអាចក្លាយជាកម្មវត្ថុនៃការធ្វើបណ្តឹងជិតចិត្តបានទេ។

## ផ្នែកទី៣ សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា

សាលាដំបូងនីមួយៗ ត្រូវបានអមដោយអយ្យការអមសាលាដំបូង ដែលត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាមួយរូប។ ដើម្បីធានានូវការប្រព្រឹត្តទៅ នៃអយ្យការអមសាលាដំបូងនីមួយៗ ឲ្យមានភាពច្បាស់លាស់ និងជៀសវាងការកើតឡើងនូវវិវាទសមត្ថកិច្ច ដូចនេះច្បាប់បានកំណត់អំពីវង្វង់នៃដែនសមត្ថកិច្ចរបស់ព្រះរាជអាជ្ញានីមួយៗ ដែលត្រូវបំពេញ តួនាទី ភារកិច្ច និង អំណាចក្នុងទំហំនៃដែនសមត្ថកិច្ចនោះ។

### ក. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

នៅពេលមានបទល្មើសមួយកើតឡើង ការស្រាវជ្រាវលើបទល្មើសអាចនឹងធ្វើឡើងនៅច្រើនកន្លែង ដែលពាក់ព័ន្ធនឹងបទល្មើសនោះដូចជា៖ ទីកន្លែងប្រព្រឹត្តបទល្មើល ទីលំនៅរបស់ជនសង្ស័យ ទីកន្លែងចាប់ខ្លួនជនសង្ស័យជាអាទិ៍។ ដូច្នេះហើយ ដើម្បីងាយស្រួលកំណត់ថា តើព្រះរាជអាជ្ញាណាមួយដែលមានសមត្ថកិច្ចក្នុងការធ្វើចំណាត់ការលើបទល្មើសនោះ សមត្ថកិច្ចរបស់ព្រះរាជអាជ្ញាត្រូវបានបែងចែកតាមដែនដីគឺ៖

-ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនសង្ស័យថា បានប្រព្រឹត្តបទល្មើស[៨]។

### ខ. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានតួនាទីយ៉ាងសកម្មក្នុងការចំណាត់ការរឿងក្តីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ហើយដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពនៃការស៊ើបអង្កេត ពិនិត្យមើលការអនុវត្តសេចក្តីសម្រេចរបស់តុលាការ និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឲ្យផលប្រយោជន៍សាធារណៈ។

ព្រះរាជអាជ្ញា ត្រូវបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងឲ្យបានឆាប់រហ័ស ហើយគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកំពស់សិទ្ធិមនុស្ស។ ហេតុដូច្នេះ ត្រូវរួម

[៨] មាត្រា៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចំណែកក្នុងការធានាដល់កិច្ចដំណើរការដ៏ត្រឹមត្រូវ និងការប្រព្រឹត្តទៅឲ្យបានរលូននៃប្រព័ន្ធយុត្តិធម៌លើផ្នែកព្រហ្មទណ្ឌ[៩]។

### គ. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវឈរគោលការណ៍សំខាន់ៗ ដែលមានដូចជា[១០]៖

-អនុវត្តមុខងាររបស់ខ្លួន ដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា សង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត។

-ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ឲ្យបានល្អចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលម្អៀង ព្រមទាំងយកចិត្តទុកដាក់គ្រប់កាលៈទេសៈដែលពាក់ព័ន្ធដល់ជនសង្ស័យដោយមិនត្រូវគិតថា កាលៈទេសៈនោះ មានប្រយោជន៍ ឬគ្មានប្រយោជន៍នោះទេ។

-រក្សាការសម្ងាត់នៃរឿងក្ដី លើកលែងតែដើម្បីបំពេញភារកិច្ច ឬដើម្បីតម្រូវការរបស់តុលាការដើម្បីបញ្ជាក់អំពីភាពយុត្តិធម៌។

-ពិនិត្យមើលពីទិដ្ឋភាព និងក្ដីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់របស់ពួកគេ និងធានាថា ជនរងគ្រោះត្រូវបានប្រាប់ពីសិទ្ធិរបស់ពួកគេ ដោយអនុលោមតាមសេចក្ដីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌ សម្រាប់ជនរងគ្រោះពីបទល្មើស និងការរំលោភអំណាចផ្សេងៗ។

### ឃ. អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ប្រើប្រាស់សិទ្ធិ និងអំណាចរបស់ខ្លួនស្របតាមច្បាប់ ឬបទដ្ឋានគតិយុត្ត ដែលបានកំណត់ និងផ្ដល់ឲ្យ។ នៅក្នុងដំណាក់កាលនៃការចោទប្រកាន់ គឺជាដំណាក់កាល ដែលព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ច និងទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿង។ អំណាចរបស់ព្រះរាជអាជ្ញា ដែលអាចមាននៅក្នុងដំណាក់កាលនេះ អាចធ្វើការបែងចែកជា ៣គឺ៖ អំណាចលើនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

[៩] គោលការណ៍ណែនាំស្ដីពី "តួនាទីរបស់ព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

[១០] គោលការណ៍ណែនាំស្ដីពី "តួនាទីរបស់ព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

**-អំណាចលើនគរបាលយុត្តិធម៌[១១]៖** ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស នោះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់ខ្លួន។ នៅក្នុងករណីចាំបាច់ ព្រះរាជអាជ្ញា អាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំដាក់សមាសភាព មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី ដើម្បីធ្វើការស៊ើបអង្កេតជំនួស។ ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ច ទៅអង្គភាពនគរបាលយុត្តិធម៌ បានគ្រប់ពេលវេលា ដើម្បីពិនិត្យការអនុវត្តការងារលើសំណុំរឿង។

**-អំណាចក្នុងការស៊ើបអង្កេត៖** មុននឹងសម្រេចធ្វើការចោទប្រកាន់ចំពោះអំពើណាមួយព្រះរាជអាជ្ញាត្រូវធ្វើការស៊ើបអង្កេតជាមុន ក្នុងការស្វែងរកភស្តុតាង និងធាតុផ្សំបទល្មើសឲ្យបានគ្រប់គ្រាន់។ ក្នុងការស៊ើបអង្កេត ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់ក្នុងការស៊ើបអង្កេត[១២]។ ដូច្នេះ ព្រះរាជអាជ្ញា អាចប្រើប្រាស់អំណាចទាំងអស់ក្នុងការស៊ើបអង្កេត ទោះបីជាការស៊ើបអង្កេតបឋមក្តី ការស៊ើបអង្កេតករណីជាក់ស្តែងក្តី ដែលអំណាចទាំងនោះមានដូចជា៖ ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ការបញ្ជាឲ្យចូលខ្លួន ការធ្វើកោសល្យវិច័យ ការឃាត់ខ្លួន។ល។

**-អំណាចក្នុងការចោទប្រកាន់៖** ការចោទប្រកាន់ គឺជាអំណាចចំបង និងសំខាន់បំផុត ដែល ព្រះរាជអាជ្ញាប្រើប្រាស់ ដើម្បីឲ្យសំណុំរឿងព្រហ្មទណ្ឌមួយអាចដំណើរការទៅដំណាក់កាលបន្ទាប់បាន។ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ អំណាចក្នុងការចោទប្រកាន់បានផ្តល់ឲ្យព្រះរាជអាជ្ញា ក្នុងការជ្រើសរើសវិធីក្នុងការចោទប្រកាន់ ឬសម្រេចមិនធ្វើការចោទប្រកាន់ ដោយត្រូវបានហៅថា "**ជម្រើសនៃការចោទប្រកាន់**" ឬ "**គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**" ដែលនឹងត្រូវបកស្រាយក្នុងជំពូកបន្តបន្ទាប់។

[១១] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១២] មាត្រា៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី២
# ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

នៅក្នុងដំណើរក្តីព្រហ្មទណ្ឌ ដំណាក់កាលចោទប្រកាន់គឺជាដំណាក់កាលមួយដែលអនុវត្ត ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាគឺជាម្ចាស់បណ្តឹងអាជ្ញានៅក្នុងការធ្វើបណ្តឹង និងចោទប្រកាន់ជន ល្មើស។ បណ្តឹងអាជ្ញានេះអនុវត្តលើគ្រប់បុគ្គលទាំងអស់ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដោយឥត ប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គមធនធាន ឬស្ថានភាពឯទៀតឡើយ[១៣]។ ម្យ៉ាងវិញទៀតការចោទប្រកាន់ត្រូវបានធ្វើឡើង បន្ទាប់ពីព្រះរាជអាជ្ញាទទួលបានបណ្តឹងដោយពាក្យប្តឹង និងពាក្យបរិហារពីសំណាក់ជនរងគ្រោះ ដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ដែលបញ្ជូនមក[១៤]។ ជាគោលការណ៍ ព្រះរាជអាជ្ញា ដែលតាំងខ្លួនជាម្ចាស់បណ្តឹងអាជ្ញាតែងតែប្រកាន់ខ្ជាប់នូវតួនាទីរបស់ខ្លួន ក្នុងការធានាសណ្តាប់ធ្នាប់ សាធារណៈ និងការពារផលប្រយោជន៍ទូទៅ ដូចនេះព្រះរាជអាជ្ញាមិនអាចបដិសេធសំណុំរឿងណា មួយដោយមិនធ្វើការចោទប្រកាន់នោះទេ បើសំណុំរឿងនោះ ត្រូវបានពិនិត្យឃើញថា មានអត្ថិភាព នៃបទល្មើស និងជនល្មើសមានពិរុទ្ធភាព ហើយមានស្ថានភាពចាំបាច់ដើម្បីសម្រេចធ្វើការចោទ ប្រកាន់។

តើអ្វីទៅជាការចោទប្រកាន់របស់ព្រះរាជអាជ្ញា? ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺជា ចំណាត់ការមួយដែលមានអានុភាព ផ្ទេរសមត្ថកិច្ចពីអយ្យការ ទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការ ជំនុំជម្រះ ឬម្យ៉ាងទៀតគេអាចនិយាយបានថា ជាការបញ្ជូនជនល្មើសមួយ ឬច្រើននាក់ទៅចំពោះ មុខចៅក្រមស៊ើបសួរ ឬចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌដើម្បីធ្វើការផ្តន្ទាទោសតាមបញ្ញត្តិ ច្បាប់។ ដោយយោងតាមមាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ការចោទប្រកាន់នេះអាចធ្វើឡើងដោយស្តែងតាមនីតិវិធីបីយ៉ាងគឺ៖

**ផ្នែកទី១ ការបើកការស៊ើបសួរ**

**ផ្នែកទី២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

**ផ្នែកទី៣ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

[១៣] មាត្រា៣ នៃក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១៤] មាត្រា៤០ នៃក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី១ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាការប្តឹងរបស់ព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរ ឲ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហើយការស្រាវជ្រាវទៅលើអង្គហេតុរបស់ចៅក្រមស៊ើបសួរ គឺមានលក្ខណៈខុសពីការស្រាវជ្រាវរបស់ព្រះរាជអាជ្ញាពីព្រោះថាព្រះរាជអាជ្ញានៅពេលដែលស្រាវជ្រាវរកព័ត៌មាន និងភស្តុតាងទាំងឡាយណា ដើម្បីកំណត់ឲ្យឃើញអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌដើម្បីធ្វើការចោទប្រកាន់។ ប៉ុន្តែនៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅឲ្យចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ចៅក្រមស៊ើបសួរបំពេញកិច្ច ធ្វើការស្រាវជ្រាវ ដើម្បីស្វែងរកឲ្យឃើញការពិតអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ហើយក្នុងខណៈនោះចៅក្រមស៊ើបសួរនឹងធ្វើការស្រាវជ្រាវនូវគ្រប់ទិន្នន័យ ឬពត៌មានទាំងអស់ដែលមានទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[១៥]។ គួរបញ្ជាក់ផងដែរថា ការបើកការស៊ើបសួរត្រូវតែធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គ្មានកិច្ចស៊ើបសួរណាមួយដែលអាចធ្វើឡើងដោយគ្មានដីកានេះបានទេ[១៦]។ ការស៊ើបសួរត្រូវបានបើកប្រឆាំងលើ បុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន[១៧]។ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរនេះ ត្រូវបានទាមទារឲ្យមានការគោរពនូវលក្ខខណ្ឌអនុគ្រោះមួយចំនួន ហើយស្របទៅតាមនីតិវិធីជាក់លាក់ និងតាមទម្រង់ការ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាដាច់ខាត និងដើម្បីបង្កើតឲ្យមានអានុភាពផ្សេងៗទៀត។

### ក. លក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចង្អុលបង្ហាញអំពីលក្ខខណ្ឌមួយចំនួនដើម្បីឲ្យឈានទៅដល់ការបើកការស៊ើបសួរ ដោយស្របតាមនីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ លក្ខខណ្ឌនោះ គឺសំដៅទៅដល់ការកំណត់មើលអំពីប្រភេទនៃបទល្មើសជាមុនសិន មុននឹងព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបើកការស៊ើបសួរ។

តាមរយៈមាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានប្បញ្ញត្តិអំពីប្រភេទនៃបទល្មើសដែលអាចបើកការស៊ើបសួរមានពីរ គឺបទឧក្រិដ្ឋ និងបទមជ្ឈិម។

---

[១៥] មាត្រា១២៧ កថាខណ្ឌទី២ នៃក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១៦] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១៧] មាត្រា៤៤ កថាខណ្ឌទី២ នៃក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៧

**-ចំពោះបទឧក្រិដ្ឋ៖** ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ[18]។ គ្មានបទឧក្រិដ្ឋណាមួយដែលត្រូវបានជំនុំជម្រះដោយពុំបានឆ្លងកាត់ដំណាក់កាលនៃការបើកការស៊ើបសួរនោះទេ ពីព្រោះបទឧក្រិដ្ឋជាប្រភេទបទល្មើសមួយដែលមានលក្ខណៈធ្ងន់ធ្ងរ មានអប្បបរមានៃទោសដាក់ពន្ធនាគារចាប់ពី៥ឆ្នាំទៅ៣០ឆ្នាំ ឬអស់មួយជីវិត[19]។ ដោយសារកម្រិតទោសនេះធ្ងន់ធ្ងរ ដូចនេះទាមទារនូវការស្រាវជ្រាវឲ្យបានហ្មត់ចត់មុននឹងសម្រេចយកជនល្មើសទៅចំពោះមុខតុលាការធ្វើការជនុំជម្រះ ពីព្រោះដើម្បីជៀសវាងការជំនុំជម្រះធ្វើឡើងដោយមានការភាន់ច្រឡំ ឬធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនដែលត្រូវគេចោទប្រកាន់ និងដើម្បីធានាឲ្យដំណើរការរឿងក្តីប្រកបដោយយុត្តិធម៌។ ការស៊ើបសួរជាមុនចំពោះបទឧក្រិដ្ឋដែលធ្វើឡើង ដោយចៅក្រមស៊ើបសួរក្នុងការស៊ើប ទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដែលចំណុចនេះ គឺដើម្បីស្វែងឲ្យដឹងការពិត និងលាតត្រដាងកាន់តែច្បាស់មួយ កម្រិតទៀតក្រៅពីការជំនុំជម្រះរបស់យុត្តាធិការជំនុំជម្រះ។

**-ចំពោះបទមជ្ឈិម៖** ដោយយោងតាមមាត្រា៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់ថា ព្រះរាជអាជ្ញាអាចប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមចំពោះប្រភេទបទមជ្ឈិមនេះ ហើយព្រះរាជអាជ្ញាក៏អាចប្រើនីតិវិធីបើកការស៊ើបសួរបានដែរ។ បទមជ្ឈិម ជាប្រភេទនៃបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ៦ថ្ងៃដល់ ៥ឆ្នាំ[20]។ ដោយឡែក ការបើកការស៊ើបសួរចំពោះបទមជ្ឈិមនេះ គឺគេពុំបានចែងច្បាស់ថាជាប្រភេទបទមជ្ឈិមស្មុគស្មាញ ឬយ៉ាងណាទេ ក៏ប៉ុន្តែតាមស្មារតីនៃក្រមគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងអំពីស្ថានភាពនៃបទល្មើស ប្រសិនបើបទល្មើសដែលជនត្រូវចោទបានប្រព្រឹត្តជាបទមជ្ឈិម ប៉ុន្តែមិនមានភស្តុតាងគ្រប់គ្រាន់ ឬជនល្មើសជាអញ្ញាតជនពុំមានអត្តសញ្ញាណច្បាស់លាស់ ហើយសំណុំរឿងមិនទាន់មូល ពោលគឺមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការជំនុំជម្រះបាន ដូចនេះព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់តាមនីតិវិធីបើកការស៊ើបសួរ។

**ឧទាហរណ៍៖** កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ មានបុរសម្នាក់បានជិះម៉ូតូម៉ាកហុងដាពណ៌ខ្មៅ បានឆក់យកកាបូបរបស់កញ្ញា ដានី ដែលកំពុងតែជិះម៉ូតូតាមផ្លូវ។ បន្ទាប់ពីធ្វើសកម្មភាពឆក់ហើយបុរសនោះ ក៏ជិះម៉ូតូទៅបាត់ដោយសុវត្ថិភាព ហើយពុំមាននរណាម្នាក់ស្គាល់ពីអត្តសញ្ញាណជនសង្ស័យនោះទេ។ ក្នុងករណីនេះ ជាប្រភេទបទមជ្ឈិម ហើយព្រះរាជអាជ្ញាអាចធ្វើការ

---

[18] មាត្រា៤៤កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[19] មាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[20] មាត្រា៤៧ កថាខណ្ឌទី១ និងទី៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចោទប្រកាន់ តាមរយៈការបើកការស៊ើបសួរបាន ពីព្រោះជននោះជាអញ្ញាតជន ពោលគឺជនមិនស្គាល់មុខ ហើយត្រូវការស្រាវជ្រាវបន្ថែម ក្នុងការស្វែងរកអត្តសញ្ញាណ ភស្តុតាង ក៏ដូចជាចាប់ខ្លួនជននេះមកចំពោះមុខចៅក្រមស៊ើបសួរ។

ជារួមមក គ្រប់ស្ថានភាពនៃបទល្មើសដែលត្រូវបានចាត់ចូលជាប្រភេទ បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលមានលក្ខណៈដូចដែលបានរៀបរាប់ខាងលើ គឺត្រូវតែធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ។

## ខ. នីតិវិធីនៃការបើកការស៊ើបសួរ

ក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាទទួលសំណុំរឿងតាមរយៈការដាក់ពាក្យបណ្ដឹងដោយផ្ទាល់របស់ដើមបណ្ដឹងដែលបញ្ជូនមកព្រះរាជអាជ្ញា ឬតាមរយៈការបញ្ជូនសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌។ ដូចនេះ មុននឹងសម្រេចបើកការស៊ើបសួរ ព្រះរាជអាជ្ញាធ្វើការវាយតម្លៃ និងវិនិច្ឆ័យលើសំណុំរឿងតាមប្រភពនៃការបញ្ជូននីមួយៗ។

### ១. ការបើកការស៊ើបសួរតាមរយៈពាក្យបណ្ដឹងបញ្ជូនមកដោយផ្ទាល់

ដើមបណ្ដឹងអាចធ្វើការដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើចំណាត់ការចំពោះពាក្យបណ្ដឹងនោះ។ បន្ទាប់ពីព្រះរាជអាជ្ញាទទួលបានពាក្យបណ្ដឹងដោយផ្ទាល់ ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងសម្រេចធ្វើការចោទប្រកាន់តាមវិធីណាមួយ ប្រសិនបើអង្គហេតុនោះជាបទល្មើស។ ដោយនីតិវិធីនៃការថ្លឹងថ្លែង និងស្រាវជ្រាវត្រូវធ្វើឡើងរយៈ ការសុំទៅមន្ត្រីនគរបាលយុត្តិធម៌ឲ្យធ្វើការស៊ើបអង្កេតបឋម[២១] ឬការកោះហៅ ដើមបណ្ដឹង ជនសង្ស័យ សាក្សី ដើម្បីសួរ និងស្ដាប់ចម្លើយដោយផ្ទាល់។ បន្ទាប់ពីការស៊ើបអង្កេត និងស្រាវជ្រាវបានបញ្ចប់ ប្រសិនបើអង្គហេតុនោះជាបទល្មើស ហើយបានបំពេញលក្ខខណ្ឌនៃការបើកការស៊ើបសួរដូចបានបកស្រាយខាងលើ ព្រះរាជអាជ្ញានឹងសម្រេចធ្វើការបើកការស៊ើបសួរតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

### ២. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្ដឹងបរិហារ និងបណ្ដឹងទាមទារក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ហើយមន្ត្រីនគរបាលយុត្តិធម៌បើកការស៊ើបអង្កេតបឋមចំពោះបណ្ដឹងដែលខ្លួនបានទទួល ឬនៅពេលដឹងពីបទឧក្រិដ្ឋ មជ្ឈិម ឬលហុណាមួយ រួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ចំពោះករណីបទល្មើសជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់ខ្លួន និងឃាត់ខ្លួនជនសង្ស័យរួចបញ្ជូន

[២១] មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា។ ដូចនេះ នីតិវិធីក្នុងការធ្វើចំណាត់ការចំពោះសំណុំរឿង ដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើឡើងតាមករណីដូចខាងក្រោម៖

**-ករណីសំណុំរឿងគ្មានខ្លួនជនសង្ស័យ (ក្រៅឃុំ)**

សំណុំរឿងគ្មានខ្លួនជនសង្ស័យ សំដៅដល់សំណុំរឿងដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយជនសង្ស័យពុំត្រូវបានឃាត់ខ្លួន ហើយបញ្ជូនមកព្រះរាជអាជ្ញានោះទេ។ នៅពេលដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿង ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអង្គហេតុ ដោយពិនិត្យមើលភស្តុតាងដែលមានក្នុងសំណុំរឿង របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកោះហៅដើមបណ្តឹង ជនសង្ស័យ និងសាក្សី ដើម្បីសួរ និងស្តាប់ចម្លើយ។ បន្ទាប់មកប្រសិនបើអង្គហេតុខាងលើ គឺជាបទល្មើស ហើយបានបំពេញលក្ខខណ្ឌ ដែលតម្រូវឲ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ នោះព្រះរាជអាជ្ញាចេញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយកំណត់ឈ្មោះជនត្រូវចោទម្នាក់ ឬច្រើននាក់ ឬអញ្ញាតជន ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

**-ករណីសំណុំរឿងមានខ្លួនជនសង្ស័យ (ឃុំខ្លួន)**

សំណុំរឿងមានខ្លួន សំដៅដល់សំណុំរឿង ដែលជនសង្ស័យត្រូវបានចាប់ និងឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវនាំមកបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញាបន្ទាប់ពីផុតរយៈពេលឃាត់ខ្លួនបណ្តោះអាសន្ន។ នៅពេលដែលជនសង្ស័យ និងវត្ថុតាង (បើមាន) ត្រូវបានបញ្ជូនដល់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញាធ្វើការសួរចម្លើយ និងពិនិត្យលើសំណុំរឿងនោះ។ ដោយការពិនិត្យលើសំណុំរឿង ព្រះរាជអាជ្ញាធ្វើការពិនិត្យលើអង្គហេតុ ឯកសារ និងភស្តុតាងដែលមានក្នុងសំណុំរឿង របាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលជាការសន្និដ្ឋានរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយរបស់ជនត្រូវចោទ។ ប្រសិនបើពិនិត្យទៅលើសំណុំរឿងនោះហើយ យល់ឃើញថាជាបទល្មើស និងបំពេញលក្ខខណ្ឌក្នុងការបើកការស៊ើបសួរ នោះព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយព្រះរាជអាជ្ញាអាចសន្និដ្ឋានសុំឲ្យចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសន្និដ្ឋានសុំឲ្យដាក់ជនត្រូវចោទស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្ន។

**គ. ទម្រង់ការចាំបាច់ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ជាចាំបាច់ចំពោះនីតិវិធីនៃការបើកការស៊ើបសួរ ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយដីកានេះត្រូវធ្វើឡើងតាមទម្រង់ការមួយជាក់លាក់ ដើម្បីឲ្យនីតិវិធីនេះមានអានុភាពស្របតាមបញ្ញត្តិនៃក្រម។

យោងតាមមាត្រា៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានប្បញ្ញត្តិអំពីទម្រង់របស់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដូចតទៅ៖

**-សេចក្តីសង្ខេបអង្គហេតុ៖** ចំណុចនេះមានសារៈសំខាន់ណាស់ ពីព្រោះបើគ្មានអង្គហេតុណាមួយទេនោះ ចៅក្រមស៊ើបសួរនឹងមិនដឹងថា កិច្ចស៊ើបសួរនឹងត្រូវស្តែងទៅលើអង្គហេតុណាមួយទេ ព្រោះកិច្ចស៊ើបសួរអាចបើកបានតែទៅលើអង្គហេតុណា ដែលព្រះរាជអាជ្ញាចោទប្រកាន់មកតែប៉ុណ្ណោះ។ ហើយម្យ៉ាងទៀតបើគ្មានអង្គហេតុ ក៏គ្មានកិច្ចចោទប្រកាន់ណាមួយកើតមានដែរ។

**-ការកំណត់ឈ្មោះបទល្មើស៖** ការកំណត់ឈ្មោះបទល្មើស វាមានអត្ថប្រយោជន៍សម្រាប់ជំហានដំបូងនៃកិច្ចស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរនឹងមិនអាច ឬមិនទាន់អាចកំណត់ថាអង្គហេតុជាបទល្មើសអ្វីនោះ លុះបិទកិច្ចស៊ើបសួរសិនទើបមានមូលដ្ឋានគ្រប់គ្រាន់ ក្នុងការសម្រេចថាអង្គហេតុនេះជាបទល្មើសអ្វី។ ដូចនេះពិតជាមានភាពលំបាក ប្រសិនបើមិនមានការកំណត់ឈ្មោះបទល្មើសណាមួយសម្រាប់បើកកិច្ចស៊ើបសួរ ទោះជាមានការកំណត់ពីឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរលើការកំណត់បទល្មើសណាមួយជាមុនក៏ដោយ។ នេះគ្រាន់តែគិតលើស្មារតីនៃផលប្រយោជន៍តែប៉ុណ្ណោះ ប៉ុន្តែកត្តាចម្បងនេះ បើព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ខាងបទព្រហ្មទណ្ឌ តែមិនឃើញមានសរសេរថា ចោទពីបទណាមួយនោះទេ ដូច្នេះត្រូវចាត់ទុកថា គ្មានការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយឡើយ។

**-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស៖** ការកំណត់នេះ គឺជាកត្តាមូលហេតុដែលព្រះរាជអាជ្ញាអះអាងពីឈ្មោះបទល្មើស តែបើមិនសរសេរចូលក្នុងដីកាមានន័យថាគ្មានមូលដ្ឋាននៃការអះអាងលើការចោទប្រកាន់ទេ។ នេះគ្រាន់ជាការកំណត់ពីភាពច្បាស់លាស់នៃកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាប៉ុណ្ណោះ។

**-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន៖** ចំណុចនេះបើបុគ្គលជាជនល្មើសត្រូវបានស្គាល់អត្តសញ្ញាណ គឺត្រូវតែមានកំណត់ឈ្មោះរបស់ជនល្មើសនោះ ក៏ប៉ុន្តែទោះ ជាមិនមានក៏មិនអីដែរ ព្រោះកិច្ចស៊ើបសួរអាចបើកប្រឆាំងគ្រប់បុគ្គលដែលមានតម្រុយពិរុទ្ធភាព ពាក់ព័ន្ធជាមួយអង្គហេតុ ទោះជាមិនមានកំណត់ឈ្មោះរបស់ជនល្មើសក៏ដោយ។

ដីកានេះចាំបាច់ត្រូវតែចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ នេះជាទម្រង់រដ្ឋបាលដែលត្រូវតែមាន តែបើគ្មានហត្ថលេខា មានន័យថាមិនមានការទទួលស្គាល់ណាមួយរបស់ព្រះរាជអាជ្ញា ដូចនេះមិនមែនជាដីកាមានអានុភាព ឬដីកានេះមិនទាន់មានការសម្រេចរបស់ព្រះរាជអាជ្ញានៅឡើយ ដូច្នេះ គ្មានកិច្ចចោទប្រកាន់ណាមួយកើតមានទេ។

យោងតាមសារៈសំខាន់នៃទម្រង់ការដែលមិនអាចខ្វះបាន ទោះជាស្មារតីនៃផលប្រយោជន៍ ឬជាស្មារតីនៃច្បាប់ក៏ដោយ ទម្រង់នេះត្រូវបានកំណត់ជាលក្ខណៈដាច់ខាត ដែលត្រូវតែគោរព បើមិនដូច្នោះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។

**ឃ. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

បន្ទាប់ពីព្រះរាជអាជ្ញា សម្រេចចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ វានាំឲ្យដីកានេះបង្កើតឲ្យមានអានុភាពមួយចំនួនដូចជា ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកកិច្ចស៊ើបសួរ និងការកំណត់ពីដែនសមត្ថកិច្ចលើការស៊ើបសួរ។

**-ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស៖** ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមពីពេលប្រព្រឹត្តបទល្មើស។ អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ[២២]។ មានន័យថា គ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនថាតាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ការបង្ហាញភ្លាម ឬការបើកការស៊ើបសួរនោះទេ វាជាសញ្ញាណនៃការចោទប្រកាន់មួយដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស។ រីឯគ្រប់កិច្ចនៃការស៊ើបសួរ សំដៅទៅដល់កិច្ចដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលកិច្ចនេះក៏មានអានុភាពផ្តាច់អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាយុកាលផងដែរ។

**-ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកកិច្ចស៊ើបសួរ៖** គ្មានកិច្ចស៊ើបសួរណាមួយអាចបើកដោយគ្មានកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាទេ លើកលែងការដាក់ឲ្យមានចលនានៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរដែលបើកដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ កិច្ចស៊ើបសួរត្រូវមោឃភាព។ ការប្តឹងមោឃភាព គឺត្រូវប្តឹងទៅសភាស៊ើបសួរគ្រប់ពេលវេលានៅពេលដែលមានការយល់ឃើញថា កិច្ចស៊ើបសួរណាមួយស្តែងក្នុងភាពខុសនីតិវិធី។ ការចូលជាស្ថាពរនៃដីកាដំណោះស្រាយ គឺមានអានុភាពលុបលាងមោឃភាពនៃនីតិវិធីមុន មានន័យថាទោះជាកិច្ចស៊ើបសួរណាមួយដែលអាចជាកម្មវត្ថុមោឃភាពក៏ដោយ ក៏កិច្ចមោឃៈនោះមិនអាចលើកមកពិចារណាទៀតទេនៅពេលសវនាការ។ ដីកាដែលអាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍មិនអាចជាកម្មវត្ថុនៃបណ្តឹងមោឃភាពទេ ព្រោះការចែងពីចំណុចនេះដើម្បីការពារការចូលជាស្ថាពររបស់ដីកាដំណោះស្រាយ ដោយសារភាគីយល់ថា ខ្លួនបានប្តឹងមោឃៈពីដីកានេះ ភាគីបែរជាមិនធ្វើបណ្តឹងឧទ្ធរណ៍ដែលជាហេតុនាំឲ្យផុតរយៈពេលប្តឹងឧទ្ធរណ៍។ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក៏បាន

[២២] មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

កំណត់ថា បណ្ដឹងឧទ្ធរណ៍អាចជាកម្មវត្ថុនៃការពិនិត្យនិយ័តភាពនៃកិច្ចនីតិវិធីដោយសភាស៊ើបសួរឯកឯងដែរ។

**-កំណត់ពីដែនសមត្ថកិច្ចលើការស៊ើបសួរ៖** ចៅក្រមស៊ើបសួរ អាចស៊ើបសួរបានតែអង្គហេតុដែលកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ករណីលេចចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានអំពីអង្គហេតុថ្មីនោះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបាន តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[២៣]។ បើកិច្ចស៊ើបសួរដែលបើកដោយបំពានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញាទេ គឺជាកម្មវត្ថុនៃកិច្ចមោឃភាព។ តែករណីមួយចំនួនមិនបាច់សុំដីកានេះទេ ដូចជាអង្គហេតុថ្មីដែលជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ។ ដើម្បីដឹងថាមានអង្គហេតុណាខ្លះនោះ យើងគ្រាន់តែមើលច្បាប់ ដែលអះអាងយ៉ាងជាក់លាក់ទាក់ទងនឹងការកំណត់ពីស្ថានទំងន់ទោសនៃអង្គហេតុមួយដោយសារមានអង្គហេតុមួយទៀត។ ឧទាហរណ៍៖ ដូចជា បទឃាតកម្មគិតទុកជាមុន ឬដោយមានស្ថានទម្ងន់ទោសដោយសារជនរងគ្រោះ ឬដោយសារគោលដៅ ឬទារុណកម្មអំពើឃោរឃៅ ឬអំពីរំលោភសេពសន្ថវៈ និងអំពើផ្សេងៗទៀត ដែលកំណត់ក្នុងច្បាប់ព្រហ្មទណ្ឌ សុទ្ធតែជាអង្គហេតុដែលមានលក្ខណៈជាស្ថានទម្ងន់ទោសនៃបទឃាតកម្ម។

## ផ្នែកទី២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីដែលព្រះរាជអាជ្ញាបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង ដើម្បីធ្វើការជំនុំជម្រះដោយផ្ទាល់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[២៤]។ ការទទួលយកការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានគោលបំណងធានាសិទ្ធិរបស់ជនល្មើស ក្នុងការទទួលបាននូវការជំនុំជម្រះរបស់តុលាការដោយទាមទារឲ្យមានការធ្វើការចោទប្រកាន់ជនល្មើស និងបញ្ជូនអង្គហេតុទៅយុត្តាធិការជំនុំជម្រះតែម្ដង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីណាផ្សេងទៀតឡើយ។ មិនត្រឹមតែប៉ុណ្ណោះដំណើរការនៃនីតិវិធីនេះ គឺវាមានលក្ខណៈឆាប់រហ័ស ពីព្រោះការចោទប្រកាន់ត្រូវបានផ្ទេរពីសមត្ថកិច្ចរបស់អង្គការអយ្យការទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្ដង។ យ៉ាងណាមិញដើម្បីឲ្យនីតិវិធីនេះអាចប្រព្រឹត្តទៅបាន គឺទាមទារឲ្យមានការគោរពលក្ខខណ្ឌមួយចំនួន ហើយត្រូវអនុវត្តឲ្យស្រប

[២៣] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[២៤] មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

តាមនីតិវិធីមួយជាក់លាក់ ដែលនីតិវិធីនេះត្រូវតែធ្វើឡើងតាមទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឈានឲ្យមានអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះផងដែរ។

**ក. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**

មុននឹងឈានទៅដល់ការសម្រេចចោទប្រកាន់ តាមនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចាំបាច់ទាមទារឲ្យព្រះរាជអាជ្ញាគោរពនូវលក្ខខណ្ឌមួយចំនួន។ លក្ខខណ្ឌទាំងនោះ គឺសំដៅទៅដល់លក្ខខណ្ឌនៃបទល្មើស និងលក្ខខណ្ឌនៃសាវតាជាតិរបស់ជនល្មើសដែលចាំបាច់ត្រូវបំពេញ។

**១. លក្ខខណ្ឌនៃបទល្មើស**

នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ អាចធ្វើឡើងបានចំពោះ បទមជ្ឈិម និងបទលហុតែប៉ុណ្ណោះ[២៥]។

**-ចំពោះបទមជ្ឈិម៖** ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ពុំបានចែងច្បាស់ថាជាប្រភេទបទមជ្ឈិមបែបណា ដែលអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញាអនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏ដោយ ក៏ប៉ុន្តែគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងពីស្ថានភាពនៃបទល្មើស។ ដោយឡែកបើព្រះរាជអាជ្ញាមើលឃើញថា បទមជ្ឈិមនោះមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឲ្យតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យសេចក្តីលើរឿងនេះបាន ព្រះរាជអាជ្ញានឹងប្រើនីតិវិធីនៃការចោទប្រកាន់នេះ។ ផ្ទុយមកវិញបទមជ្ឈិមអាចជាកម្មវត្ថុនៃការចោទប្រកាន់តាមទម្រង់ជាការបើកការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ព្រោះមានស្ថានភាពនៃបទមជ្ឈិមមួយចំនួនត្រូវបានទទួលឲ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀតបាន។ ដូចជាស្ថានភាពនៃបទមជ្ឈិមដែលមានលក្ខណៈស្មុគ្រស្មាញ ទាមទារឲ្យមានការបើកការស៊ើបអង្កេតស្វែងរកភស្តុតាងគ្រប់គ្រាន់ ឬបទល្មើសដែលមិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម។

**ឧទាហរណ៍៖** លោក សុខា បានលួចគោរបស់អ្នកជិតខាងចំនួនពីរក្បាល។ ដល់ថ្ងៃក្រោយមកម្ចាស់គោបានដាក់ពាក្យបណ្តឹងចោទប្រកាន់លោក សុខា ដោយមានសាក្សីពីរនាក់បានឃើញយ៉ាងច្បាស់លាស់។ លើសពីនេះទៅទៀត នៅពេលដែលតំណាងអយ្យការបានកោះហៅលោក សុខា មកស្តាប់ចម្លើយ លោក ក៏បានសារភាពថាពិតជាបានលួចគោនោះមែន ដោយសារតែម្ចាស់គោបានចងទុកចោល ហើយគាត់ត្រូវការប្រាក់ជាបន្ទាន់ ដើម្បីយកទៅព្យាបាលជម្ងឺប្រពន្ធរបស់គាត់។ នៅក្នុងស្ថានភាពបែបនេះ ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីបទល្មើសដែលព្រះរាជអាជ្ញាមិនចាំបាច់បើកការស៊ើបសួរទៀតនោះទេ គឺព្រះរាជអាជ្ញា នឹងបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង។

[២៥] មាត្រា៤៥ និង៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**-ចំពោះបទលហុ៖** ព្រះរាជអាជ្ញាត្រូវតែជ្រើសរើសយកវិធីនៃការចោទប្រកាន់នេះ[២៦]។ មិនមានបទប្បញ្ញត្តិណាផ្សេងដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ ឬប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះបទលហុនោះទេ។ មូលហេតុ គឺដោយសារតែបទលហុជាបទល្មើសតូចតាច ដោយមានអតិបរិមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើ៦ថ្ងៃ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ ឬត្រឹមតែជាបទល្មើសដែលត្រូវផ្ដន្ទាទោសដែលគ្រាន់តែពិន័យជាប្រាក់ប៉ុណ្ណោះ[២៧]។ ដោយមើលឃើញថាបទលហុជាប្រភេទបទល្មើសដែលត្រូវផ្ដន្ទាទោសស្រាល ដូចនេះគ្មានជម្រើសផ្សេងដែលល្អជាង ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នោះទេ ពីព្រោះវាអាចការពារមិនឲ្យមានការប៉ះពាល់សិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងររបស់ជនជាប់ចោទ និងផ្ដល់ផលប្រយោជន៍ដល់តុលាការក្នុងការធ្វើដំណើរការរឿងក្ដីបានឆាប់រហ័សផងដែរ។

គួរបញ្ជាក់ផងដែរថា ទោះបីជាការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ចំពោះករណីបទលហុ ឬបទមជ្ឈិមក៏ដោយ ការបញ្ជូនទៅជំនុំជម្រះនេះត្រូវតែធ្វើឡើងតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។

**២. លក្ខខណ្ឌសាវតាជាតិរបស់ជនល្មើស**

ក្រៅពីការកំណត់ឲ្យបានអំពីប្រភេទនៃបទល្មើសហើយ ព្រះរាជអាជ្ញាចាំបាច់ត្រូវរកឲ្យឃើញអំពីសាវតាជាតិរបស់ជនល្មើស។ នេះក៏ជាលក្ខខណ្ឌចាំបាច់មួយដែរ ព្រោះជាស្មារតីក្នុងធ្វើបណ្ដឹងអាជ្ញា គឺមានគោលបំណងមិនត្រឹមតែស្វែងរកអត្ថិភាពនៃបទល្មើសទេ អ្វីដែលសំខាន់នោះគឺចង់ឲ្យមានការផ្ដន្ទាទោសចំពោះជនល្មើសទៀតផង។ ការចោទប្រកាន់តាមទម្រង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលមិនស្គាល់ជនល្មើស គឺមិនអាចប្រព្រឹត្តទៅបាន។ ម្យ៉ាងទៀត ក្រមនីតិវិធីទទួលស្គាល់វិសាលភាពនៃបណ្ដឹងចំពោះជនជាប់ចោទ គឺមានន័យថាតុលាការនឹងជំនុំជម្រះតែជនណា ដែលមានក្នុងពាក្យដែលប្ដឹងមកខ្លួនប៉ុណ្ណោះ។ ដូចនេះការស្គាល់អត្តសញ្ញាណជនល្មើសជាលក្ខខណ្ឌត្រូវតែមានដែលខ្វះមិនបាន។

**ខ. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជានីតិវិធីមួយដែលមិនឆ្លងកាត់ដំណាក់កាលនៃការស៊ើបសួរទេ ពោលគឺនៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យបណ្ដឹង ហើយលក្ខខណ្ឌនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវបានបំពេញ ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយបញ្ជូនសំណុំ

[២៦] មាត្រា៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[២៧] មាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

រឿងនេះទៅយុត្តាធិការជំនុំជម្រះតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់សម្រាប់កោះហៅជនជាប់ចោទ ឲ្យចូលសវនាការដើម្បីធ្វើការជំនុំជម្រះ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវប្រគល់ឲ្យជនជាប់ចោទក្នុងថិរវេលានៃការកោះហៅមួយដែលកំណត់ដោយច្បាប់ និងស្របតាមរបៀបបែបបទនៃការប្រគល់មួយច្បាស់លាស់ ជៀសវាងការបង្កើតឲ្យមានមោឃភាពនៃនីតិវិធី។

**-ថិរវេលានៃប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ[២៨]៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។

**-របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ការប្រគល់ដីកាកោះ និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវប្រគល់ដល់ជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា។ ក្នុងករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដល់ជនជាប់ចោទ។ ព្រះរាជអាជ្ញាចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកា។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកានេះ[២៩]។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ដោយអាជ្ញាសាលាបានដែរ។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឲ្យជនជាប់ចោទដោយផ្ទាល់ដៃ[៣០]។

របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចធ្វើឡើងតាមរយៈក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ក្រឡាបញ្ជី

[២៨] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[២៩] មាត្រា៤៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៣០] មាត្រា៤៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថដែលព្រះរាជអាជ្ញាសុំឲ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា[៣១]។

**-ផលវិបាកនៃការពុំបានគោរពរយៈពេលតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ក្នុងករណីដែល រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្ហាញខ្លួនភ្លាម មិនបានគោរពទេ នោះតុលាការត្រូវមានចំណាត់ការតាមករណីដូចខាងក្រោម[៣២]៖

- ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ តុលាការបង្គាប់ឲ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់។
- ផ្ទុយទៅវិញបើជននេះបែរជាមកបង្ហាញខ្លួននៅពេលសវនាការ តុលាការមិនចាំបាច់ទាមទារដីកាចោទប្រកាន់ជាថ្មីទេ ក្នុងករណីនេះតុលាការពិនិត្យមើលរឿង ប្រសិនបើជនជាប់ចោទយល់ព្រមជាក់លាក់ឲ្យជំនុំជម្រះភ្លាម តែបើជននេះមិនព្រមឲ្យជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឲ្យលើករឿងនេះទៅជំនុំជម្រះនៅពេលសវនាការលើកក្រោយទៀត។

### គ. ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

យោងតាមមាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានកំណត់ពីទម្រង់របស់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ទម្រង់របស់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះបានកំណត់នូវចំណុចជាផលប្រយោជន៍ដ៏សំខាន់ក្នុងកិច្ចជំនុំជម្រះ ហើយទម្រង់របស់ដីកានេះរួមមានដូចតទៅ៖

**-អត្តសញ្ញាណជនជាប់ចោទ៖** ការកំណត់ពីអត្តសញ្ញាណជនជាប់ចោទ គឺមានប្រយោជន៍ដល់កិច្ចជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះបុគ្គល និងមានន័យគ្រប់គ្រាន់ថាជាបណ្តឹងចោទប្រកាន់ជនល្មើស ព្រោះបើគ្មានឈ្មោះជនល្មើសមានន័យថា គ្មានការចោទប្រកាន់លើបទព្រហ្មទណ្ឌកើតមានឡើងទេ។

**-សេចក្តីសង្ខេបនៃអង្គហេតុ៖** ការកំណត់ពីសេចក្តីសង្ខេបអង្គហេតុ គឺមានប្រយោជន៍ដល់កិច្ចជំនុំជម្រះត្រង់ដែននៃការប្តឹងចំពោះអង្គហេតុ និងនាំឲ្យយើងដឹងថាបណ្តឹងប្តឹងអំពីអ្វី ព្រោះបើមិនកំណត់អង្គហេតុមានន័យថា ព្រះរាជអាជ្ញាមិនបានចោទប្រកាន់លើអង្គហេតុនោះទេ និយាយឲ្យខ្លីគឺឥតមានបណ្តឹង។

---

[៣១] មាត្រា៤៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៣២] មាត្រា៤៩១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧

**-ឈ្មោះបទល្មើស៖** សំដៅដល់បទល្មើស ដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ចំពោះជនជាប់ចោទ។ ចំពោះបទចោទប្រកាន់ តុលាការមិនជាប់កាតព្វកិច្ចចំពោះឈ្មោះបទល្មើសទេ ដោយសារតុលាការជាប់កាតព្វកិច្ចចំពោះដែននៃការប្ដឹងចំពោះអង្គហេតុ និងបុគ្គលតែប៉ុណ្ណោះ។ ដូច្នេះ តុលាការអាចសម្រេចអំពីប្រភេទបទល្មើសផ្សេងដោយសេរីចំពោះអង្គហេតុនោះ លើបុគ្គលនោះ។

**-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស៖** ការកំណត់នេះ គឺសំដៅទៅលើបទល្មើសដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ដោយត្រូវតែពឹងផ្អែកទៅលើប្បញ្ញត្តិមាត្រានៃច្បាប់។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការផងដែរ ព្រោះការជូនដំណឹងស្ដែងឡើងដោយដីកានេះតែម្ដង ដោយមិនចាំបាច់មានដីកាកោះហៅចូលសវនាការទេ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន។

### ឃ. អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ បានបង្កើតនូវអានុភាពមួយចំនួនរួមមាន ការផ្ដាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ច និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ។

**-ការផ្ដាច់អាជ្ញាយុកាលនៃបទល្មើស**

យើងបាននិយាយរួចទៅហើយទាក់ទងនឹងការបង្អាក់អាជ្ញាយុកាលនៃបទល្មើស។ បណ្ដឹងអាជ្ញាមិនអាចធ្វើបានជាដាច់ខាត កាលបើវាផុតអាជ្ញាយុកាលសំរាប់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។ អាជ្ញាយុកាលចំពោះបទល្មើស នឹងត្រូវផ្ដាច់កាលណាមានកិច្ចចោទប្រកាន់កើតមាន។ នេះជាសារៈសំខាន់ព្រោះ ថាបើមិនមានការថែងពីចំណុចនេះទេ អាជ្ញាយុកាលមិនត្រូវផ្ដាច់ទោះបីបើមានការចោទប្រកាន់រួចហើយក៏ដោយ។ ដូច្នេះ អាចមានករណី នៅពេលបណ្ដឹងបញ្ជូនទៅដល់តុលាការហើយ តែបែរជារលត់បណ្ដឹងអាជ្ញាទៅវិញ ករណីនេះតុលាការនឹងសម្រេចឲ្យជននោះរួចខ្លួន។ អាជ្ញាយុកាលចាប់រាប់ដោយគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ដោយរយៈពេល ១៥ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ឆ្នាំចំពោះបទមជ្ឈិម និង១ឆ្នាំចំពោះបទលហុ។

**-ការផ្ទេរសមត្ថកិច្ចទៅតុលាការ**

អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់[៣៣]។ ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាកិច្ចចោទប្រកាន់មួយរបស់ព្រះរាជអាជ្ញាដែលជាតំណាងរបស់អង្គការអយ្យការ ដែលតាមរយៈដីកានេះ បាននាំឲ្យមានអវត្តមាននៃកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ តែវាបានផ្ទេរសមត្ថកិច្ចពី អយ្យការ ទៅយុត្តាធិការជំនុំជម្រះវិញ។

**-ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ**

យោងតាមមាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានប្បញ្ញត្តិពីដែនកំណត់ចំពោះអង្គហេតុ។ ដែនកំណត់ចំពោះអង្គហេតុមានន័យថា តុលាការអាចជំនុំជម្រះបានត្រឹមអង្គហេតុដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ ដូចដែលបានឃើញពីការកំណត់ចំណុចមួយរបស់ទម្រង់ដីកា គឺកំណត់អំពីសេចក្ដីសង្ខេបនៃអង្គហេតុ។ តុលាការមិនអាចលើកយកអង្គហេតុទាំងឡាយណាដែលមិនបានសរសេរក្នុងដីកានោះមកជំនុំជម្រះបានទេ។ ទោះជាមានការកំណត់អង្គហេតុរួចហើយក៏ដោយ តែជួនកាលមានករណីមួយចំនួនដែលតុលាការនឹងបង្គាប់ឲ្យបង្វិលសំណុំរឿងឲ្យព្រះរាជអាជ្ញាវិញ ដោយសារករណីបទមជ្ឈិម ឬបទលហុ ត្រូវជំនុំជម្រះដោយចៅក្រមទោល ឯករណីបទឧក្រិដ្ឋចាំបាច់ត្រូវជំនុំជម្រះជាក្រុមសមូហភាពដែលមានចៅក្រមបីរូប។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នេះចេញក្នុងករណី ចោទប្រកាន់លើបទមជ្ឈិម ឬលហុ ដូចនេះបើតុលាការយល់ថា ជាបទឧក្រិដ្ឋវិញ នោះតុលាការនឹងបង្វិលសំណុំរឿងមកព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។

រីឯការកំណត់ដែនសមត្ថកិច្ចនៃការប្ដឹងចំពោះបុគ្គលមានន័យថា តុលាការនឹងអាចជំនុំជម្រះចំពោះតែជនណាដែលបានចង្អុលឈ្មោះក្នុងដីកានេះតែប៉ុណ្ណោះ។ តុលាការមិនអាចធ្វើការជំនុំជម្រះលើជនទាំងឡាយណាដែលមិនមានការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះទេ។

គួរបញ្ជាក់ផងដែរថា ក្នុងករណីការចោទប្រកាន់ធ្វើឡើងដោយដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ វាគ្មានអានុភាពបង្ខំឲ្យជនជាប់ចោទឲ្យចូលសវនាការទេ ជនជាប់ចោទមានសេរីភាពក្នុងការបង្ហាញខ្លួននៅមុខសវនាការ[៣៤]។

[៣៣] មាត្រា២៧ វាក្យខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៣៤] មាត្រា៣០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី៣ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជានីតិវិធីដែលព្រះរាជអាជ្ញាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូងដោយផ្ទាល់។ នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនេះ ជានីតិវិធីដែលមានលក្ខណៈលឿនជាងនីតិវិធីផ្សេងទៀត វាជម្រុញដល់ដំណើរការរឿងក្ដីព្រហ្មទណ្ឌឲ្យបានឆាប់រហ័ស ជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាដើម្បីសម្រួលដល់វិស័យយុត្តិធម៌ក្នុងតុលាការកម្ពុជាផងដែរ។ យ៉ាងណាមិញនីតិវិធីបង្ហាញខ្លួនភ្លាមនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅស្របតាមនីតិវិធី និងឈានទៅដល់ការបង្កើតឲ្យមានអានុភាពមួយចំនួន។

### ក. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចជ្រើសយកនីតិវិធីនៃការចោទប្រកាន់ តាមរយៈការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខសាលាដំបូង ក្នុងករណីបើមានលក្ខខណ្ឌគ្រប់ដូចខាងក្រោម៖

**-បទល្មើសដាច់ខាតត្រូវតែជាបទមជ្ឈិមជាក់ស្ដែង**

បទល្មើសនេះបានបញ្ជាក់បង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ដូច្នេះក្រៅពីបទមជ្ឈិមជាក់ស្ដែង ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានឡើយ ឬអាចនិយាយម្យ៉ាងទៀតបានថា នីតិវិធីមួយនេះមិនអាចអនុវត្តបានឡើយ ចំពោះករណីបទឧក្រិដ្ឋ មជ្ឈិមមិនជាក់ស្ដែង ឬបទលហុ។

**-បទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ យ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ**

បទល្មើសដែលមានការដាក់ពន្ធនាគារបែបនេះ សំដៅដល់បទល្មើសមិនមែនលហុមិនមែនមជ្ឈិមដែលមានការផ្ដន្ទាទោសដែលទោសអតិបរមាតិចជាង១ឆ្នាំ និងមិនមែនបទឧក្រិដ្ឋនោះទេ គឺសំដៅដល់បទមជ្ឈិម ដែលទោសអតិបរមាយ៉ាងតិចចំនួន១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ។

**-ជនជាប់ចោទជានីតិជន**

នីតិជនសំដៅដល់ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ វិធានការបានកម្រិតពីចំណុចជាច្រើនដែលនាំឲ្យមានការសន្និដ្ឋានថា នីតិវិធីនេះជាវិធានការដែលចង់ឲ្យមានការជំនុំជម្រះឲ្យលឿន និងចង់បានវត្តមានជនល្មើសនៅពេលអនុវត្តទោស ដោយអនុញ្ញាតឲ្យចៅក្រមអាចសម្រេចឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន។ ដូចនេះបើយើងយកអនីតិជនមកប្រើចំពោះនីតិវិធីបែបនេះហាក់បីដូចជា គម្រាមដល់គោលការណ៍នៃការយកចិត្តទុកដាក់បំផុតចំពោះផលប្រយោជន៍របស់អនីតិជន។ ការទទួលលក្ខខណ្ឌបែបនេះ គឺជាស្មារតីនៃការទទួលស្គាល់សិទ្ធិរបស់អនីតិជន ដោយ

ធានាថាមានពេលវេលាគ្រប់គ្រាន់សំរាប់ការពារខ្លួនរបស់អនីតិជន និងជៀសវាងការបំពាននូវសិទ្ធិរបស់អនីតិជន។

**-រឿងក្ដីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន**

ចំណុចនេះ ដូចការកំណត់របស់ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ ដោយសារបើសំណុំរឿងគ្មានបន្ទុកចោទប្រកាន់គ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់តាមទម្រង់នេះទេ។ ក្នុងករណីនេះព្រះរាជអាជ្ញាគួរពិចារណាលើការបើកការស៊ើបសួរ ឬស៊ើបអង្កេតឲ្យគ្រប់សិន។ ព្រះរាជអាជ្ញាមិនត្រូវគិតថាមានការស៊ើបអង្កេតណាមួយកើតមានក្នុងពេលជំនុំជម្រះទេ ព្រោះវាអាចជាមូលហេតុនាំឲ្យជនជាប់ចោទត្រូវបានតុលាការសម្រេចក្ដីឲ្យរួចខ្លួន ហើយព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់ជាថ្មីចំពោះអំពើដដែលលើជនដដែលទៀតទេ ដោយសារអាជ្ញាអស់ជំនុំ។

**ឧទាហរណ៍៖** លោក សម្បត្តិ អាយុ ២២ ឆ្នាំ បានខ្ចីម៉ូតូរបស់មិត្តភក្តិគាត់ ដើម្បីយកទៅប្រើប្រាស់មួយភ្លែត ប៉ុន្តែផ្ទុយទៅវិញ បែរជាយកម៉ូតូនោះទៅបញ្ចាំនៅកុងស៊ីបញ្ចាំ ហើយភ្លាមៗនោះម្ចាស់ម៉ូតូក៏តាមមកទាន់ និងចាប់ខ្លួនលោកសម្បត្តិ ប្រគល់ជូននគរបាលប៉ុស្តិ៍តែម្តង។ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ លោកបានសារភាពពីចេតនាទុច្ចរិតរបស់លោក។

នៅក្នុងស្ថានភាពបែបនេះ ព្រះរាជអាជ្ញាអាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបានពីព្រោះថា៖

-លោក សម្បត្តិ បានប្រព្រឹត្តបទមជ្ឈិម ពោលគឺបទ រំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ

-បទល្មើសនេះ គឺជាបទល្មើសជាក់ស្តែង ដោយហេតុថា លោកសម្បត្តិ ត្រូវបានចាប់ខ្លួននៅពេលដែលកំពុងតែបញ្ចាំម៉ូតូរបស់ជនរងគ្រោះ

-ជនសង្ស័យ មានអាយុ២២ឆ្នាំ គឺជានីតិជន

-រឿងក្តីនេះមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន ពីព្រោះថា លោកសម្បត្តិបានសារភាពពីចេតនាទុច្ចរិតរបស់គាត់ រួមជាមួយនឹងវត្ថុតាងជាម៉ូតូដែលលោកបានយកទៅបញ្ចាំ ហើយត្រូវបានចាប់ខ្លួនជាក់ស្តែងតែម្តង។

## ខ. នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ការចោទប្រកាន់របស់ព្រះរាជអាជ្ញា តាមរយៈនីតិវិធីបង្ហាញខ្លួនភ្លាម មានលក្ខណៈពិសេសប្លែកជាងនីតិវិធីផ្សេងៗទៀត ពីព្រោះនីតិវិធីនេះត្រូវបានបញ្ញត្តិយ៉ាងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ រីឯនីតិវិធីពីរផ្សេងទៀតពុំមានចែងច្បាស់នៅក្នុងច្បាប់ទេ។ ជាក់ស្តែងដោយយោងតាមមាត្រា៤៨ និងមាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នីតិវិធីបង្ហាញខ្លួនភ្លាមនេះត្រូវបានចែកចេញជា

ពីរដំណាក់កាលគឺ នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា និងនីតិវីធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ។

**១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា**

ជាជំហានដំបូងគឺ ជនជាប់ចោទចាំបាច់ត្រូវតែជាជនដែលត្រូវបានឃាត់ខ្លួនតាមរយៈមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បន្ទាប់ពីផុតរយៈពេលឃាត់ខ្លួនក្រោមការវិនិច្ឆ័យចំពោះមាត្រានេះ ចំពោះរយៈពេលឃាត់ខ្លួននោះ ព្រះរាជអាជ្ញាសម្រេចឲ្យមានការដោះលែងវិញ ឬព្រះរាជអាជ្ញាសម្រេចឲ្យមានការបញ្ជូនខ្លួនជននោះមក។ ក្នុងករណីដែលបញ្ជូនជននេះមក ព្រះរាជអាជ្ញានឹងសម្រេចថាខ្លួននឹងប្រើនីតិវិធីណាមួយសម្រាប់ចោទប្រកាន់។ ក្នុងករណីដែលបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលអាចប្រើការបង្ហាញខ្លួនភ្លាមនេះ ព្រះរាជអាជ្ញានឹងធ្វើដូចតទៅ៖

**-ពិនិត្យអត្តសញ្ញាណរបស់ជនដែលត្រូវបានបញ្ជូនមក**

ការធ្វើបែបនេះ ដើម្បីសម្គាល់ថានរណាជាជនល្មើស ហើយជននោះមានអត្តសញ្ញាណដូចអ្វីដែលកំណត់ហេតុបានកត់ត្រាឬទេ។

**-ត្រូវឲ្យដំណឹងដល់ជននោះអំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស**

ការទទួលយកបែបនេះ ព្រោះវាជាសិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងលឺអំពីមូលហេតុអ្វីដែលគេចោទមកខ្លួន នេះជាស្មារតីលើការទទួលស្គាល់លើសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។

**-ទទួលចម្លើយរបស់បុគ្គលនោះប្រសិនបើសាមីខ្លួនចង់និយាយ**

នេះក៏ជាសិទ្ធសេរីភាពរបស់ជនជាប់ចោទលើការអះអាងគ្រប់បែបយ៉ាង ដើម្បីការពារខ្លួន និងលើកយកព័ត៌មានគ្រប់យ៉ាងដែលខ្លួនបានដឹងជាផលប្រយោជន៍របស់ខ្លួន។

**-ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

ដើម្បីជាការចោទប្រកាន់ទៅតុលាការ ព្រះរាជអាជ្ញាត្រូវចេញកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរួចបញ្ជូនទៅតុលាការជាន់ដំបូងដើម្បីចាត់តាំងថៅក្រមជំនុំជម្រះ (ដោយប្រធានតុលាការ) ក្នុងការបើកសវនាការ។ ក្នុងកំណត់ហេតុនេះចាំបាច់ត្រូវតែមានការចែងនូវចំណុច ដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិ ក្នុងការពឹងពាក់មេធាវីដែលអាចជ្រើសរើសដោយខ្លួនឯង ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្នុងករណីនេះមេធាវីត្រូវទទួលដំណឹងភ្លាមដើម្បីទទួលស្គាល់នូវសិទ្ធិមានរយៈពេលគ្រប់គ្រាន់ ដើម្បីការពារខ្លួនរបស់ជនជាប់ចោទ។

ទម្រង់ការដែលរៀបរាប់ខាងលើ ត្រូវតែចុះចូលកំណត់ហេតុ បើមិនដូចនេះទេ នីតិវីធីត្រូវទុកជាមោឃៈ។ នៅពេលដែលកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមត្រូវបានធ្វើចប់សព្វ

គ្រប់រួចហើយ ជនជាប់ចោទនឹងត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ និងបញ្ជូនជននោះ ព្រមទាំងសំណុំរឿងទៅចំពោះមុខតុលាការ ដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។

**២. នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ**

បន្ទាប់ពីតុលាការជាន់ដំបូងទទួលបណ្តឹង តាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម។ តុលាការនឹងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទឲ្យច្បាស់លាស់ និងធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុដែលចោទប្រកាន់។ តុលាការប្រាប់ដល់ជនជាប់ចោទថាខ្លួនអាចមានរយៈពេលសម្រាប់ការពារខ្លួនបន្ថែមទៀត។

ក្នុងករណីដែលជននោះសុំរយៈពេលការពារខ្លួននោះ ឬតុលាការយល់ឃើញថា រឿងក្តីនោះមិនអាចទាន់ជំនុំជម្រះបានទេ តុលាការអាចលើកទៅជំនុំជម្រះនៅពេលក្រោយ។ ក្នុងករណីនេះតុលាការអាចសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នដោយសាលក្រមដែលមានសំអាងហេតុ។ ហេតុដែលត្រូវសំអាងនេះ គឺជាមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដូចតទៅ៖

១-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី។

២-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៤-ដើម្បីរក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥-ដើម្បីការពារសន្តិភាពឱ្យជនត្រូវចោទ។

៦-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

តុលាការក៏ទាមទារក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនដែរ ព្រោះដីកាសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នមានអានុភាពតែទៅលើជនជាប់ចោទនេះប៉ុណ្ណោះ ឯដីកាបង្គាប់ឲ្យឃុំខ្លួនមានអានុភាពជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលយក និងឲ្យឃុំខ្លួនជននោះ[៣៥]។

សាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី២សប្តាហ៍ គិតពីពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវបញ្ចប់ដោយពេញច្បាប់

[៣៥] មាត្រា២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្រោយផុតរយៈពេលនេះ មានន័យថាជនជាប់ចោទនឹងត្រូវដោះលែងឲ្យមានសេរីភាព[៣៦] ព្រោះវិធានការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការដែលបំពានដល់សិទ្ធិសេរីភាពរបស់មនុស្សយ៉ាងខ្លាំង ហើយម្យ៉ាងទៀតជននេះមិនទាន់ត្រូវបានផ្តន្ទាទោសដោយតុលាការទេ។ ការឃុំខ្លួនរបស់នីតីវិធីនេះទាមទារនូវរយៈពេលកំណត់មួយដែរ ព្រោះដើម្បីធានាថា មិនមានការបំពានណាមួយហួសហេតុដល់សេរីភាពរបស់ជននោះទោះ ដោយសារការជំនុំជម្រះយឺតយ៉ាវ។

**គ. អានុភាពនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ជានីតិវិធីចោទប្រកាន់ដែលស្តែងឡើងដោយកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ កំណត់ហេតុនេះមានអានុភាពដូចតទៅៈ

**-ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស**

ការចេញកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមដោយព្រះរាជអាជ្ញា គឺជាកិច្ចចោទប្រកាន់ជនល្មើស។ កិច្ចចោទប្រកាន់មានអានុភាពផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ។ មូលហេតុដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាល គឺដូចគ្នានឹងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរ។

**-ការផ្ទេរសមត្ថកិច្ចតុលាការ**

ជាការផ្ទេរសមត្ថកិច្ចពីអយ្យការមកយុត្តាធិការជំនុំជម្រះ តាមរយៈកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា។ តុលាការនឹងគ្មានសមត្ថកិច្ចលើការជំនុំជម្រះ ប្រសិនបើមិនមានកិច្ចចោទប្រកាន់មកខ្លួន។

**-ចំណងតុលាការចំពោះដែនបណ្តឹងចំពោះអង្គហេតុ និងបុគ្គល**

កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានការកំណត់ពីអង្គហេតុ និងពីបុគ្គលដែលព្រះរាជអាជ្ញាចង់ធ្វើការចោទប្រកាន់ទៅលើ។ តុលាការអាចជំនុំជម្រះបានតែលើអង្គហេតុណាដែលមានចែងក្នុងកំណត់ហេតុនោះ ហើយអាចជំនុំជម្រះតែលើជនណាដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តែប៉ុណ្ណោះ។

[៣៦] មាត្រា៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី៣
# ការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា

មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ត្រូវបានបង្កើតឡើង ព្រះរាជាណាចក្រកម្ពុជា អនុវត្តគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់[៣៧] ដែលគោលការណ៍នេះត្រូវបានផ្តល់ដោយច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាត្រូវតែសម្រេចធ្វើការចោទប្រកាន់នៅគ្រប់បទល្មើសទាំងអស់ ដោយមិនអាចសម្រេចមិនចោទប្រកាន់បាននោះទេ។ ក្រោយមកដោយមានការវិវត្តនៃបរិបទសង្គម កម្ពុជាបានទទួលយកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មកអនុវត្តវិញ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

តាមរយៈប្បញ្ញត្តិនៃមាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ហើយព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែមមុននឹងសម្រេចថា តើត្រូវធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើស។ តាមរយៈន័យនេះ ក្រៅពីការធ្វើការចោទប្រកាន់ដូចបានបកស្រាយក្នុងជំពូកទី២ខាងលើ ក្រមនីតិវិធីព្រហ្មទណ្ឌនេះក៏បានផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាក្នុងការមិនចោទប្រកាន់ផងដែរ។ មានន័យថា ទោះបីជាព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញាក៏ពិតមែន ប៉ុន្តែមិនមែនមានន័យថា ព្រះរាជអាជ្ញាត្រូវប្រើសិទ្ធិអំណាចធ្វើការចោទប្រកាន់ទៅលើអំពើ ដែលបង្កើតបានជាបទល្មើសទាំងអស់នោះទេ។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការតាមរយៈការវាយតម្លៃរបស់ខ្លួន ដោយធ្វើការថ្លឹងថ្លែងទៅលើស្ថានភាពដែលពាក់ព័ន្ធទៅនឹងអំពើ ទោះបីអំពើនោះច្បាប់បានប្បញ្ញត្តិថាជាបទល្មើសក៏ដោយ ដោយព្រះរាជអាជ្ញាពិចារណាទៅដល់អំពើ ដែលបង្កឲ្យមានភាពរឹករវដល់សណ្តាប់សាធារណៈក្នុងកម្រិតណាមួយ និងភស្តុតាងដែលប្រមូលបាននៅតាមរយៈការស៊ើបអង្កេតជាអាទិ៍។ ខ្លឹមសារទាំងស្រុងនៃការតម្កល់រឿងទុកឥតចាត់ការត្រូវបានបកស្រាយដោយលម្អិតតាមរយៈ ផ្នែកនានាដូចជា៖

**ផ្នែកទី១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**

**ផ្នែកទី២ ទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការ**

**ផ្នែកទី៣ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**

**ផ្នែកទី៤ យន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ**

---

[៣៧] មាត្រា៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

## ផ្នែកទី១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ថ្វីត្បិតតែព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយឆន្ទានុសិទ្ធិ តាមរយៈការថ្លឹងថ្លែងរបស់ខ្លួន ប៉ុន្តែការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះត្រូវផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមស្របដែលមានដូចជា៖ នត្ថិភាពនៃបទល្មើស មូលហេតុគតិយុត្តិ និងការចោទប្រកាន់មិនផ្តល់ប្រយោជន៍។

### ក. នត្ថិភាពនៃបទល្មើស

រាល់អំពើដែលបានបង្កើតជាព្យសនកម្ម មិនប្រាកដថាអំពើទាំងអស់នោះ គឺជាបទល្មើសព្រហ្មទណ្ឌនោះឡើយ តាមរយៈគោលការណ៍នីត្យានុកូលភាព មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន[៣៨] មានន័យថា លុះត្រាតែមានអត្ថបទច្បាប់បានចែងថាអំពើនោះជាបទល្មើស ទើបការចោទប្រកាន់អាចប្រព្រឹត្តទៅបាន។ ដូច្នេះ នត្ថិភាពនៃបទល្មើសសំដៅដល់ អវត្តមានបទល្មើស និងធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់។

#### ១. អវត្តមានបទល្មើស

នៅខណៈពេលដែលព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងទៅលើបណ្តឹង ដែលខ្លួនទទួលបានដោយផ្ទាល់ ឬដោយកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមកសព្វគ្រប់ ព្រមទាំងបានបើកការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែមហើយ តែបណ្តឹងនោះ មិនមានវត្តមាននៃបទល្មើសព្រហ្មទណ្ឌទេ នោះព្រះរាជអាជ្ញានឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ។ អវត្តមានបទល្មើសសំដៅដល់បណ្តឹងដែលធ្វើឡើងប្រឆាំងនឹងអំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ដែលអាចជាបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្តឹងខុសសមត្ថកិច្ចតុលាការ ឬការបញ្ជូនកំណត់ហេតុដោយមន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើសេចក្តីសន្និដ្ឋានដោយភាន់ច្រឡំ ឬខុស។

#### ២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ លុះត្រាតែអំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់។ ករណីដែលមានធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ វាជាកត្តាមួយដែលនាំឲ្យព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ចំពោះអំពើនោះបាន។ កាលណាព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បាន នោះការតម្កល់រឿងទុកឥតចាត់ការត្រូវបានយកមកអនុវត្ត។ ជាគោលការណ៍ធាតុផ្សំនៃបទល្មើសមានបីគឺ៖ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

---

[៣៨] មាត្រា៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

**-ធាតុនីត្យានុកូល៖** គឺជាធាតុផ្សំទាក់ទងនឹងច្បាប់។ អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ លុះត្រាតែមានច្បាប់ប្បញ្ញត្តិថា អំពើនោះ គឺជាបទល្មើស។ ឧទាហរណ៍៖ អំពើលួច គឺជាបទល្មើសព្រហ្មទណ្ឌ ព្រោះអំពើនេះត្រូវបានប្បញ្ញត្តិក្នុង មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ ថាជាបទល្មើសព្រហ្មទណ្ឌ។

**-ធាតុសត្យានុម័ត៖** ធាតុសត្យានុម័តនេះ អាចហៅម្យ៉ាងទៀតថា ធាតុផ្សំសម្ភារៈ ដែលជាអង្គហេតុ ឬជាហេតុការណ៍ទាំងឡាយណាដែលបង្កឲ្យកើតមាននូវអាកប្បកិរិយាណាមួយ ដែលត្រូវបានកំណត់ក្នុងអត្ថបទច្បាប់ដែលបញ្ជាក់ថាជាបទល្មើស។ អង្គហេតុទាំងនោះមានច្រើនសន្ធឹកសន្ធាប់ណាស់ អាចជាអំពើសកម្ម អំពើអកម្ម អំពើកើតឡើងភ្លាមៗ ឬអូសបន្លាយ អំពើកើតឡើងម្តងម្កាល ឬជាទម្លាប់ជាអាទិ៍។

**-ធាតុអត្តនោម័ត៖** ជាផ្នែកខាងក្នុងនៃបទល្មើស។ ធាតុផ្សំអត្តនោម័ត គឺជាឆន្ទៈ ឬចេតនា ដែលជាកិរិយាផ្លូវចិត្តរបស់អ្នកប្រព្រឹត្តចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ ជាគោលការណ៍ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត លើកលែងតែច្បាប់បានចែងទុកជាមុន ពីបទល្មើសដែលអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ[៣៩]។

ដូចនេះ ក្នុងករណីដែលអំពើណាមួយកើតឡើង ហើយធាតុផ្សំណាមួយដែលបានរៀបរាប់ខាងលើមិនត្រូវបំពេញ ត្រូវចាត់ទុកថា ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ដែលនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

## ខ. មូលហេតុគតិយុត្ត

តាមរយៈគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ឬជម្រើសនៃការចោទប្រកាន់[៤០] ដែលត្រូវបានផ្តល់ឲ្យព្រះរាជអាជ្ញាតាមរយៈប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើការចោទប្រកាន់បាន ដោយផ្អែកលើមូលហេតុផ្សេងៗតាមការថ្លឹងថ្លែងរបស់ខ្លួន ប៉ុន្តែក្រៅពីមូលហេតុទាំងនោះ ព្រះរាជអាជ្ញាត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការផងដែរ ប្រសិនបើមានមូលហេតុគតិយុត្តណាមួយ ដែលច្បាប់តម្រូវឲ្យតម្កល់រឿងទុកឥតចាត់ការ។ ដោយមូលហេតុគតិយុត្តទាំងនោះមានដូចជា៖ ការរលត់នៃបណ្តឹងអាជ្ញា ក្រៅពីនេះមានមូលហេតុគតិយុត្តផ្សេងៗទៀត។

[៣៩] មាត្រា៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៤០] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ១. ការរលត់នៃបណ្តឹងអាជ្ញា

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់[៩១]។ មានន័យថាប្រសិនបើមានមូលហេតុណាមួយនៃការផុតរលត់នៃបណ្តឹងអាជ្ញាបានកើតឡើង ក្នុងករណីដែលនីតិវិធីបានដំណើរការដល់ដំណាក់កាលអយ្យការនោះព្រះរាជអាជ្ញាមិនអាចចាប់ផ្តើមធ្វើការចោទប្រកាន់បានទៀតទេ គឺត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ ហើយក្នុងករណីព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់រួចហើយក៏ដោយ នីតិវិធីនៅគ្រប់ដំណាក់កាលត្រូវតែបញ្ចប់។

មូលហេតុដែលនាំឲ្យមានការរលត់នៃបណ្តឹងអាជ្ញាមានដូចជា៖ មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ[៩២]។ ក្រៅពីមូលហេតុខាងលើ ក៏មានមូលហេតុផ្សេងទៀតដែលនាំឲ្យបណ្តឹងអាជ្ញាផុតរលត់ផងដែរ កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់។ មូលហេតុទាំងនោះមានដូចជា៖ ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹង នៅក្នុងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ និងដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល[៩៣]។

**-មរណភាពនៃជនល្មើស**

មរណភាពនៃជនល្មើស សំដៅដល់មរណភាពរបស់បុគ្គលដែលត្រូវបានចាត់ទុកថាជាជនដែលបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាបានប្រព្រឹត្ត ដែលអាចជាជនជាប់ចោទ ឬជនត្រូវចោទដែលកំពុងតែស្ថិតនៅក្នុងនីតិវិធីណាមួយរបស់តុលាការ។ កាលណាបើជនល្មើសបានទទួលមរណភាពហើយនោះ ជាធម្មតា ជននេះមិនត្រូវបានកំណត់ជាប្រធាននៃនីតិក្នុងការទទួលយកសិទ្ធិ និងកាតព្វកិច្ចទៀតទេ។ ម្យ៉ាងទៀតបើផ្អែកទៅលើគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ[៩៤]។ មានន័យថាគ្មានបុគ្គលណាក្រៅពីជនល្មើសមកទទួលទោសជំនួសជនល្មើសបានឡើយ ហើយបើជនល្មើសបានទទួលមរណភាពទៅហើយនោះ ដូចនេះពុំមានបុគ្គលណាទទួលខុសត្រូវព្រហ្មទណ្ឌទៀតដែរ។

[៩១] មាត្រា៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩២] មាត្រា៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៣] មាត្រា៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៤] មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

ម្យ៉ាងទៀតចំពោះរឿងព្រហ្មទណ្ឌ ការដាក់ទណ្ឌកម្ម គឺដើម្បីអប់រំកែប្រែឲ្យជនល្មើសចុះចូលក្នុងសង្គមឡើងវិញ និងដើម្បីបង្ហាញឲ្យជនដទៃទៀតខ្លាចរអារក្នុងការប្រព្រឹត្តបទល្មើស មិនមែនក្នុងគោលបំណងសងសឹកនោះទេ។ ហើយច្បាប់កម្ពុជា ក៏ពុំបានប្បញ្ញត្តិអំពីទោសសម្រាប់ប្រើប្រាស់ទៅលើសាកសពដែរ ព្រោះវាជារឿងឥតប្រយោជន៍ និងមិនអាចទៅកើតនោះទេ មិនតែប៉ុណ្ណោះមហាជនអាចយល់ថា ជាអំពើឃោរឃៅ និងអមនុស្សធម៌ថែមទៀត។

ដូចនេះដោយផ្អែកតាមអំណះអំណាងខាងលើ មរណភាពនៃជនល្មើស គឺជាមូលហេតុដ៏ត្រឹមត្រូវមួយ ដើម្បីឲ្យព្រះរាជអាជ្ញាសម្រេចមិនធ្វើការចោទប្រកាន់តាមរយៈការចេញដីកាតម្កល់រឿងទុកឥតចាត់ការ។

**-ការផុតអាជ្ញាយុកាល**

អាជ្ញាយុកាល ក្នុងរឿងព្រហ្មទណ្ឌមាន ២ គឺអាជ្ញាយុកាលនៃបទល្មើស[៩៥] និងអាជ្ញាយុកាលនៃទោស[៩៦]។ ការផុតអាជ្ញាយុកាល ត្រង់ចំណុចនេះសំដៅដល់អាជ្ញាយុកាលនៃបទល្មើស ដែលជារយៈពេលដែលច្បាប់កំណត់ក្នុងការធ្វើបណ្តឹងអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយបន្ទាប់ពីបានប្រព្រឹត្តរួច។ ដោយថិរវេលានៃអាជ្ញាយុកាលនៃបទល្មើសនេះមានភាពខុសគ្នាទៅតាមប្រភេទនៃបទល្មើសដែលត្រូវបានបែងចែកតាមរយៈទម្ងន់នៃបទល្មើស ដែលមានដូចតទៅនេះ៖

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ

ប៉ុន្តែអាជ្ញាយុកាលខាងលើ មិនត្រូវបានយកមកអនុវត្តឡើយចំពោះបទឧក្រិដ្ឋមួយចំនួនដូចជា៖ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម[៩៧]។

ប្រសិនបើថិរវេលាខាងលើត្រូវបានកន្លងផុត នោះការធ្វើបណ្តឹងអាជ្ញាដោយព្រះរាជអាជ្ញាក៏មិនអាចប្រព្រឹត្តទៅរួចដែរ ដូច្នេះ ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ។

[៩៥] មាត្រា១០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៩៦] មាត្រា១៥៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៩៧] មាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**-ការលើកលែងទោសជាទូទៅ**

រដ្ឋសភា អនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ[៤៨]។ ការលើកលែងទោសជាទូទៅនេះមានអានុភាពលុបបំបាត់ចោលនូវទណ្ឌកម្ម ដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ហើយទោសមិនអាចយកមកអនុវត្តទេ ឯទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់ ប៉ុន្តែចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ[៤៩]។ តាមរយៈន័យនេះ និយាយយ៉ាងខ្លីការលើកលែងទោសជាទូទៅមានគោលបំណង ដកចេញនូវទណ្ឌកម្មទាំងឡាយដែលត្រូវអនុវត្តចំពោះជនល្មើសដែលបានប្រព្រឹត្តបទល្មើស។

រីឯបណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនល្មើសតាមច្បាប់កំណត់[៥០] ដូចនេះ បណ្តឹងអាជ្ញា ត្រូវបានធ្វើឡើងចាប់ពីចំណុចចាប់ផ្តើមតាមរយៈការចោទប្រកាន់ដោយព្រះរាជអាជ្ញារហូតដល់គោលដៅចុងក្រោយ គឺធ្វើការអនុវត្តទោសចំពោះជនដែលបានប្រព្រឹត្តបទល្មើស។ ប៉ុន្តែច្បាប់ស្តីពីការលើកលែងទោសជាទូទៅមានអានុភាពលុបបំបាត់នូវទណ្ឌកម្មដែលពាក់ព័ន្ធទៅវិញ ដែលធ្វើឲ្យការផ្តន្ទាទោសចំពោះជនល្មើសមិនអាចប្រព្រឹត្តទៅបាន។ ហើយបើការផ្តន្ទាទោសមិនអាចប្រព្រឹត្តបាន នោះនាំឲ្យការចោទប្រកាន់ដែលជាចំណុចចាប់ផ្តើមនោះក៏គ្មានន័យដែរ ព្រោះវាផ្ទុយពីគោលបំណងចុងក្រោយនៃបណ្តឹងអាជ្ញា។

ដូច្នេះ ទើបការលើកលែងទោសជាទូទៅ ត្រូវបានច្បាប់បញ្ញត្តិជាមូលហេតុនៃការផុតរលត់នៃបណ្តឹងអាជ្ញា ដែលតម្រូវឲ្យព្រះរាជអាជ្ញាត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺជាការច្រានូវបទប្បញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌចាស់ដែលផ្ទុយនឹងបទប្បញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌថ្មី នៅពេលដែលច្បាប់ថ្មីចូលជាធរមានមានអានុភាពអនុវត្ត។ នេះគឺមានការពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលសុទ្ធសាធ ព្រោះច្បាប់ដែលកំណត់អំពើមួយជាបទល្មើស លុះត្រាច្បាប់នោះនៅជាធរមានទើបមានអានុភាពអនុវត្ត។ ដោយសារច្បាប់ចាស់ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីហើយ ដូចនេះជាគោលការណ៍ អំពើដែលច្បាប់មុនកំណត់ជាបទ

[៤៨] មាត្រា ៩០ ថ្មី (ពីរ) កថាខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
[៤៩] មាត្រា១៤៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០
[៥០] មាត្រា២ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ល្មើស តែត្រូវច្បាប់ថ្មីបដិសេធអំពើនោះមិនអាចត្រូវចោទប្រកាន់ទៀតឡើយ[៥១]។ អានុភាពនៃ បទប្បញ្ញត្តិថ្មី ដែលលុបចោលបទល្មើសនេះមិនត្រឹមតែហាមមិនឲ្យចោទប្រកាន់ទេ តែថែមទាំងកំណត់ថារាល់ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តក៏ត្រូវបញ្ចប់ ហើយបើមានការប្រកាសទោសរួចហើយ ការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត[៥២]។

**-អាជ្ញាអស់ជំនុំ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ[៥៣]។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ទៅលើជនដែលមានសាលក្រមស្ថាពរ របស់តុលាការសម្រេចឲ្យរួចខ្លួនទៅហើយនោះ ទោះបីជាព្រះរាជអាជ្ញា ធ្វើការកំណត់ឈ្មោះនៃបទល្មើសថ្មីលើអង្គហេតុចាស់ក៏ដោយ ប៉ុន្តែចំពោះដីកាតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ពុំមានអានុភាពនាំឲ្យមានអាជ្ញាអស់ជំនុំទេ[៥៤] ដូចនេះ មានន័យថា ប្រសិនបើព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអង្គហេតុមួយ ប៉ុន្តែក្រោយមកបានរកឃើញអង្គហេតុនោះជាបទល្មើសព្រហ្មទណ្ឌ ដូច្នេះព្រះរាជអាជ្ញាអាចយកអង្គហេតុនោះមកធ្វើការចោទប្រកាន់សារជាថ្មីបាន។

**-ការសម្របសម្រួលជាមួយរដ្ឋ**

ការសម្របសម្រួលជាមួយរដ្ឋ គឺជាមូលហេតុដែលនាំឲ្យមិនមានការចោទប្រកាន់តាមរយៈការតម្កល់រឿងទុកឥតចាត់ការ ប៉ុន្តែអាចធ្វើទៅបានលុះត្រាតែមានចែងក្នុងច្បាប់ដោយឡែក ដែលអនុញ្ញាតឲ្យមានការសម្របសម្រួលបាន។ ជាទូទៅការសម្របសម្រួលនេះ អាចធ្វើទៅបានលុះត្រាតែអំពើនោះមិនធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ហើយជនដែលបានប្រព្រឹត្តទទួលស្គាល់កំហុស និងបានសន្យាណាមួយ។ ប៉ុន្តែគួរកត់សម្គាល់ផងដែរថា ការសម្របសម្រួលរវាងជនរងគ្រោះ និងជនល្មើសតាមរយៈការជួសជុលសំណងការខូចខាត សំណងជម្ងឺចិត្ត មិននាំឲ្យមានការផុតរលត់នូវបណ្តឹងអាជ្ញានោះទេ វាអាចត្រឹមរំលត់បណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។

[៥១] មាត្រា៩ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០
[៥២] មាត្រា៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០
[៥៣] មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៥៤] មាត្រា៤១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការសម្របសម្រួលជាមួយរដ្ឋនេះ សង្កេតឃើញថាអាចមានជាការព្រមានជាលាយលក្ខណ៍អក្សរជាដើម។

**-ការដកពាក្យបណ្ដឹង**

ការដកពាក្យបណ្ដឹងដោយជនរងគ្រោះ អាចធ្វើទៅបានចំពោះបទល្មើសមួយចំនួនដែលច្បាប់ដោយឡែកបានចែងជាក់លាក់ ហើយពាក្យបណ្ដឹងនេះ ជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់។ បទប្បញ្ញត្តិច្បាប់ជាធរមានមួយចំនួន ដែលបានអនុញ្ញាតឲ្យជនរងគ្រោះធ្វើការដកពាក្យបណ្ដឹង ឧទាហរណ៍៖ ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ តាមរយៈមាត្រា៣៦ "ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជា បទមជ្ឈិមស្រាល ឬលហុ..."។ តាមរយៈន័យនេះ បើមានសំណើពីជនរងគ្រោះដើម្បីកុំឲ្យមានការចោទប្រកាន់ នោះព្រះរាជអាជ្ញានឹងមិនធ្វើការចោទប្រកាន់ចំពោះបទលហុ ឬ បទមជ្ឈិមស្រាលនោះឡើយ។ សំណើនេះត្រូវចាត់ទុកជាការដកពាក្យបណ្ដឹង បើសិនមានការចោទប្រកាន់រួច ដែលនាំឲ្យបណ្ដឹងអាជ្ញាត្រូវផុតរលត់។

**-ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល**

បទល្មើសមួយចំនួនអាចបញ្ចប់បានដោយមិនចាំបាច់ធ្វើបណ្ដឹងអាជ្ញា ឬចោទប្រកាន់ គឺគ្រាន់តែបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួលតែប៉ុណ្ណោះ។ ករណីភាគច្រើនសង្កេតឃើញមានអនុវត្តចំពោះបទល្មើសចរាចរណ៍។

ឧទាហរណ៍៖ មាត្រា៦៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥ "បទល្មើសចរាចរណ៍ដែលត្រូវផ្ដន្ទាទោសពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក។ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក អាចសម្រុះសម្រួលក្នុងករណីមានគ្រោះថ្នាក់ ដែលបណ្ដាលឲ្យសងតែសំណងខូចខាត"។

ដូចនេះ ចំពោះបទល្មើសដែលត្រូវផ្ដន្ទាទោសពិន័យអន្តរការណ៍ អាចអនុញ្ញាតឲ្យអ្នកប្រព្រឹត្តរួចផុតពីបណ្ដឹងអាជ្ញាបានតាមរយៈការបង់ប្រាក់ពិន័យ។

**២. មូលហេតុគតិយុត្តផ្សេងទៀត**

ក្រៅពីការផុតរលត់នៃបណ្ដឹងអាជ្ញា ដែលនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ក៏នៅមានមូលហេតុគតិយុត្តផ្សេងទៀត ដែលមានប្បញ្ញត្តិក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលនាំឲ្យព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់។ ដោយមូលហេតុគតិយុត្តិទាំងនោះមានដូចជា៖ អភ័យឯកសិទ្ធិ អនិយ័តភាពនៃនីតិវិធី និងការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស។

**-អភ័យឯកសិទ្ធិ**

អភ័យឯកសិទ្ធិ គឺជាសិទ្ធិរបស់បុគ្គលណាមួយ ដែលច្បាប់ប្បញ្ញត្តិឲ្យអំពីលក្ខខណ្ឌពិសេស ទាក់ទងនឹងកិច្ចនីតិវិធី ការទទួលខុសត្រូវ ឬការទទួលបាននូវស្ថានសម្រាលចំពោះការប្រព្រឹត្តល្មើស ណាមួយ។ តាមរយៈបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា គោលការណ៍នៃអភ័យឯកសិទ្ធិនេះ ត្រូវបានផ្តល់ឲ្យបុគ្គលមួយចំនួនប៉ុណ្ណោះ។ បុគ្គលទាំងនោះមានដូចជា ព្រះមហាក្សត្រ សមាជិករដ្ឋ សភា សមាជិកព្រឹទ្ធសភា តំណាងទូត និងអភ័យឯកសិទ្ធិគ្រូសារចំពោះបទល្មើសលួច។

ដូច្នេះ បុគ្គលដែលមានអភ័យឯកសិទ្ធិទាំងនេះ មិនអាចត្រូវបានចោទប្រកាន់បានទេ ដែល តម្រូវឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**-អនិយ័តភាពនៃនីតិវិធី**

ក្នុងចំណោមមូលហេតុជាច្រើន អនិយ័តភាពនៃនីតិវិធី ជាមូលហេតុមួយដែលព្រះរាជអាជ្ញា លើកយកមកធ្វើសំអាងមិនធ្វើការចោទប្រកាន់តាមរយៈ ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការផង ដែរ។ អនិយ័តភាពនៃនីតិវិធី គឺសំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធីក្នុងដំណើរប្រតិបត្តិការរបស់ ព្រះរាជអាជ្ញា ឬនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែមរបស់នគរបាលយុត្តិធម៌ ហើយនោះ ប្រតិបត្តិការនេះហាក់ដូចជាមិនស្របច្បាប់នីតិវិធី និងមិនបានលទ្ធផល ឬគ្មាន ប្រយោជន៍ទេ នោះព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយមូលហេតុអនិយ័តនៃ នីតិវិធី។

**-ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស**

ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស សំដៅដល់ការរួចផុតពីការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់អ្នកប្រព្រឹត្តបទល្មើសនោះ។ ដោយមូលហេតុនៃការរួចផុតពីការទទួលខុសត្រូវ ព្រហ្មទណ្ឌ ត្រូវបានកំណត់ដោយច្បាប់ ដែលត្រូវបានពិចារណាទៅលើកាលៈទេសៈនៃការប្រព្រឹត្ត ឬ បុគ្គលិកលក្ខណៈនៃជនល្មើស ដែលអាចតម្រូវឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

តាមរយៈក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០ មូលហេតុនៃការរួចផុតពីការ ទទួលខុសត្រូវព្រហ្មទណ្ឌមានដូចជា៖

- **វិបល្លាសស្មារតី[៥៥]៖** កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើត វិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវ ព្រហ្មទណ្ឌទេ។ ប៉ុន្តែបើការកើតវិបល្លាសស្មារតីនោះ បន្ថយនូវការដឹងខុសត្រូវ ឬកើតឡើង

[៥៥] មាត្រា៣១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

ដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ នោះជននោះមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។

- **ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**[៥៦]**៖** អំពើដែលអនុញ្ញាតដោយច្បាប់ ឬបទប្បញ្ញត្តិនានា និងតាមការបញ្ជារបស់អាជ្ញាធរស្របច្បាប់ ទោះមានរូបភាពជាបទល្មើសក៏ដោយ ក៏នាំឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ លើកលែងតែពាក់ព័ន្ធនឹងបទល្មើសប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម និងអំពើខុសច្បាប់ជាក់ច្បាស់ណាមួយ។
- **ការការពារស្របច្បាប់**[៥៧]**៖** ការប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ប៉ុន្តែលុះត្រាតែការការពារស្របច្បាប់បំពេញលក្ខខណ្ឌ ៣ គឺលក្ខខណ្ឌទី១៖ ភាពចាំបាច់ដើម្បីការពារខ្លួន អ្នកដទៃ ឬទ្រព្យសម្បត្តិ ដែលប្រឈមមុខនឹងការឈ្លានពាន។ លក្ខខណ្ឌទី២៖ បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។ លក្ខខណ្ឌទី៣៖ គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារ និងទម្ងន់នៃការឈ្លានពាន។
- **សច្ចធារណ៍នៃការការពារស្របច្បាប់**[៥៨]**៖** ត្រូវសន្មត់ថាជាការការពារស្របច្បាប់ ប្រសិនបើ បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ និងប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា។
- **ស្ថានភាពចាំបាច់**[៥៩]**៖** ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌ ២ គឺ៖ លក្ខខណ្ឌទី១៖ ស្ថានភាពចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ លក្ខខណ្ឌទី២៖ គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។
- **អានុភាពនៃកម្លាំង ឬការបង្ខំ**[៦០]**៖** ការប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ

[៥៦] មាត្រា៣២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៥៧] មាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៥៨] មាត្រា៣៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៥៩] មាត្រា៣៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៦០] មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ហើយមិនអាចមើលឃើញជាមុន និងមិនអាចជៀសវាងបាន។

- **ជនល្មើសជាអនីតិជនអាយុក្រោម ១៨ឆ្នាំ៖** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ[៦១]។ តែការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន គឺចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ[៦២]។ ដូចនេះ អនីតិជនអាយុក្រោម ១៨ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ជារួមមក ថ្វីត្បិតតែអំពើប្រព្រឹត្តខាងលើ គឺជាបទល្មើសក៏ពិតមែន ប៉ុន្តែច្បាប់បានប្បញ្ញត្តិថាអំពើទាំងអស់នោះជាអំពើយុត្តិកម្ម ដែលតម្រូវឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដូច្នេះព្រះរាជអាជ្ញាក៏មិនអាចធ្វើការចោទប្រកាន់បានដែរ ដែលត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### គ. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

ទោះបីជាអំពើដែលប្រព្រឹត្ត គឺជាបទល្មើសក្តី ប៉ុន្តែព្រះរាជអាជ្ញាអាចធ្វើការពិចារណាថ្លឹងថ្លែងថាគួរតែធ្វើការចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ ដោយអាស្រ័យទៅលើស្ថានភាព និងកាលៈទេសៈនានា។ ជាទូទៅកម្មវត្ថុនៃការចោទប្រកាន់ គឺជាការទាមទារឲ្យជនល្មើសមកទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ មិនតែប៉ុណ្ណោះ ក៏ចាំបាច់ផងដែរសម្រាប់ការធានាដល់សិទ្ធិជនរងគ្រោះក្នុងបទល្មើសនោះ ដើម្បីទទួលបាននូវសំណងព្យសនកម្មពីអំពើល្មើសរបស់ជនល្មើសមកលើខ្លួន។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាធ្វើការពិចារណាថ្លឹងថ្លែងមើលទៅឃើញថា ការចោទប្រកាន់នោះ ហាក់មិនបានផ្តល់នូវប្រយោជន៍ទាំងអស់ ដូច្នេះការចោទប្រកាន់ក៏ពុំមានន័យអ្វីដែរ។

ដោយមូលហេតុដែលបណ្តាលឲ្យការចោទប្រកាន់មិនផ្តល់ប្រយោជន៍ អាចបណ្តាលមកពីមូលហេតុផ្សេងៗដូចជា[៦៣]៖

-ការស្វែងរកមិនបានផល

-ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង

-ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ជនល្មើស

-ការខកខានរបស់ដើមបណ្តឹង

-អាកប្បកិរិយារបស់ជនរងគ្រោះ

[៦១] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៦២] មាត្រា៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០

[៦៣] និទ្ទេសនៃដីកាតម្កល់រឿងទុកឥតចាត់ការ

-ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

-ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស ជាអាទិ៍។

សរុបជារួមមក ការចោទប្រកាន់មិនផ្តល់ប្រយោជន៍ សំដៅដល់ការចោទប្រកាន់ដែលធ្វើឡើងនាំឲ្យខាតពេលវេលា មិនបានផ្តល់ផលប្រយោជន៍សម្រាប់ជនរងគ្រោះ ឬដើមបណ្តឹង និងផ្តល់ប្រយោជន៍សារធារណៈ ហើយហាក់មិនអាចសម្រេចនូវកម្មវត្ថុនៃការចោទប្រកាន់ ដូច្នេះវានឹងក្លាយជាកម្មវត្ថុនៃការពិចារណាលើការមិនចោទប្រកាន់ ដែលនាំឲ្យព្រះរាជអាជ្ញាធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

## ផ្នែកទី២ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការសម្រេចរបស់ព្រះរាជអាជ្ញាដោយមិនចោទប្រកាន់ចំពោះអង្គហេតុណាមួយ ដោយមូលហេតុ នត្ថិភាពនៃបទល្មើសក្តី មូលហេតុគតិយុត្តក្តី ឬដោយសារការចោទប្រកាន់មិនបានប្រយោជន៍ក្តី គឺត្រូវធ្វើឡើងតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។ ដោយការសម្រេចនេះត្រូវធ្វើឡើងតាមនីតិវិធីមួយច្បាស់លាស់ ត្រឹមត្រូវតាមទម្រង់ការនៃដីកា ដើម្បីឲ្យដីកាសម្រេចនោះមានអានុភាពក្នុងការអនុវត្ត។

### ក. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក[៦៤]។ ប្រសិនបើ ព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ទៅលើពាក្យប្តឹង ឬពាក្យបរិហារ ដែលខ្លួនបានទទួលនោះទេ ព្រះរាជអាជ្ញាត្រូវធ្វើចេញសេចក្តីសម្រេចមួយតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។

បន្ទាប់ពីព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹងនៅក្នុងបញ្ជី[៦៥]។ មានន័យថា នៅពេលដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងដល់អ្នកប្តឹង ដែលអ្នកប្តឹងត្រង់ចំណុចនេះ សំដៅដល់ ជនរងគ្រោះ អ្នកតំណាងស្របច្បាប់ និងសិទ្ធិវន្តរបស់ជនរងគ្រោះ ហើយការជូនដំណឹងនេះត្រូវធ្វើឡើងតាមរយៈ លិខិតជូនដំណឹង។ ការជូនដំណឹងនេះ ធ្វើឡើងដើម្បីគោរពនូវសិទ្ធិរបស់អ្នកប្តឹង ដើម្បីឲ្យគេបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ដែលបានសម្រេចទៅលើ

[៦៤] មាត្រា៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៥] មាត្រា៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បណ្ដឹងរបស់ខ្លួន ហើយក៏ដើម្បីធានានូវសិទ្ធិរបស់អ្នកប្ដឹងក្នុងការតវ៉ាទៅនឹងសេចក្ដីសម្រេចនេះផងដែរ។

រីឯរយៈពេលនៃការឲ្យដំណឹង ត្រូវធ្វើឡើងយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ខែ គិតចាប់ពីថ្ងៃចុះពាក្យប្ដឹងនៅក្នុងបញ្ជី ដូចនេះមានន័យថា ការឲ្យដំណឹងធ្វើឡើងកាន់តែឆាប់ គឺកាន់តែល្អសម្រាប់អ្នកប្ដឹង ដើម្បីឲ្យគាត់បានទទួលដំណឹងបានលឿន ដែលនាំឲ្យមិនអូសបន្លាយពេលវេលាយូរសម្រាប់គាត់ក្នុងការសម្រេចចិត្តទទួលយកសេចក្ដីសម្រេច ឬតវ៉ាទៅនឹងសេចក្ដីសម្រេចនោះ។ ហើយរយៈពេលឲ្យដំណឹងនេះ បើមិនអាចធ្វើឡើងបានឆាប់រហ័សទេ គឺមិនអាចឲ្យលើសរយៈពេល ២ខែនោះទេ។ ដោយរយៈពេលឲ្យដំណឹងខាងលើ គឺត្រូវគិតចាប់ពីថ្ងៃចុះពាក្យប្ដឹងក្នុងបញ្ជី ដែលបញ្ជីនោះជា បញ្ជីអយ្យការសម្រាប់ចុះបណ្ដឹងនៅតាមតុលាការជាន់ដំបូងនីមួយៗ ហើយស្ថិតនៅក្រោមការកាន់កាប់របស់លេខាធិការរបស់អយ្យការ និងក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាផ្ទាល់[៦៦]។

## ខ. ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ។ ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ សំដៅដល់ធាតុទាំងឡាយដែលមានក្នុងដីកាតម្កល់រឿងទុកឥតចាត់ការ ដែលតម្រូវឲ្យមាន ដើម្បីឲ្យដីកានេះមានភាពត្រឹមត្រូវ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ពុំមានប្បញ្ញត្តិពីទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការបានច្បាស់លាស់នោះទេ ប៉ុន្តែគ្រាន់តែបានប្បញ្ញត្តិថា ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់[៦៧]។ តាមន័យនេះ ដីកាតម្កល់រឿងទុកឥតចាត់ការ ដាច់ខាតត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់ដែលជាលក្ខខណ្ឌចាំបាច់ដោយពុំអាចខ្វះបាន។

សំអាងហេតុ សំដៅដល់ការលើយកនូវអង្គហេតុទាំងឡាយដែលពាក់ព័ន្ធមកធ្វើជាសំអាងដែលជាមូលហេតុដែលនាំឲ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។ រីឯសំអាងច្បាប់ គឺជាការលើកយកនូវអត្ថបទច្បាប់ដែលគាំទ្រដល់អង្គហេតុ និងជាមូលហេតុដែលធ្វើឲ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

[៦៦] មាត្រា៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៧] មាត្រា៤១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## គ. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គ្មានអាជ្ញាអស់ជំនុំទេ[៦៨]។ គោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ[៦៩] ប៉ុន្តែការតម្កល់រឿងទុកឥតចាត់ការ ពុំបានបង្កើតឲ្យមានអានុភាពអាជ្ញាអស់ជំនុំនោះទេ មានន័យថា ប្រសិនបើព្រះរាជអាជ្ញាសម្រេចធ្វើការមិនចោទប្រកាន់ចំពោះជនណារួចហើយ មិនមែនមានន័យថាជននោះរួចផុតពីការចោទប្រកាន់ជាស្ថាពរនោះទេ ក្នុងករណីដែលលេចឡើង ឬក៏ព្រះរាជអាជ្ញាទទួលបានភស្តុតាងសម្រាប់ដាក់បន្ទុកក្នុងការចោទប្រកាន់បាននោះ ព្រះរាជអាជ្ញាអាចលើកយករឿងនោះមកចោទប្រកាន់សារជាថ្មីបាន។ ការអនុវត្ត ភាពគ្មានអាជ្ញាអស់ជំនុំនេះ ព្រោះការសម្រេចមិនចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការជាការសម្រេចមួយដោយឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា មានន័យថានីតិវិធីនេះ ផ្តោតសំខាន់ទៅលើការយល់ឃើញរបស់ព្រះរាជអាជ្ញា ដូចនេះវាបានធានាដល់សិទ្ធិរបស់ជនរងគ្រោះនៃអំពើល្មើស ដើម្បីឲ្យមានការសើរើឡើងវិញចំពោះការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាធ្វើការសម្រេចដោយមានការខុសឆ្គង ឬចន្លោះប្រហោងត្រង់ចំណុចណាមួយ។

ជារួមមក ការកំណត់ពីអាជ្ញាអស់ជំនុំមិនអាចស្តែងឡើងបានទេ ដោយគ្រាន់តែពឹងលើការយល់ឃើញរបស់ព្រះរាជអាជ្ញា។ ហើយភាពគ្មានអាជ្ញាអស់ជំនុំ នាំឲ្យព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់ជាថ្មីលើអង្គហេតុដដែលនៅពេលដែលខ្លួនយល់ឃើញថា អង្គហេតុនោះបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែលើកលែងតែមានការផុតរលត់បណ្តឹងអាជ្ញា។

## ផ្នែកទី៣ យន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ

ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីមានលក្ខណៈមិនដាច់ខាត ដែលព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់ជនណាមួយពីបទល្មើសព្រហ្មទណ្ឌ។ ការសម្រេចមិនចោទប្រកាន់អាចជាការថ្លឹងថ្លែងប្រកបដោយភាពត្រឹមត្រូវ តែក៏អាចជាការខុសឆ្គងលើការសម្រេចមិនចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាដែរ ដូចនេះដើម្បីធានាថា ទោះជាមានការតម្កល់រឿងទុកឥតចាត់ការយ៉ាងណាក៏ដោយ ក៏វាត្រូវបានយកមកដោះស្រាយដោយយន្តការបន្តលើចំណាត់ការនេះ។ ដោយយន្តការទាំងនោះត្រូវធ្វើឡើងតាមរយៈ ការសើរើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា

[៦៨] មាត្រា៤១ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៩] មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ និងការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

**ក. ការសើរើកែប្រែសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា**

ប្រសិនបើព្រះរាជអាជ្ញាបានសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយពុំមានការតវ៉ាតាមរយៈយន្តការណាមួយដែលធ្វើឡើងចំពោះសេចក្ដីសម្រេចនេះទេ សំណុំរឿងព្រហ្មទណ្ឌនោះនឹងត្រូវបញ្ចប់។ ប៉ុន្តែការតម្កល់រឿងទុកឥតចាត់ការ ពុំនាំឲ្យមាននូវអានុភាពអាជ្ញាអស់ជំនុំកើតឡើងទេ ហើយតាមរយៈប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទោះបីជាមានការសម្រេចតម្កល់រឿងទុកឥតចាត់ការក៏ដោយ ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួនវិញបាន តែការសើរើកែប្រែនេះ អាចធ្វើក្នុងខណៈដែលបណ្ដឹងអាជ្ញាមិនទាន់ផុតរលត់ប៉ុណ្ណោះ[៧០]។ មានន័យថា នៅពេលដែលមានការសម្រេចតម្កល់រឿងទុកឥតចាត់ការរួច ព្រះរាជអាជ្ញានៅតែអាចធ្វើការសើរើសំណុំរឿងព្រហ្មទណ្ឌនោះមកធ្វើការចោទប្រកាន់ឡើងវិញបាន ប៉ុន្តែការចោទប្រកាន់នេះ អាចធ្វើបានតែក្នុងករណីបណ្ដឹងអាជ្ញាមិនទាន់ផុតរលត់។ បានជាមានការអនុញ្ញាតឲ្យមានការកែប្រែសេចក្ដីសម្រេចបែបនេះ ព្រោះព្រះរាជអាជ្ញាធ្វើសេចក្ដីសម្រេចចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ តាមរយៈការថ្លឹងថ្លែងរបស់ខ្លួន ដូចនេះការសម្រេចសេចក្ដីអាចមានភាពខុសឆ្គងដោយសារការខ្វះចន្លោះត្រង់ប្រការណាមួយ ដែលនាំឲ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវ។ ចំណែកឯមូលហេតុដែលនាំឲ្យមានការសើរើសេចក្ដីសម្រេចនេះ អាចបណ្ដាលមកពីហេតុការណ៍មួយចំនួនដែលនាំឲ្យព្រះរាជអាជ្ញាយល់ឃើញថា ការសម្រេចតម្កល់រឿងទុកឥតចាត់ការនោះមិនត្រឹមត្រូវដូចជា៖ មានអង្គហេតុថ្មីត្រូវបានរកឃើញ ឬមានភស្តុតាងណាមួយបានលេចឡើងដែលអាចនាំឲ្យធ្វើការចោទប្រកាន់បាន ឬនៅពេលដែលមានភាពចន្លោះប្រហោងណាមួយនៃនីតិវិធីដែលនាំឲ្យការសម្រេចរបស់ខ្លួនមិនត្រឹមត្រូវជាអាទិ៍។

ដូច្នេះ ការបើកផ្លូវឲ្យព្រះរាជអាជ្ញា ធ្វើការសើរើកែប្រែសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួននេះ គឺជានីតិវិធីមួយដែលត្រូវបានផ្ដល់ឲ្យព្រះរាជអាជ្ញា ក្នុងការបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះ នៃអំពើល្មើសឲ្យទទួលបានយុត្តិធម៌ផងដែរ។

[៧០] មាត្រា៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ខ. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានីតិវិធីមួយដែលអនុញ្ញាតឲ្យជនរងគ្រោះ អាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅពេលដែលពាក្យប្តឹងត្រូវបានសម្រេចតម្កល់រឿងទុកឥតចាត់ការដោយព្រះរាជអាជ្ញា ឬពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ[៧១]។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវបានកំណត់នូវតួនាទីលើការឃ្លាំមើលការអនុវត្តច្បាប់ ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[៧២] ហើយដោយសារតែតួនាទីនេះ ទើបច្បាប់សម្រេចទទួលយកអគ្គព្រះរាជអាជ្ញាជាអ្នកទទួលបណ្តឹងពីជនរងគ្រោះ និងជាអ្នកសម្រេចសេចក្តីលើបណ្តឹងនោះ។

ការធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល ២ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ[៧៣]។ មានន័យថា ចិរវេលាខាងលើ គឺគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ រហូតដល់ ២ខែក្រោយ ទើបជនរងគ្រោះអស់សិទ្ធិក្នុងការធ្វើបណ្តឹងតវ៉ានេះ។ ប៉ុន្តែគួរបញ្ជាក់ផងដែរថា ក្នុងករណីដូចមានប្បញ្ញត្តិក្នុងមាត្រា៦ បណ្តឹងតវ៉ាអាចត្រូវបានធ្វើឡើងនៅពេលពាក្យប្តឹងរបស់ជនរងគ្រោះត្រូវបានតម្កល់រឿងទុកឥតចាត់ការ ឬស្ថិតនៅដោយគ្មានចម្លើយ ដូចនេះប្រសិនបើពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ នោះនាំឲ្យជនរងគ្រោះមិនបានទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការដូចគ្នា ដូច្នេះរយៈពេលប្តឹងតវ៉ាខាងលើមិនអាចប្រើប្រាស់ក្នុងករណីពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយបានទេ។

រីឯនីតិវិធីនៃការធ្វើបណ្តឹងតវ៉ា ត្រូវធ្វើឡើងដោយបណ្តឹងសាមញ្ញរបស់អ្នកប្តឹងមួយ ទៅអង្គការអយ្យការដែលពាក់ព័ន្ធ។ អង្គការអយ្យការដែលពាក់ព័ន្ធនេះ សំដៅដល់អង្គការអយ្យការអមសាលាដំបូងដែលបានទទួលបណ្តឹងលើកទី១។ នៅពេលបណ្តឹងត្រូវបានដាក់រួច ព្រះរាជអាជ្ញាអមសាលាដំបូងត្រូវបញ្ជូនសំណុំរឿងនេះ មកឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីធ្វើការសម្រេច។ ដោយការសម្រេចសេចក្តីនេះ អាចមាន ២ករណី៖

**-ការបដិសេធនឹងសេចក្តីសម្រេច៖** បើបណ្តឹងនេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ជា ដល់ព្រះរាជអាជ្ញាអមសាលាដំបូងឲ្យធ្វើការចោទប្រកាន់។ ការធ្វើ

[៧១] មាត្រា៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៧២] មាត្រា៣៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៧៣] មាត្រា៤១ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អធិបញ្ញាចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ទើបការចោទប្រកាន់ចាំបាច់ត្រូវតែមាន ហើយព្រះរាជអាជ្ញាត្រូវតែចោទ គាត់គ្មានសិទ្ធិអំណាចសម្រេចដោយខ្លួនឯងដូចពីមុននោះទេ។

**-ការយល់ស្របនឹងសេចក្តីសម្រេចៈ** នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទុកជាបានការ ហើយជូនព័ត៌មានអំពីការសម្រេចនេះទៅអ្នកប្តឹងឲ្យដឹង ហើយអ្នកប្តឹងមិនអនុញ្ញាតឲ្យធ្វើបណ្តឹងតវ៉ាទៀតទេ។ ការជូនដំណឹងនេះ ដើម្បីជាឱកាសក្នុងការប្រើនីតិវិធីផ្សេងៗទៀត ដូចជាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ[៧៤]។

## គ. អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ

អំណាចអធិបញ្ញា តាមន័យទូទៅគឺជាបញ្ជាតាមឋានានុក្រមពីថ្នាក់លើមកថ្នាក់ក្រោមដើម្បីឲ្យធ្វើអ្វីមួយ។ តាមរយៈខ្លឹមសារនៃមាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ សំដៅដល់ការបញ្ជាតាមឋានានុក្រមឲ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ។ ដោយសមាសភាពនៃអង្គការអយ្យការក្នុងការធ្វើអធិបញ្ញាមានឋានានុក្រមដូចជាៈ រដ្ឋន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។

**-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមុខនាទីមួយដែលតំណាង ឬជាសេនាធិការដល់រាជរដ្ឋាភិបាលក្នុងការពង្រឹងវិស័យច្បាប់របស់សង្គមជាតិទាំងមូល។ ច្បាប់បានផ្តល់អំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឲ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលគាត់យល់ឃើញថាជាការគួរ ។

**-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍[៧៥]។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឲ្យចោទប្រកាន់ ឬ

[៧៤] មាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧៥] មាត្រា៣៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ[៧៦]។ ដូចនេះ មានន័យថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិបញ្ញា ឲ្យព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការបានធ្វើឡើង។

**-ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាត្រង់ចំណុចនេះ មិនសំដៅដល់ព្រះរាជអាជ្ញាអមតុលាការកំពូល ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទេ ព្រោះអ្នកទាំងនេះគ្មានអំណាចលើចៅក្រមអយ្យការណាមួយ ក្នុងការប្រើអំណាចអធិបញ្ញាទេ ហេតុនេះ ព្រះរាជអាជ្ញា សំដៅដល់ព្រះរាជអាជ្ញាអមសាលាដំបូងតែប៉ុណ្ណោះ។ ព្រះរាជអាជ្ញា មានអំណាចទៅលើចៅក្រមអយ្យការដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាក៏អាចធ្វើអធិបញ្ញាឲ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានតាមដែលខ្លួនយល់ឃើញថាជាការគួរ។ ដូចនេះមានន័យថា ព្រះរាជអាជ្ញាអមសាលាដំបូង អាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារង ដែលស្ថិតនៅសមត្ថកិច្ចដែនដី ឬនៅអមសាលាដំបូងរបស់ខ្លួន ធ្វើការចោទប្រកាន់នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការបានធ្វើឡើង។

**-ព្រះរាជអាជ្ញារង**

ព្រះរាជអាជ្ញារង គឺជាចៅក្រមអយ្យការនៅអមសាលាដំបូងរាជធានី-ខេត្ត ដែលមានឋានុក្រមក្រោមគេ។ ព្រះរាជអាជ្ញារងស្ថិតនៅក្រោមអំណាចព្រះរាជអាជ្ញា ប៉ុន្តែអាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។ ដូចនេះនៅពេលដែលមានការធ្វើអធិបញ្ញាចំពោះរឿងដែលខ្លួនបានតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញារងត្រូវតែគោរពតាមអធិបញ្ញានោះ។

គួរកត់សម្គាល់ផងដែរថា ការធ្វើអធិបញ្ញា ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ហើយអំណាចអធិបញ្ញា គឺជាការបញ្ជាឲ្យមានការចោទប្រកាន់ មិនមែនជាការបញ្ជាឲ្យមានការតម្កល់រឿងទុកឥតចាត់ការទេ។ ចៅក្រមអយ្យការគ្រប់រូបត្រូវគោរពអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម ប៉ុន្តែនៅពេលសវនាការ ចៅក្រមអយ្យការធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន ហើយក៏គ្មានការចោទប្រកាន់ខាងវិន័យត្រូវបានធ្វើឡើងចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួនពេលសវនាការនោះដែរ[៧៧]។

---

[៧៦] មាត្រា២៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧៧] មាត្រា៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដូច្នេះ ប្រសិនបើមានការតម្កល់រឿងទុកឥតចាត់ការត្រូវបានធ្វើឡើង ជនរងគ្រោះ អាចជ្រើសយកជម្រើសនេះ ដោយធ្វើការប្តឹងទៅនាយឋានានុក្រមនៃអង្គការអយ្យការខាងលើ ដើម្បីឲ្យធ្វើអធិបញ្ញាដែលនាំឲ្យមានការចោទប្រកាន់ឡើងវិញ ប្រសិនបើពួកគាត់យល់ថារឿងនោះគួរចោទប្រកាន់។

**ឃ. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ**

ក្រៅពីជម្រើសនៃការដាក់ពាក្យប្តឹង ឬពាក្យបរិហារទៅមន្ត្រីនគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាផ្ទាល់ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ[៧៨]។ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា[៧៩] ដែលអាចនាំឲ្យមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ។

បន្ទាប់មកចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាក៏អាចសុំដល់ចៅក្រមស៊ើបសួរ កុំឲ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ទោះបីជាមានការសុំមិនឲ្យបើកការស៊ើបសួរដោយព្រះរាជអាជ្ញាក៏ដោយ ក៏ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចចំពោះការសុំមិនឲ្យបើកការស៊ើបសួរនោះដែរ។ ហើយចៅក្រមស៊ើបសួរនៅតែអាចសម្រេចចំណាត់ការលើពាក្យប្តឹងនោះ ដោយឯករាជ្យដែលដោយ៖

**-សម្រេចមិនបើកការស៊ើបសួរ៖** ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមានសំអាងហេតុ ហើយជូនដំណឹងនេះជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

**-សម្រេចបើកការស៊ើបសួរ៖** ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមានសំអាងហេតុ ហើយជូនដំណឹងនេះដល់ព្រះរាជអាជ្ញា។

[៧៨] មាត្រា១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧៩] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដីកាសម្រេចខាងលើរបស់ចៅក្រមស៊ើបសួរ សុទ្ធតែអាចប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរបាន ដោយ ដើមបណ្ដឹងរដ្ឋប្បវេណី[៨០] និងព្រះរាជអាជ្ញា[៨១]។

[៨០] មាត្រា២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៨១] មាត្រា២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# សន្និដ្ឋាន និងអនុសាសន៍

## ១.សន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង បានដើរតួយ៉ាងសំខាន់ក្នុងរឿងព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា ធ្វើការក្នុងនាមបម្រើផលប្រយោជន៍សាធារណៈ ហើយភារកិច្ចដ៏ចំបងរបស់ព្រះរាជអាជ្ញា គឺការធ្វើចំណាត់ការចំពោះបទល្មើស។ ព្រះរាជអាជ្ញាមានជម្រើសក្នុងការចោទប្រកាន់ ដោយអាចសម្រេចធ្វើការចោទប្រកាន់ និងមិនចោទប្រកាន់។

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានផ្តល់វិធីក្នុងការចោទប្រកាន់ចំនួន ៣យ៉ាងគឺការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ បន្ទាប់ពីធ្វើការសិក្សាលម្អិតលើនីតិវិធីនៃការចោទប្រកាន់នីមួយៗ យើងបានរកឃើញ និងអាចកំណត់បាននូវមូលហេតុដែលនាំឲ្យមានការបង្កើតនីតិវិធីនៃការចោទប្រកាន់ផ្សេងៗពីគ្នា គឺដើម្បីធានាបាននូវភាពច្បាស់លាស់ និងភាពឆាប់រហ័ស។

**ភាពច្បាស់លាស់៖** ភាពច្បាស់លាស់ត្រូវបានតម្រូវឲ្យមានគ្រប់វិធីនៃការចោទប្រកាន់ទាំងអស់ ដោយសារការចោទប្រកាន់ធ្វើឡើងដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ការពារប្រយោជន៍សាធារណៈ និងបញ្ឈប់ភាពចលាចលក្នុងសង្គមជាអាទិ៍។ ប៉ុន្តែប្រសិនបើ ការចោទប្រកាន់ធ្វើឡើងដោយមិនមានភាពច្បាស់លាស់ វាអាចនឹងផ្តល់ផលប៉ះពាល់ដល់ភាគីនៃរឿងក្តី ជាពិសេសជនត្រូវចោទ។ ជនត្រូវចោទអាចនឹងត្រូវទទួលផលប៉ះពាល់ ដូចជាខាតបង់ពេលវេលា (ត្រូវបានឃុំខ្លួន) ផលប្រយោជន៍សេដ្ឋកិច្ច កិត្តិយស។ល។ រីឯជនរងគ្រោះ ក៏អាចនឹងទទួលផលប៉ះពាល់ផងដែរ ដូចជាករណីដែលការចោទប្រកាន់ធ្វើឡើងដោយមិនបានស្រាវជ្រាវគ្រប់គ្រាន់ ដែលនាំឲ្យជនរងគ្រោះទទួលរងនូវភាពអយុត្តិធម៌ និងមិនអាចទទួលបាននូវការប៉ះប៉ូវសំណងជម្ងឺចិត្ត ព្រោះតាមរយៈគោលការណ៍វិមតិសង្ស័យ ដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ វានឹងធ្វើឲ្យជនល្មើសអាចរួចផុតពីការទទួលខុសត្រូវរបស់ខ្លួន។ ដូចនេះហើយ ដើម្បីធានាឲ្យបាននូវភាពច្បាស់លាស់ ការពារសិទ្ធិ និងបញ្ចៀសផលប៉ះពាល់ដល់ភាគីនៃរឿងក្តី ការចោទប្រកាន់ធ្វើឡើងតាមរយៈ នីតិវិធីបើកការស៊ើបសួរ ជាជម្រើសដ៏ល្អបំផុត ព្រោះនីតិវិធីនេះ បាននាំឲ្យមានការស្រាវជ្រាវបន្ថែមទៀតតាមរយៈចៅក្រមស៊ើបសួរ។

**ភាពឆាប់រហ័ស៖** នីតិវិធីនីមួយៗ សុទ្ធតែតម្រូវឲ្យមានភាពច្បាស់លាស់ក៏ពិតមែន ប៉ុន្តែមិនអាចធ្វើឡើយអូសបន្លាយពេលវេលា បណ្តាលឲ្យខាតបង់ផលប្រយោជន៍របស់ភាគីនៃរឿងក្តីបានដែរ។ នៅពេលដែលព្រះរាជអាជ្ញាមានភាពច្បាស់លាស់ ក្នុងការសន្និដ្ឋានពីពិរុទ្ធភាពរបស់ជនសង្ស័យហើយ ការបើកការស៊ើបសួរ ហាក់ដូចជាមិនចាំបាច់ព្រោះវានាំឲ្យខាតបង់ពេលវេលាទៅវិញ។ ដូចនេះ

ព្រះរាជអាជ្ញាអាចសម្រេចធ្វើការបញ្ជូនជនសង្ស័យនេះទៅជំនុំជម្រះតែម្តងតាមរយៈ នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ នីតិវិធីទាំងពីរ ជានីតិវិធីដែលអាចជួយពន្លឿននីតិវិធីឲ្យបានឆាប់រហ័ស និងបានផ្តល់ផលប្រយោជន៍ដល់ទាំងជនរងគ្រោះ និងដល់អង្គតុលាការផងដែរ។ ជនរងគ្រោះ អាចទទួលបាននូវភាពយុត្តិធម៌បានឆាប់រហ័ស ការទទួលបាននូវការប៉ះប៉ូវការខូចខាត និងសំណងទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសម្ភារៈបានទាន់ពេលវេលា។ ចំណែកអង្គតុលាការក៏ទទួលបាននូវផលប្រយោជន៍ដូចជា ជួយកាត់បន្ថយសំណុំរឿងនៅចៅក្រមស៊ើបសួរ និងបន្ទុករបស់ចៅក្រមស៊ើបសួរ ពីព្រោះដោយសារបច្ចុប្បន្ន ទោះបីជាច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ បានបែងចែកជាតុលាការជំនាញពិតមែន ប៉ុន្តែជាក់ស្តែងនៅតាមសាលាដំបូងរាជធានី-ខេត្ត ពុំទាន់បង្កើតជាតុលាការជំនាញនោះទេ ដូចនេះបន្ទុកនៃសំណុំរឿងស៊ើបសួរ សំណុំរឿងជំនុំជម្រះ និងប្រភេទសំណុំរឿងផ្សេងទៀតក្រៅពីរឿងព្រហ្មទណ្ឌ សុទ្ធតែជាបន្ទុករបស់ចៅក្រមនៃសាលាដំបូងរាជធានី-ខេត្ត។

ដូច្នេះ យើងអាចសន្និដ្ឋានចំពោះនីតិវិធីនៃការចោទប្រកាន់បានថា ទោះបីជាការចោទប្រកាន់អាចត្រូវបានធ្វើឡើងតាមនីតិវិធីផ្សេងគ្នាៗក៏ដោយ ប៉ុន្តែវាមានចំណុចរួមមួយគឺ ដើម្បីឲ្យភាគីនៃរឿងក្តីទទួលបានផលប្រយោជន៍ និងភាពយុត្តិធម៌ពិតប្រាកដ។

ចំណែកឯក្រៅពីការចោទប្រកាន់ចំពោះបទល្មើស ព្រះរាជអាជ្ញាក៏អាចសម្រេចធ្វើការមិនចោទប្រកាន់បានដែរ ទោះបីជាអំពើដែលបានប្រព្រឹត្តនោះជាបទល្មើសក៏ដោយ ព្រោះការចោទប្រកាន់ចំពោះអំពើខ្លះ អាចធ្វើឲ្យមានផលប៉ះពាល់ និងខាតបង់ទៅវិញ ដូចនេះព្រះរាជអាជ្ញាអាចធ្វើការពិចារណាទៅលើមូលហេតុដូចបានបកស្រាយក្នុងផ្នែកទី២។ មូលហេតុដែលបណ្តាលឲ្យព្រះរាជអាជ្ញាអាចសម្រេចធ្វើការមិនចោទប្រកាន់ គឺបណ្តាលមកពីហេតុផលមួយចំនួនទាក់ទងនឹងផលប្រយោជន៍របស់តុលាការ ភាគី និងរដ្ឋ។ ចំពោះផលប្រយោជន៍សម្រាប់តុលាការ គឺអាចកាត់បន្ថយសំណុំរឿងដែលកកស្ទះ ផ្តល់ប្រសិទ្ធភាពក្នុងការស៊ើបសួរ និងជំនុំជម្រះ ព្រោះនៅពេលសំណុំរឿងត្រូវបានកាត់បន្ថយ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញកិច្ចការរបស់ខ្លួន។ ចំណែកផលប្រយោជន៍សម្រាប់ភាគី គឺភាគីដែលជាជនល្មើសអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីកែប្រែខ្លួន និងរួមរស់ជាមួយសង្គមវិញ ជាពិសេសអនីតិជន និងជនដែលកំពុងជាប់កាតព្វកិច្ច ដូចជាការចិញ្ចឹមបីបាច់គ្រួសារជាអាទិ៍។ ឯផលប្រយោជន៍ចំពោះរដ្ឋ គឺកាត់បន្ថយការចំណាយទាំងពេលវេលា និងថវិកា ដោយអាចកាត់បន្ថយការចំណាយលើទណ្ឌិត និងកាត់បន្ថយចំនួនទណ្ឌិត។ ប៉ុន្តែស្របពេលនឹងការផ្តល់ផលប្រយោជន៍ នីតិវិធីនេះ ក៏បានផ្តល់គុណវិបត្តិផងដែរ។ ដោយគុណវិបត្តិនេះ ត្រូវបានផ្តល់តាមរយៈការបង្កើតវប្បធម៌និទណ្ឌភាព។ ព្រះរាជ

អាជ្ញាមានសិទ្ធិអំណាច ក្នុងការមិនធ្វើការចោទប្រកាន់ ដូចនេះជនល្មើសអាចនឹងត្រូវបានរួចខ្លួនពីការប្រព្រឹត្តអំពើល្មើសរបស់ខ្លួន មិនតែប៉ុណ្ណោះវាអាចបង្កើតឲ្យមានអំពើពុករលួយថែមទៀតផង។

ដូច្នេះ យើងអាចធ្វើការសន្និដ្ឋានចំពោះនីតិវិធីនៃការមិនចោទប្រកាន់បានថា គឺជានីតិវិធីមួយដែលផ្តល់ទាំងគុណសម្បត្តិ និងគុណវិបត្តិ ប្រសិនបើនីតិវិធីនេះត្រូវបានធ្វើឡើយដោយមិនត្រឹមត្រូវ វាពិតជាធ្វើឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ភាគីជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ។

## ២.អនុសាសន៍

ឆ្លងតាមការសិក្សាលើប្រធានបទខាងលើ ព្រះរាជអាជ្ញា ជាតួអង្គដ៏សំខាន់ក្នុងនីតិវិធីនេះ។ នីតិវិធីនេះអាចប្រព្រឹត្តបានល្អ ត្រឹមត្រូវ ដើម្បីជានាបាននូវនីតិរដ្ឋ លុះត្រាតែព្រះរាជអាជ្ញាបំពេញតួនាទីរបស់ខ្លួនដោយឈរលើចំណុចសំខាន់ៗដូចជា៖

**-ទាក់ទងនឹងការចោទប្រកាន់៖** ព្រះរាជអាជ្ញា ត្រូវធ្វើការវិនិច្ឆ័យឲ្យបានត្រឹមត្រូវចំពោះ ជម្រើសណាមួយដែលត្រូវធ្វើការចោទប្រកាន់ ដើម្បីឲ្យភាគីទាំងសងខាង ទោះជនរងគ្រោះក្តី ឬជនល្មើសក្តីបានទទួលយុត្តិធម៌ ការវិនិច្ឆ័យដ៏ត្រឹមត្រូវ ច្បាស់លាស់ និងបង្ការផលប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយនៅពេលដែលខ្លួនបានធ្វើការវិនិច្ឆ័យខុស ដែលនាំឲ្យខាតបង់ផលប្រយោជន៍ ពេលវេលា និងកិត្តិយស។ល។

**-ទាក់ទងនឹងការមិនចោទប្រកាន់៖** ការមិនចោទប្រកាន់ គឺជានីតិវិធីដែលបើកសិទ្ធិអំណាចដ៏ទូលាយដល់ព្រះរាជអាជ្ញា ដែលផ្តល់ឱកាសដល់ជនល្មើសបានរួចខ្លួន និងមានសេរីភាពផងដែរ ដូច្នេះហើយព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវការអនុវត្តច្បាប់ ក្រមសីលធម៌ វិជ្ជាជីវៈរបស់ខ្លួនឲ្យបានត្រឹមត្រូវ មុននឹងសម្រេចធ្វើការមិនចោទប្រកាន់ ដើម្បីឲ្យជនរងគ្រោះ និងសង្គមទទួលបាននូវយុត្តិធម៌យ៉ាងពិតប្រាកដ។ មិនតែប៉ុណ្ណោះ ការសម្រេចមិនចោទប្រកាន់ ត្រូវធ្វើឡើយដោយឈរលើផលប្រយោជន៍ពិតប្រាកដរបស់ភាគី និងសង្គម ជៀសវាងការគិតដល់ផលប្រយោជន៍របស់ខ្លួនជាការដោះដូរនឹងលាភសក្ការៈ។

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៤. ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ប្រកាសឲ្យប្រើតាមក្រឹត្យលេខ ២១ក្រ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣

៥. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

៦. ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

## II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. គោលការណ៍ណែនាំស្តីពី "តួនាទីរបស់ព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

## III. ក្រមសីលធម៌

១. ក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

## IV. សៀវភៅ


១. **រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត**, ឯកសារមេរៀន "នីតិវិធីព្រហ្មទណ្ឌ" បោះពុម្ព ឆ្នាំ២០១៥

២. **អ៊ាន សំអាត**, "មេរៀននីតិវិធីព្រហ្មទណ្ឌ" បោះពុម្ពឆ្នាំ ២០១៥

៣. **ជួន សុរាសី**, "នីតិវិធីសង្ខេប រដ្ឋប្បវេណី និងព្រហ្មទណ្ឌ" ភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩

៤. **កែ វិសាល, សេហា សុខឃី និង ហេង ពូង**, មណ្ឌលច្បាប់ "នីតិវិធីនៃការអនុវត្តជាក់ស្តែងក្នុងរឿងក្តីព្រហ្មទណ្ឌ" បោះពុម្ព ឆ្នាំ២០១៤

៥. **កុយ នាម និង ឡុង បញ្ញាវុឌ្ឍ**, "អយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប" បោះពុម្ព ឆ្នាំ២០០៦

៦. រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឯកសារមេរៀន "មេរៀននីតិវិធីព្រហ្មទណ្ឌ" បោះពុម្ព ឆ្នាំ ២០០៧

៧. **ហ៊ី សោភា**, ឯកសារមេរៀន "នីតិព្រហ្មទណ្ឌទូទៅ"

៨. **វុន ពណ្ណារិទ្ធ**, "នីតិព្រហ្មទណ្ឌទូទៅ", ភ្នំពេញ, បោះពុម្ព ឆ្នាំ២០១២

V. **គេហទំព័រ**

១. https://llundi.wordpress.com/2012/10/03/method-of-researching-document/

២. https://khmerexpat.wordpress.com/tag/នីតិវិធីព្រហ្មទណ្ឌ/

៣. http://itcambo.com/wp/?p=21852

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ **កកកកកក** អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១២១០H ភូមិ៦១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**ឯកឧត្តមព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

**សូមទានជ្រាប។**

**កម្មវត្ថុ៖** សុំប្តឹងលើឈ្មោះ **ខខខខខខ** ភេទស្រី អាយុ ៤៥ឆ្នាំ និង ប្តីឈ្មោះ **គគគគគគ** សញ្ជាតិ Finnish ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៨D ក្រុមទី៧ ភូមិ៦២ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។ ពីបទ " **ឆបោក** "

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស សូមជម្រាបជូន **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាជ្រាបថា: កាលពីថ្ងៃទី០៥ ខែកុម្ភ: ឆ្នាំ២០១៥ ឈ្មោះ**ខខខខខខ** ភេទស្រី អាយុ ៤៥ឆ្នាំ និង ប្តីឈ្មោះ **គគគគគគ** សញ្ជាតិ Finnish បានលក់ដីទំហំ ២០ម គុណ ៤០ម =៨០០ម$^2$ ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុលេខ៖ **១៨០១០៤០៥-២៧០២** ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១០ នៅក្រុងព្រះសីហនុ ដោយខ្ញុំបាទកក់ប្រាក់ថ្លៃដីចំនួន **៣៣.០០០ $ (បីម៉ឺនបីពាន់ដុល្លាអាមេរិក)** ទៅឱ្យឈ្មោះ **ខខខខខខ** និង ប្តីឈ្មោះ **គគគគគគ** ដោយឈ្មោះ**ខខខខខខ** និង ប្តីឈ្មោះ **គគគគគគ** សន្យាថានឹងកាត់ឈ្មោះមកអោយខ្ញុំបាទនៅរយៈពេលមួយខែក្រោយ ហើយឈ្មោះ **ខខខខខខ** និង ប្តីឈ្មោះ **គគគគគគ** សន្យាទៀតថា ប្រសិនបើមានការកែប្រែតម្លៃ ឬ មិនព្រមលក់វិញនោះ ឈ្មោះ **ខខខខខខ** និង ប្តីឈ្មោះ **គគគគគគ** សូមធានាសងប្រាក់វិញ គុណនឹង០២ដង នៃប្រាក់ដែលខ្ញុំបាទបានកក់ ។ ក្រោយមកទើបខ្ញុំបាទបានដឹងថាដីខាងលើនេះ ត្រូវបានឈ្មោះ **ខខខខខខ** និង ប្តីឈ្មោះ **គគគគគគ** យកទៅដាក់បញ្ចាំនៅធនាគារ **អេស៊ីលីដា** តាំងពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ មកម្លេះ។ ក្រោយមកខ្ញុំបាទក៏បានទៅទារប្រាក់កក់នោះមកវិញ តែឈ្មោះ **ខខខខខខ** និង ប្តីឈ្មោះ **គគគគគគ** បានគេចវេសពីខ្ញុំបាទរហូតមកដល់សព្វថ្ងៃនេះ ។

អាស្រ័យដូចបានជម្រាបជូនកម្មវត្ថុខាងលើសូម **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាផ្តន្ទាទោសជនល្មើសទៅតាមផ្លូវច្បាប់ និង សុំទាមទារប្រាក់កក់គុណនឹង០២មកវិញ ។

សូម **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រឡាបញ្ជី: [redacted]
បន្ទប់:.......ជាន់ទី.....

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ............
ចុះថ្ងៃទី ........ ខែ .......... ឆ្នាំ ២០១៦

# ដីកាកោះ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

អញ្ជើញឈ្មោះ **កកកកកកក** ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅ ផ្ទះគ្មានលេខ ផ្លូវលូ៥ ភូមិទ្រា៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ឲ្យចូលទៅកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី......ខែ..........ឆ្នាំ២០១៦ វេលាម៉ោង ០៩និង៣០នាទី ដើម្បី **សាកសួរ** ពីដំណើររឿង **ហិង្សាដោយចេតនា** តាមបណ្ដឹងរបស់ឈ្មោះ **ខខខខខខខ** ភេទប្រុស អាយុ ២៨ឆ្នាំ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅភ្នំពេញ, ថ្ងៃទី........ខែ...........ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

យើង ..............................................................................................................

បានប្រគល់លិខិតអញ្ជើញនេះអោយឈ្មោះ ..................................................................

ទីលំនៅសព្វថ្ងៃ ..................................................... ផ្លូវ ...................... ភូមិ .........................

ឃុំ-សង្កាត់ .............................. ស្រុក-ខណ្ឌ .............................. ខេត្ត-រាជធានី ......................

នៅថ្ងៃទី .......... ខែ .............. ឆ្នាំ ................. ផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះមួយច្បាប់ អោយសាមីខ្លួន ហើយប្រាប់ថាអោយសាមីខ្លួន ប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់តុលាការ ឬអយ្យការ។

**អ្នកទទួលលិខិត** **អ្នកប្រគល់**

ហត្ថលេខា ឬ ផ្ដិតម្រាមដៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

*លេខ                    អ.យ.ណ*

# ដីកាបញ្ជាឲ្យចូលខ្លួន[១]

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ លិខិតលេខ៧៧ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ៣៧[២], ៥៤[៣] និងមាត្រា ១១៤[៤] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

## បញ្ជា

នាម-គោត្តនាម [redacted] ភេទប្រុស អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

ឲ្យចូលបង្ហាញខ្លួននៅ ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ឲ្យបានមុនថ្ងៃទី ខែមិថុនា ឆ្នាំ២០១៥ នៅរៀងរាល់ម៉ោងធ្វើការ ដើម្បីសាកសួរលើបណ្តឹងព្រហ្មទណ្ឌពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** តាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែឧសភា ឆ្នាំ២០១៥

**ជ.ព្រះរាជអាជ្ញា**

---

[១] ដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលខ្លួនបាន

[២] អំណាចរបស់ព្រះរាជអាជ្ញា

[៣]ករណីស៊ើបអង្កេតជាក់ស្តែង

[៤] ករណីស៊ើបអង្កេតបឋម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ:..................................អយណ

# <u>កំណត់ហេតុទទួលវត្ថុចាប់យក</u>

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែឧសភា ថ្ងៃទីសាមសិប វេលាម៉ោងដប់បួន និងសូន្យនាទី ។

យើង [redacted] ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញជា អ្នកទទួល ។

លោក [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌ ខណ្ឌចំការមន ជាអ្នកប្រគល់។

បានពិនិត្យភិនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ............ ចុះថ្ងៃទី...... ខែ...............ឆ្នាំ២០១៦ ឃើញមានដូចខាងក្រោម :

-ប្រដាប់ផ្ទុកទិន្នន័យរូបភាព (Flash) ចំនួន ០១ ។

យើងធ្វើកំណត់ហេតុនេះទុកជាភស្តុតាដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ............... ចុះថ្ងៃទី........ខែ................ឆ្នាំ២០១៦ តាមផ្លូវច្បាប់តទៅ ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោងដប់បួន និងដប់ប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

ជនសង្ស័យ អ្នកប្រគល់ អ្នកទទួល

**បានឃើញ**

រាជធានីភ្នំពេញ ,ថ្ងៃទី........ខែ...........ឆ្នាំ ២០១៦

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ...........
ចុះថ្ងៃទី....... ខែ............ ឆ្នាំ២០១៦

# កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែមិថុនា ថ្ងៃទីពីរ វេលាម៉ោងដប់បួន និងសូន្យនាទី។

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ដោយមានលោក [redacted] ជាក្រឡាបញ្ជីអមផងបានសួរកត់យកចម្លើយឈ្មោះ **កកកកកក** ជាដើមបណ្តឹង។

**សួរ-ឆ្លើយ** : នាងខ្ញុំឈ្មោះ **កកកកកក** អាយុ ៤១ ឆ្នាំ មុខរបរ មេផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៤៨១ ផ្លូវលេខវ៉ាដា ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ខខខខខ** (ស) ម្តាយឈ្មោះ **គគគគគគ** (ស) ប្តីឈ្មោះ **឵យយយយ** (រ) មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។

**សួរ-ឆ្លើយ** : កាលពីថ្ងៃខែមិនចាំ ក្នុងឆ្នាំ២០១៥ វេលាម៉ោងប្រហែល ១១ ថ្ងៃត្រង់ ឈ្មោះ **យយយយ** ជាប្តី ឈ្មោះ **ងងងង** និងឈ្មោះ **ចចចចច** ជាឪពុកម្តាយក្មេក ឈ្មោះ **ឆឆឆឆ** និងឈ្មោះ **ជជជជ** ត្រូវជាបងថ្លៃ បានព្រួតគ្នាប្រើអំពើហិង្សាវាយដំលើនាងខ្ញុំ បណ្តាលឲ្យមានរបួសយ៉ាងធ្ងន់ធ្ងរ និងគម្រាមកំហែងមកលើរូបនាងខ្ញុំជាញឹកញាប់ ថែមទាំងបក្សពួកខាងលើបណ្តេញនាងខ្ញុំចេញពីផ្ទះ ដែលកំពុងរស់នៅសព្វថ្ងៃ។ ឈ្មោះ **ឆឆឆឆ** និងឈ្មោះ **ជជជជ** បានលួងលោមនាងខ្ញុំថា ទៅធ្វើការដកជំឡូងនៅពេជនិល ដោយបានប្រាក់មួយថ្ងៃ ៣០,០០០ រៀល។ នៅពេលទៅដល់ពេជនិល ពួកគាត់បានដាក់ច្រវ៉ាក់ជើងនាងខ្ញុំ ដោយចោទថានាងខ្ញុំឆ្កួត ហើយយកគ្រូមកស្រោចទឹក និងធ្វើទារុណកម្មរាល់ថ្ងៃ ទោះនាងខ្ញុំអង្វរយ៉ាងណា ក៏គេមិនព្រមដោះច្រវ៉ាក់ដែរ។ ក្រោយមកបងប្រុសនិងបងស្រីរបស់នាងខ្ញុំ មកនាងខ្ញុំត្រលប់មកផ្ទះវិញ។

**សួរ-ឆ្លើយ** : សព្វថ្ងៃបក្សពួកខាងលើ បានបណ្តេញនាងខ្ញុំចេញពីផ្ទះ ដោយផ្ទះខាងលើជាទ្រព្យសម្បត្តិរបស់នាងខ្ញុំដែរ។

**សួរ-ឆ្លើយ** : ភស្តុតាងមាន រូបថតចំនួន ១០សន្លឹក ដែលបង្ហាញពីស្លាកស្នាមរបួស និងការបង្ខាំងទុក។

**សំណូមពរ** : សុំឲ្យតុលាការផ្តន្ទាទោសឈ្មោះ **យយយយ**, ឈ្មោះ **ងងងង**, ឈ្មោះ **ចចចចច**, ឈ្មោះ **ឆឆឆឆ**, និងឈ្មោះ **ជជជជ** តាមច្បាប់ និងសុំទាមទារសំណងជំងឺចិត្ត ១០,០០០ ដុល្លារអាមេរិក។

ឈប់សួរសាមីខ្លួន បានអានឆ្លើយថាត្រឹមត្រូវ ហើយសុខចិត្ត ផ្តិតមេដៃជាមួយយើង។

**អ្នកឆ្លើយ** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ...........
ចុះថ្ងៃទី ....... ខែ .............. ឆ្នាំ ២០១៦
លេខ ៖ .............................អ.យ.ណ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**យើង** [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ............. ចុះថ្ងៃទី ...... ខែមិថុនា ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** របាយការណ៍សំយោគលេខ ............ រ.ប.ក ចុះថ្ងៃទី...... ខែមិថុនា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

**<u>ក្រោយពីបានពិនិត្យឯកសារខាងលើ</u>**

**យល់ឃើញថាមានតម្រុយសន្មត**

១. ឈ្មោះ **កកកកកក** ហៅ **ខ្វង** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិរាំងដេក ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ទទទទទទ** (រ) ម្តាយឈ្មោះ **ននននន** (រ) ប្រពន្ធឈ្មោះ **សសសស** (រ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។

២. ឈ្មោះ **ខខខខ** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែកំណើត ភូមិគរ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ងងងងងង** (រ) ម្តាយឈ្មោះ **ឆឆឆឆឆឆ** (ស) ប្រពន្ធឈ្មោះ **បបបបប** (រ) មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។

**បានប្រព្រឹត្តអំពើដូចតទៅ**

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៩និង០០នាទី កម្លាំងចម្រុះរបស់គណៈបញ្ជាការឯកភាពខណ្ឌដង្កោ បានចុះត្រួតពិនិត្យអាវុធជាតិផ្ទុះទៅលើយានជំនិះគ្រប់ប្រភេទ លើបណ្តោយផ្លូវ២១៧ ត្រង់ចំណុចមុខវត្តស័ង្ហរមាស ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ លុះដល់ម៉ោងប្រហែល ១៩និង៥០នាទី មានជនសង្ស័យចំនួន ០២នាក់ ឈ្មោះ **កកកកកក** ហៅ **ខ្វង** ភេទប្រុស អាយុ ២៧ឆ្នាំ និងឈ្មោះ **ខខខខ** ភេទប្រុស អាយុ ២៥ឆ្នាំ ជិះម៉ូតូ០១គ្រឿង ម៉ាកធូដេ ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1AW-3628 ទិសដៅពីជើង ទៅត្បូង ហើយសមត្ថកិច្ចក៏បានឆែកឆេរឃើញមាន ក្រាមពណ៌សថ្លាចំនួន ០៣កញ្ចប់ចង់តូច ប្រភេទមេតំហ្វេតាមីនមានទម្ងន់ ០,៣៨ក្រាម (សូន្យក្រាមសាមសិបប្រាំបី) នៅក្នុងកាបូបលុយរបស់ជនសង្ស័យឈ្មោះ **កកកកកក** ហៅ **ខ្វង** រួចសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ និងវត្ថុតាងមកសាកសួរនៅអធិការដ្ឋានខណ្ឌដង្កោ។ ក្រោយពីការសាកសួរ ជនសង្ស័យបានសារភាពថា ជនសង្ស័យបានចូលលុយគ្នា ទិញថ្នាំញៀន ពីបុរសម្នាក់មិនស្គាល់ឈ្មោះ នៅម្តុំផ្លូវ៦០ម៉ែត្រ ភូមិព្រៃកតាគង់ សង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចំនួន ០៣កញ្ចប់តូច ក្នុងតម្លៃ ៣០ ដុល្លារអាមេរិក។

អំពើខាងលើជាបទល្មើស **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខវត្តសំបូរមាស ផ្លូវ២១៧ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ តាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**បានឃើញ** មាត្រា ៩៤ និង មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>សម្រេច</u>**

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង**

☑ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ៖

១. ឈ្មោះ **កកកកកក** ហៅ **ខ្វង** ភេទប្រុស អាយុ ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ឈ្មោះ **ខខខខ** ភេទប្រុស អាយុ ២៥ឆ្នាំ (ឃាត់ខ្លួន)

ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខវត្តសំបូរមាស ផ្លូវ២១៧ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ តាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើជនខាងលើ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
*សំណុំរឿងព្រហ្មទណ្ឌលេខ ............*
*ចុះថ្ងៃទី........ ខែមិថុនា  ឆ្នាំ២០១៦*

# ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន

*យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។*

*☐ បានឃើញសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ        អ.យ.ណ ចុះថ្ងៃទី....... ខែមិថុនា ឆ្នាំ២០១៦ បើកការស៊ើបសួរពីបទ* ***រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។***

*☐ បានឃើញមាត្រា ២០៣ , មាត្រា ២០៥ និងមាត្រា ២០៧ នៃក្រមស្ដីពីនីតិវិធីព្រហ្មទណ្ឌ*

**ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី** :

*☐ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី*

*☐ រក្សាភស្ដុតាង ឬតម្រុយជាសម្ភារ:*

*☐ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី*

*☐ ធានារក្សាសណ្ដាប់ធ្នាប់សាធារណ:  កុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស*

**យល់ឃើញថា:**

*ការឃុំខ្លួនបណ្ដោះអាសន្នជាមធ្យោបាយសំរាប់បញ្ចប់ភាពចលាចលធ្ងន់ធ្ងរ និងយូរអង្វែងចំពោះសណ្ដាប់ធ្នាប់សាធារណ: ដោយមូលហេតុថា :*

*☐ ភាពធ្ងន់ធ្ងរនៃបទល្មើស*

*☐ កាល:ទេស:នៃការប្រព្រឹត្តបទល្មើស*

*☐ ទំហំនៃព្យាសនកម្មដែលបទល្មើសបានបង្កឡើង*

**ម្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើ** :

*១. ឈ្មោះ* ***កកកកកកកក*** *ហៅ* **ឌួង** *ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិរាំងដេក ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ* ***ទទទទទទទទ*** *(រ) ម្ដាយឈ្មោះ* ***ននននននន*** *(រ) ប្រពន្ធឈ្មោះ* ***សសសសសស*** *(រ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។*

*២. ឈ្មោះ* ***ខខខខខខខ*** *ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែកំណើត ភូមិគរ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ* ***ងងងងងង*** *(រ) ម្ដាយឈ្មោះ* ***ឆឆឆឆឆឆ*** *(ស) ប្រពន្ធឈ្មោះ* ***បបបបប*** *(រ) មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។*

*ធ្វើនៅរាជធានីភ្នំពេញ  , ថ្ងៃទី          ខែមិថុនា ឆ្នាំ២០១៦*

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ អ.យ.ណ

## ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ............ ចុះថ្ងៃទី....... ខែមេសា ឆ្នាំ២០១៦ ។

បានឃើញ មាត្រា ៤៦, ៤៩, ២៩១,២៩៥, ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រម នស /រកម /០៨០៧ /០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា**

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ២៣ និង ១៩ នាទី គណៈកម្មការចម្រុះបានចុះត្រួតពិនិត្យជាតិស្រវឹងត្រង់ចំណុច គោលដៅមុខសាលាខណ្ឌពោធិ៍សែនជ័យ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ បានឃាត់ម៉ូតូមួយគ្រឿងម៉ាក YANATA XR125 ពណ៌ក្រហម-ស ពាក់ស្លាកលេខ ភ្នំពេញ [redacted] បើកបរដោយឈ្មោះ **កកកកកក** ភេទប្រុស អាយុ ២២ ឆ្នាំ ដោយបានធ្វើតេស្តជាតិអាល់កុលឃើញថា អ្នកបើកបរយានយន្តស្ថិតក្នុងភាពស្រវឹងមានអត្រាជាតិអាល់កុល 0,86 mg/L (សូន្យក្បៀសប៉ែតសិបប្រាំមួយ) មីលីក្រាមក្នុងមួយលីត្រខ្យល់ ។

**បានឃើញ** : របាយការណ៍លេខ ................ សណ ចុះថ្ងៃទី........ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក បានសន្និដ្ឋានថា ផ្អែកតាមច្បាប់ចរាចរណ៍ផ្លូវគោក និងការធ្វើតេស្តជាតិអាល់កុលឃើញថា អ្នកបើកបរយានយន្តស្ថិតក្នុងភាពស្រវឹងមានអត្រាជាតិអាល់កុល 0,86 mg/L ល្មើសច្បាប់ចរាចរណ៍ផ្លូវគោក (ជំពូកទី១០ ទោសបញ្ញត្តិ មាត្រា ៧៧ ) ។

**បានឃើញ** : ចម្លើយរបស់ឈ្មោះ **កកកកកក** ភេទប្រុស អាយុ ២២ ឆ្នាំ បានឆ្លើយនៅនគរបាលយុត្តិធម៌ថា ខ្លួនបានផឹកស៊ីជួបជុំមិត្តភក្តិអស់ស្រាបៀរកម្ពុជាចំនួន ០៦ កំប៉ុង ហើយបានធ្វើដំណើរត្រឡប់មកផ្ទះវិញ តាមផ្លូវសហព័ន្ធរុស្ស៊ី ពីលិចទៅកើត ពេលទៅដល់កន្លែងពិនិត្យជាតិអាល់កុលវាស់ទៅឃើញ 0,86 ml/L ។ បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនខ្លួនមកការិយាល័យ ចរាចរណ៍ផ្លូវគោកតែម្តង ។

**បានឃើញ** : ឯកសារមួយចំនួនទៀតពាក់ព័ន្ធក្នុងសំណុំរឿង ។

**យល់ឃើញថា**

-តាមរបាយការណ៍របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក និងលទ្ធផលធ្វើតេស្តជាតិអាល់កុល អាចបញ្ជាក់បានថា ឈ្មោះ **កកកកកក** ភេទប្រុស អាយុ ២២ ឆ្នាំ ពិតជាបានបើកបរយានយន្តស្ថិតក្នុងភាពស្រវឹងប្រាកដមែន ។

-អំពើរបស់ជនត្រូវចោទជាបទល្មើស **បើកបរយានយន្តនៅពេលដែលខ្លួនស្ថិតក្នុងភាពស្រវឹង** តាមមាត្រា ៧៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ជនត្រូវចោទឈ្មោះ **កកកកកក** អាយុ ២២ ឆ្នាំ ជានីតិជន ដែលអាចទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនបានប្រព្រឹត្ត។

-ឈ្មោះ **កកកកកក** ត្រូវបានសមត្ថកិច្ចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញជាបណ្តោះអាសន្ន ដោយបានដាក់ប្រាក់តម្កល់ចំនួន ៨០0,000 (ប៉ែតសិបម៉ឺន) រៀល ។

-មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ចោទប្រកាន់ឈ្មោះ **កកកកកក** ភេទប្រុស អាយុ ២២ ឆ្នាំ ពីបទ **បើកបរយានយន្តនៅពេលដែលខ្លួនស្ថិតក្នុងភាពស្រវឹង** ប្រព្រឹត្តនៅចំណុច មុខសាលាខណ្ឌពោធិ៍សែនជ័យ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ តាមមាត្រា ៧៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**ហេតុដូច្នេះសម្រេច**

១- ចោទប្រកាន់ឈ្មោះ **កកកកកក** ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ18A ផ្លូវលំ ក្រុម៤ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ **អអអអអអអ** (រ) ម្តាយឈ្មោះ **ញញញញ** (រ) ប្រពន្ធឈ្មោះ **ណណណណ** (រ) ជានីតិជន ទោសពីមុន គ្មាន។

ត្រូវជាប់ចោទពីបទ "**បើកបរយានយន្តនៅពេលដែលខ្លួនស្ថិតក្នុងភាពស្រវឹង**" ប្រព្រឹត្តនៅចំណុចមុខសាលាខណ្ឌពោធិ៍សែនជ័យ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ តាមមាត្រា ៧៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២- បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ សំណុំរឿងព្រហ្មទណ្ឌលេខ................ចុះថ្ងៃទី......... ខែមេសា ឆ្នាំ២០១៦ និងវត្ថុតាង ព្រមទាំងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងសំណុំរឿងនេះ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែឧសភា ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង**...................................
សំណុំរឿងរដ្ឋប្បវេណីលេខ:.........
ថ្ងៃទី.........ខែ............ឆ្នាំ២០១.......
លេខ:................................/អ.យ

# ដីកាកោះបញ្ជូនទៅជំនុំជំរះផ្ទាល់

**យើង .........................................អយ្យការអមសាលាដំបូង...........................។**

**បញ្ជាឲ្យចូលទៅបង្ហាញខ្លួននៅសវនាការ:**

១/នាម-គោត្តនាម.................................ហៅ.............................ភេទ□ប្រុស□ស្រី អាយុ......ឆ្នាំ
ជាតិ..........................................របររកស៊ី.......................................................................ទី
កន្លែងកំណើត....................................ឃុំ-សង្កាត់............................ស្រុក-ខណ្ឌ......................
ខេត្ត-ក្រុង..............................................។
ទីលំនៅបច្ចុប្បន្ន....................................ឃុំ-សង្កាត់............................ស្រុក-ខណ្ឌ..................
ខេត្ត-ក្រុង..............................................។
ទោសពីមុន...........ឪពុកឈ្មោះ.........................″□រ-□ស″ ម្តាយឈ្មោះ........................″□រ-□ស″
ប្តី ឬ ប្រពន្ធឈ្មោះ...................... ″□រ-□ស″ មានកូន..........នាក់ ឬ □នៅលីវ□អនីតិជន □នីតិជន។

២/នាម-គោត្តនាម..................................ហៅ................................ភេទ□ប្រុស□ស្រី អាយុ......ឆ្នាំ
ជាតិ................................របររកស៊ី..................................................................................
ទីកន្លែងកំណើត....................................ឃុំ-សង្កាត់............................ស្រុក-ខណ្ឌ..................
ខេត្ត-ក្រុង..............................................។
ទីលំនៅបច្ចុប្បន្ន....................................ឃុំ-សង្កាត់............................ស្រុក-ខណ្ឌ..................
ខេត្ត-ក្រុង..............................................។
ទោសពីមុន...........ឪពុកឈ្មោះ.........................″□រ-□ស″ ម្តាយឈ្មោះ........................″□រ-□ស″
ប្តី ឬ ប្រពន្ធឈ្មោះ...................... ″□រ-□ស″ មានកូន..........នាក់ ឬ □នៅលីវ□អនីតិជន □នីតិជន។

អ្នកត្រូវចោទប្រកាន់ពីអង្គហេតុ:

........................................................................................................................................
........................................................................................................................................
........................................................................................................................................

............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................
............................................................................................................................................

ជាបទល្មើស:..........................................................................................

ប្រព្រឹត្តនៅ.....................................................ឃុំ-សង្កាត់..............................................

ស្រុក-ខណ្ឌ.....................................................ខេត្ត-ក្រុង.............................................. ....

កាលពីថ្ងៃទី...........ខែ..................ឆ្នាំ២០១......តាមបញ្ញត្តិមាត្រា..............................................

នៃ............................................................................................................................។

សវនាការនេះ និងប្រព្រឹត្តទៅនៅថ្ងៃទី.......ខែ...........ឆ្នាំ២០១...វេលាម៉ោង.........

នៅ..........................................................................................................................។

សាមីខ្លួនអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន។

សាមីខ្លួនត្រូវបង្ហាញខ្លួនឲ្យទានពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងជីភាពសាមីខ្លួន ឬ ដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

..................................... ,ថ្ងៃទី.........ខែ..............ឆ្នាំ២០១....

**ព្រះរាជអាជ្ញា/រង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

*សំណុំរឿងព្រហ្មទណ្ឌលេខ .............*
*ចុះថ្ងៃទី........ ខែឧសភា ឆ្នាំ២០១៣*
*លេខ :                  អយពរ*

# <u>ក័ណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>[១]

*ឆ្នាំពីពាន់ដប់បី ខែឧសភា ថ្ងៃទី០៥ វេលាម៉ោងដប់ប្រាំមួយ ។*

**យើង [redacted] តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

*-បានឃើញរបាយការណ៍សំយោគលេខ...........របក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៣ របស់នគរបាលខណ្ឌពោធិសែនជ័យ ។*

***បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវពត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម:***

*១-ឈ្មោះ* **ភភភភភភ** *ភេទប្រុស អាយុ ២៨ ឆ្នាំ មុខរបរ កម្មកររោងចក្រ កើតនៅភូមិត្រពាំងធ្នង់ ឃុំសំរោងក្រោម ខណ្ឌដង្កោ ក្រុងភ្នំពេញ កាន់សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិគោករការ សង្កាត់គោករការ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ* **ននននន** *(រ) មានកូន ០១ នាក់ ឪពុកឈ្មោះ* **ណណណណ** *(រ) ម្តាយឈ្មោះ* **បបបបប** *(រ) ជានីតិជន ទោសពីមុនគ្មាន។*

**យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ** :

*កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៣ នៅវេលាម៉ោង ១៨ និង៤០នាទី ជនត្រូវចោទឈ្មោះ* **ភភភភភភ** *ជាកម្មកធ្វើការផ្នែកអាលុយមីញ៉ូមក្នុងរោងចក្រផលិតខ្សែកាប* ***ខេ ស៊ី ធី*** **(KTC)** *ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់គោករកា ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ បានធ្វើសកម្មភាពលួចកំទេចស្ពាន់ទម្ងន់ ១,២គីឡូក្រាមក្នុងរោងចក្រយកមករុំនិងកំភួនដៃ រួចយកអាវដៃវែងគ្របពីលើ ។ លុះដល់ម៉ោងឈប់ធ្វើការដើរចេញមកដល់ប៉ុស្តិ៍យាមសន្តិសុខក្រុមហ៊ុនធ្វើការឆែកឆេរ ឃើញក៏ចាប់ខ្លួនជនត្រូវចោទឈ្មោះ* **ភភភភភភ** *ប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលសង្កាត់គោករកាតែម្តង ។*

*អង្គហេតុនេះជាបទល្មើស* **លួច** *ប្រព្រឹត្តនៅភូមិត្រពាំងពោធិ សង្កាត់គោករកា ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៣ តាមបញ្ញត្តិមាត្រា ៣៥៣ ,៣៥៦ នៃក្រមព្រហ្មទណ្ឌ ។*

---

[១] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុតិធម៌

**យើងបានទទួលចម្លើយពីជនត្រូវចោទនេះដូចតទៅ**:

១-ចម្លើយរបស់ជនត្រូវចោទឈ្មោះ **កកកកកក** ភេទប្រុស អាយុ២៨ ឆ្នាំ ជាតិខ្មែរ នៅសមត្ថកិច្ច និងនៅអយ្យការប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៣ នៅវេលាម៉ោង ៨ ព្រឹក បានចូលធ្វើការក្នុងរោងចក្រផលិតខ្សែកាប ខេ ស៊ី ធី (KTC) ស្ថិតនៅភូមិត្រពាំងពោធិ សង្កាត់គោករកា ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ លុះដល់ម៉ោង ១៨ និង៤០នាទី ខ្លួនទៅយកកំទេចស្ពាន់ប្រហែលទម្ងន់ ១ គីឡូក្រាម ក្នុងរោងចក្រយកទៅដាក់ក្នុងម៉ាស៊ីនកិនឲ្យទៅជាដុំ រួចយកទៅរុំនិងកំភួនដៃរបស់ខ្លួន រួចយកអាវដៃវែងគ្របពីលើ ។ លុះដល់ម៉ោងឈប់ធ្វើការដើរចេញមកដល់ប៉ុស្តិ៍យាមសន្តិសុខក្រុមហ៊ុនធ្វើការឆែកឆេរឃើញក៏ចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលសង្កាត់គោករកាតែម្តង ។

**យើងបានប្រាប់ដល់ជននេះថា** : ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬ ស្នើសុំឲ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់។

☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី

☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ។

**យើងបានបញ្ជាក់ថា** :

☐ លោក/លោកស្រី........................... អាចពិនិត្យសំណុំរឿងនឹងទាក់ទងជាមួយជនជាប់ចោទ។

☐ យោងលើសំណុំរឿងសុំឲ្យមានចាត់មេធាវី ស្របតាមបញ្ញត្តិច្បាប់ ស្តីពីលក្ខន្តិកៈ មេធាវី តំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម។

☐ លោក/លោកស្រីមេធាវី.................................................. វត្តមាន។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច:

-បញ្ជូនជនជាប់ចោទឈ្មោះ **កកកកកក** ភេទប្រុស អាយុ២៨ ឆ្នាំ ទៅតុលាការដើម្បីធ្វើការជំនុំជម្រះតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះអង្គហេតុ និងបទល្មើស **លួច** ប្រព្រឹត្តនៅភូមិត្រពាំងពោធិ សង្កាត់គោករកា ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៣ តាមបញ្ញត្តិមាត្រា ៣៥៣ ,៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង។

**ជនជាប់ចោទ** **តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ..........
ចុះថ្ងៃទី......ខែ ឧសភា ឆ្នាំ ២០១៦
លេខ............................អ.យ.ណ

# ដីកាសន្និដ្ឋានស្ថាពរ

**យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ............ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ............ អ.យ.ណ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ .............. ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ លិខិតជូនដំណឹង ស្តីពីការបិទការស៊ើបសួរលេខ ..............ព្រ.ទ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ ..............ព្រ.ទ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា៖**

១-ឈ្មោះ **កក** ភេទប្រុស។

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-ឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិបឹងក្រោម ឃុំខ្ពប់អាទាវ ស្រុកលើកដែក ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវបេតុង សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ **ននននន** (រ) ម្តាយឈ្មោះ **ហាហាហា** (រ) ប្តីឈ្មោះ **ទទទទទ** (លែងលះ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ **(ក្នុងឃុំ)**

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ភ្នាក់ងារស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពី ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៣-ឈ្មោះ **គគគគគ** ភេទស្រី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ន ផ្ទះជួលគ្មានលេខ ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ **រររររ** (រ) ម្តាយឈ្មោះ **មមមម** (រ) ប្តីឈ្មោះ **តតតត** (លែងលះ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

៤-ឈ្មោះ **យយយយយ** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ផ្ទះជួល សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ **ផផផផផ** (រ) ម្តាយឈ្មោះ **ណណណ** (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **លេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៤** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

**ឃើញថា៖**

នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១១និង០០នាទី នៅត្រង់ចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កម្លាំងរបស់គណៈបញ្ជាការឯកភាពខណ្ឌសែនសុខ សហការណ៍ជាមួយកម្លាំងរបស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានចុះបង្ក្រាបជាក់ស្តែងផ្ទះបើកកន្លែងល្បែងស៊ីសងខុសច្បាប់ (ហ្គេមវាយពង់) ដែលមានម្ចាស់ឈ្មោះ **កក** ភេទប្រុស ដែលពេលបង្ក្រាបនោះ បានឃាត់ខ្លួនជនត្រូវចោទចំនួន ០៣នាក់ ឈ្មោះ **ខខខខ** ភេទស្រី, ឈ្មោះ **គគគគគ** ភេទស្រី និងឈ្មោះ **យយយយយ** រួមទាំងវត្ថុតាងនាំមកអធិការដ្ឋាននគរបាលខណ្ឌសែនសុខតែម្តង។

**បានឃើញ** របាយការណ៍សំយោគលេខ **១២០/១៦** រ.ប.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា ជនសង្ស័យឈ្មោះ **កក** (គេចខ្លួន) ភេទប្រុស អាយុប្រហែល ៣៥ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ បើកលេងល្បែងស៊ីសងខុសច្បាប់ (ហ្គេមបៀរ), ជនសង្ស័យឈ្មោះ **ខខខខ** (ឃាត់ខ្លួន) ជាភ្នាក់ងារចាត់ចែងល្បែងស៊ីសងខុសច្បាប់ (ហ្គេមបៀរ), ជនសង្ស័យឈ្មោះ **គគគគគ** (ឃាត់ខ្លួន) និងជនសង្ស័យឈ្មោះ **យយយយយ** (ឃាត់ខ្លួន) ពិតជាបានប្រព្រឹត្តអំពើ លេងល្បែងស៊ីសងខុសច្បាប់ (ហ្គេមបៀរ) កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១១និង០០នាទី នៅចំណុចក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រាកដមែន។

**បានឃើញ** ចម្លើយរបស់ជនត្រូវចោទឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា មុនពេលកើតហេតុ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ ខ្លួនបានមកបម្រើការងារមើលការខុសត្រូវនៅផ្ទះបើកលេងហ្គេមវាយពង់ ឲ្យឈ្មោះ **កក** ភេទប្រុស អាយុប្រហែល ៣០ឆ្នាំជាង ជាម្ចាស់ហ្គេម ដោយខ្លួនបានទទួលប្រាក់ខែចំនួន ២០០ ដុល្លារអាមេរិកក្នុងមួយខែ។ ចាប់ពីថ្ងៃដែលខ្លួនធ្វើការមកក្នុងមួយថ្ងៃខ្លួនប្រមូលប្រាក់ចំណូលឲ្យមេហ្គេមបានចំនួនចាប់ពី ៥០ម៉ឺនរៀល ទៅ ៦០ម៉ឺនរៀល។ លុះដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១១និង០០នាទី ខ្លួនកំពុងអង្គុយមើលការខុសត្រូវនៅកន្លែងហ្គេម ស្រាប់តែឃើញសមត្ថកិច្ចចុះមកឃាត់ និងនាំខ្លួន ព្រមទាំងវត្ថុតាង យកមកធ្វើការសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខតែម្តង។

ចំណែកចម្លើយរបស់ជនត្រូវចោទនៅអយ្យការ និងនៅចៅក្រមស៊ើបសួរ បានឆ្លើយបដិសេធថា ខ្លួនមិនមែនជាអ្នកបម្រើការងារមើលការខុសត្រូវបើកលេងល្បែងស៊ីសងខុសច្បាប់ទេ។ ខ្លួនគ្រាន់តែជាអ្នកមកហាត់រៀន ដោយគេបានសន្យាថាបើចេះ គេនឹងឲ្យប្រាក់ក្នុងមួយខែ ២០០ ដុល្លារអាមេរិក។ ហើយខ្លួនទើបតែចូលមកហាត់រៀនបានជាងដប់ថ្ងៃប៉ុណ្ណោះ ដោយក្នុងមួយថ្ងៃរកចំណូលបានប្រហែល ១០ម៉ឺនរៀល ទៅ ២០ម៉ឺនរៀលប៉ុណ្ណោះ។

**បានឃើញ** ចម្លើយរបស់ជនត្រូវចោទឈ្មោះ **គគគគគ** ភេទស្រី អាយុ ២២ឆ្នាំ បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ នៅអយ្យការ និងនៅចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១១និង០០នាទី ខ្លួនបានដើរចេញពីផ្ទះសំណាក់យីហោឆាយហេង ទៅលេងអ្នកស្គាល់គ្នាឈ្មោះ **ខខខខ** ដែលកំពុងបម្រើការងារនៅផ្ទះបើកទូរហ្គេម ស្ថិតនៅភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ពេលខ្លួនដើរចូលទៅក្នុង ឃើញមានទូរហ្គេមចំនួន ១០ទូរ ហើយមានមនុស្សប្រុសម្នាក់កំពុងអង្គុយលេង។ ពេលនោះខ្លួនបានអង្គុយជជែកលេងជាមួយឈ្មោះ **ខខខខ** ស្រាប់តែសមត្ថកិច្ចចុះបង្ក្រាប ហើយឃាត់ និងនាំខ្លួន ព្រមទាំងវត្ថុតាង មកអធិការដ្ឋាននគរបាលខណ្ឌសែនសុខតែម្តង។

**បានឃើញ** ចម្លើយរបស់ជនត្រូវចោទឈ្មោះ **យយយយយ** ភេទប្រុស អាយុ ២៣ឆ្នាំ បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ នៅអយ្យការ និងនៅចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១១និង០០នាទី ខ្លួនបានដើរចេញពីផ្ទះ ស្ថិតនៅសង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មកចូលលេងហ្គេមនៅ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ពេលមកដល់ក្នុងផ្ទះហ្គេម ខ្លួនបានទិញពុងបៀរចំនួន ១ដុល្លារអាមេរិក ពីអ្នកមើលការខុសត្រូវក្នុងផ្ទះហ្គេម ហើយអង្គុយលេងបានបន្តិច ស្រាប់តែសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។

**បានឃើញ** ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **២៧០៦** "ណរ" ដ.ឃ.ដ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ លើឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ **១៩៧២** "ណរ" ដ.ព.ស ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ លើឈ្មោះ **យយយយយ** ភេទប្រុស អាយុ ២៣ឆ្នាំ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ **១៩៧១** "ណរ" ដ.ព.ស ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ លើឈ្មោះ **គគគគគ** ភេទស្រី អាយុ ២២ឆ្នាំ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** ឯកសារមួយចំនួនដែលទាក់ទងនឹងសំណុំរឿង ។

**យល់ឃើញថា**

-តាមរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ **ខខខខ** ដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរមានភាពស៊ីសង្វាក់ ដែលអាចបញ្ជាក់ថា ជនត្រូវចោទឈ្មោះ **ខខខខ** ពិតជាបានបម្រើការជា ភ្នាក់ងារល្បែងស៊ីសង ប្រាកដមែន។

-តាមរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ **យយយយ** ដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរ

មានភាពស៊ីសង្វាក់ ដែលអាចបញ្ជាក់ថា ជនត្រូវត្រូវចោទឈ្មោះ **ឃឃឃឃ** ពិតជាបានលេងល្បែងស៊ីសងដោយខុសច្បាប់ ប្រាកដមែន។

-តាមរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ជនត្រូវចោទឈ្មោះ **គគគគគ** ពិតជាបានចូលទៅលេងល្បែងស៊ីសងដោយខុសច្បាប់ប្រាកដមែន។ ចំណែកចម្លើយបដិសេធ ដែលជនត្រូវចោទ បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរថា ខ្លួនមិនបានចូលលេងល្បែងស៊ីសង គ្រាន់តែទៅលេងមិត្តភក្តិ នេះគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ព្រោះជនត្រូវចោទ គ្មានអំណះអំណាង និងភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់។

-អំពើរបស់ជនត្រូវចោទឈ្មោះ **ខខខខ** គឺជាបទល្មើស **ភ្នាក់ងារស៊ីសងដោយខុសច្បាប់** តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។ ចំណែកអំពើរបស់ជនត្រូវចោទឈ្មោះ **ឃឃឃឃឃ** និងឈ្មោះ **គគគគគ** គឺជាបទល្មើស **លេងល្បែងស៊ីសងដោយខុសច្បាប់** តាមមាត្រា**៨** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

-ជនត្រូវចោទឈ្មោះ **កក** គ្មានអត្តសញ្ញាណគ្រប់គ្រាន់អាចបញ្ជូនទៅជំនុំជម្រះបាន គប្បីលើកលែងចោទប្រកាន់ តាមមាត្រា**២៤៧ថ្មី** នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ជនត្រូវចោទឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ, ឈ្មោះ **គគគគគ** ភេទស្រី អាយុ ២២ឆ្នាំ និងឈ្មោះ **ឃឃឃឃឃ** ភេទប្រុស អាយុ ២៣ឆ្នាំ ជាជនដែលមាន សតិបញ្ញា ដឹងខុសត្រូវ និងមានសមត្ថភាព គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

-មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ចោទប្រកាន់លើៈ ឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ ពីបទ **ភ្នាក់ងារស៊ីសងដោយខុសច្បាប់**, ឈ្មោះ **គគគគគ** ភេទស្រី អាយុ ២២ឆ្នាំ និងឈ្មោះ **ឃឃឃឃឃ** ភេទប្រុស អាយុ ២៣ឆ្នាំ ពីបទ **លេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** និងមាត្រា**៨** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

<u>**ហេតុដូច្នេះ**</u>

**ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេច**

☑ បញ្ជូនជនត្រូវចោទៈ

១-ឈ្មោះ **ខខខខ** ភេទស្រី អាយុ ២៤ឆ្នាំ **(ក្នុងឃុំ) ទៅជំនុំជម្រះ** ពីបទ **ភ្នាក់ងារស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-ឈ្មោះ **គគគគគ** ភេទស្រី អាយុ ២២ឆ្នាំ **(ក្រៅឃុំ) ទៅជំនុំជម្រះ** ពីបទ **លេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៨** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៣-ឈ្មោះ **ឃឃឃឃ** ភេទប្រុស អាយុ ២៣ឆ្នាំ **(ក្រៅឃុំ) ទៅជំនុំជម្រះ** ពីបទ **លេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ

រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៤** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

☑ លើកលែងចោទប្រកាន់ឈ្មោះ **កក** ភេទប្រុស ពីបទ **បើកកន្លែងលេងល្បែងស៊ីសងដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្នុងផ្ទះជួល ផ្លូវបេតុង ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ តាមមាត្រា**៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

ធ្វើនៅអយ្យការ, ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ អ.យ.ណ

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ................ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា :**

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១.☐ ការដកពាក្យបណ្ដឹង

៣.២ ☐ ការលើកលែងទោសជាទូទៅ

៣.៣.☐ មរណភាពជនល្មើស

៣.៤.☐ ផុតអាជ្ញាយុកាល

៣.៥.☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦.☐ អាជ្ញាអស់ជំនុំ

៣.៧.☐ ការសម្របសម្រួលជាមួយរដ្ឋ

៣.៨.☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩.☐ អភ័យឯកសិទ្ធិ

៣.១០.☐ អនិយ័តភាពនៃនីតិវិធី

៣.១១.☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

៤.១.☐ ការស្វែងរកមិនបានផល

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

៤.២.□ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

៤.៣.□ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការទទួលខុសត្រូវ

៤.៤.□ ការខកខានរបស់ដើមបណ្តឹង

៤.៥.□ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦.□ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧.□ និយ័តកម្មដោយឯកឯង[3]

៤.៨.□ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១.□ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២.□ សន្ធានកម្ម[4]

៥.៣.□ អធិបញ្ញោផ្តល់ការព្យាបាល

៥.៤.□ ជនរងគ្រោះ / ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើរសុំរបស់ព្រះរាជអាជ្ញា

៥.៥.□ និយ័តកម្មតាមសណើររបស់ព្រះរាជអាជ្ញា

៥.៦.□ ការរលឹកពីអត្ថបទច្បាប់ / ការព្រមាន[5]

៥.៧.□ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨.□ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១.□ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១.□ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១.□ ការផ្តល់ជំនួយការអប់រំជំនួយការចោទប្រកាន់

## ការសង្កេតផ្សេងៗ :

ឈ្មោះ **កកកកក** និងឈ្មោះ **ខខខខខ** បានរៀបការជាមួយគ្នា ដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៧៥ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ ។ ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ឈ្មោះ **ខខខខខ** បានរួមសេវនកិច្ចជាមួយឈ្មោះ **គគគគគគ** ភេទស្រី អាយុ ២១ ឆ្នាំ ។

**ចានឃើញ** : ពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ របស់ឈ្មោះ **កកកកក** ភេទស្រី អាយុ ២៦ ឆ្នាំ ប្តឹងឈ្មោះ **ខខខខខ** ភេទប្រុស អាយុ ៣០ ឆ្នាំ ពីបទ **ផិត** ។

---

[2] ដើមបណ្តឹងឈប់ប្តឹង

[3] សកម្មភាពរបស់ជនល្មើសបានបញ្ឈប់បទល្មើស នឹងស្តារស្ថានភាពឡើងវិញ

[4] ករណីចែងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានអោយឈប់ប្រព្រឹត្ត

[6] ករណីចែងដោយច្បាប់

-**បានឃើញ** : ចម្លើយដើមបណ្ដឹងឈ្មោះ **កកកកក** ភេទស្រី អាយុ ២៦ ឆ្នាំ ឆ្លើយនៅអយ្យការថា កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១២ ខ្លួនបានរៀបការជាមួយឈ្មោះ **ខខខខខ** និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៧៥ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ ។ ខ្លួនបានរួមរស់ជា មួយប្ដីខ្លួនឈ្មោះ **ខខខខខ** ចុះសម្រុងគ្នាជាធម្មតា មិនដែលមានបញ្ហានៅក្នុងគ្រួសារទេ ។ លុះដល់ អំឡុងខែមេសា ឆ្នាំ២០១៥ ពេលដែលខ្លួនឆ្លងទន្លេបានកូនប្រុសមួយឈ្មោះ **ជជជជជ** ស្រាប់តែប្ដីរបស់ខ្លួនលបលួចមានស្រីខាងក្រៅ ដោយខ្លួនបានតាមដានតាមប្រព័ន្ធទំនាក់ទំនងហ្វេសបុក (Facebook) ឃើញគាត់មានទំនាក់ទំនងជាមួយស្ត្រីម្នាក់ឈ្មោះ **គគគគគគគ** បានណាត់ជួបគ្នានៅ ខេត្តបាត់ដំបង និងសៀមរាប ដើម្បីរួមមេត្រីជាមួយគ្នា ដោយខ្លួនបានឃើញឈ្មោះ **គគគគគគគ** បង្ហោះរូបភាពច្រាស់ដុះធ្មេញចំនួន ០២ ដើម នៅក្នុងបន្ទប់សណ្ឋាគារ ដោយច្រាស់ដុះធ្មេញមួយដើម ជារបស់ប្ដីខ្លួន បានជាខ្លួនស្គាល់ច្រាស់ដុះធ្មេញ ព្រោះខ្លួនជាអ្នកទិញឲ្យគាត់ប្រើប្រាស់ ហើយប្ដីខ្លួនបាន បង្ហោះរូបភាពតាមប្រព័ន្ធទំនាក់ទំនងហ្វេសបុកនូវរូបភាពកាន់ដៃគ្នាជាមួយឈ្មោះ **គគគគគគគ** នៅជណ្ដើរយន្តសណ្ឋាគារ ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ឈ្មោះ **គគគគគគគ** បានឡើងមកភ្នំពេញ ជួបប្ដីរបស់ខ្លួន និងបានដើរលេងជាមួយគ្នា ដោយប្ដីរបស់ខ្លួនបានធ្វើខួបកំណើតឲ្យឈ្មោះ **គគគគគគគ** នៅ LES COCKTAIL និងបានទិញទឹកអប់ឲ្យឈ្មោះ **គគគគគគគ** ថែមទៀត ។ អំឡុងខែវិច្ឆិកា ឆ្នាំ២០១៥ ប្ដីរបស់ខ្លួនឈ្មោះ **ខខខខខ** បានធ្វើខ្សែកដៃដែលមានបន្តោងដាក់ឈ្មោះ មុនីនាថ ខ្លួនដឹងដោយសារមិត្តភក្តិធ្វើការជាមួយប្ដីខ្លួនឈ្មោះ **តតតតតត** ប្រាប់ខ្លួន ។ ខ្លួនសុំឲ្យតុលាការផ្ដន្ទាទោសឈ្មោះ **ខខខខខ** តាមច្បាប់ និងឲ្យឈ្មោះ **ខខខខខ** ផ្ដល់សំណងជម្ងឺចិត្តចំនួន ២០០០០០០០ (ម្ភៃលាន) រៀល ។

-**បានឃើញ** : ចម្លើយរបស់ឈ្មោះ **ខខខខខ** ភេទប្រុស អាយុ ៣០ ឆ្នាំ ឆ្លើយនៅអយ្យការថា កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១២ ខ្លួនបានរៀបការជាមួយឈ្មោះ **កកកកក** និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៧៥ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ ។ ខ្លួនរួមរស់ជាមួយឈ្មោះ **កកកកក** ចុះសម្រុងគ្នាជាធម្មតា មិនដែលមានបញ្ហានៅក្នុងគ្រួសារទេ ។ លុះដល់អំឡុងខែឧសភា ឆ្នាំ២០១៥ ប្រពន្ធខ្លួនឈ្មោះ **កកកកក** ចេះតែចោទប្រកាន់ខ្លួនថា លួចលាក់មានស្រីខាងក្រៅឈ្មោះ **គគគគគគគ** ភេទស្រី អាយុប្រហែល ២១ ឆ្នាំ ដោយគាត់សំអាង លើរូបថត ដែលខ្លួនថតជាមួយឈ្មោះ **គគគគគគគ** នៅរាជធានីភ្នំពេញ ។ ខ្លួនស្គាល់ឈ្មោះ **គគគគគគគ** នៅពេលដែលឈ្មោះ **គគគគគគគ** មកលេងផ្ទះខ្លួនជាលក្ខណៈគ្រួសារ ទើបពួកយើងរាប់អានគ្នា ។ កាលពីថ្ងៃទី១៧ និង ១៨ ខែមេសា ឆ្នាំ២០១៥ ខ្លួនមិនបានណាត់ជួបឈ្មោះ **គគគគគគគ** នៅសណ្ឋាគារនៅខេត្តបាត់ដំបងទេ ហើយចំពោះរូបភាពច្រាស់ដុះធ្មេញ ខ្លួនមិនបានដឹងថា ប្រពន្ធខ្លួនបានមកពីណាដែរ ។ ចំពោះរូបភាពដែលប្រពន្ធខ្លួនបញ្ជាក់ថា រូបខ្លួន និងឈ្មោះ **គគគគគគគ** កាន់ដៃគ្នានៅក្នុងជណ្ដើរយន្តនោះ គឺមិនមែនជារូបខ្លួនទេ ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ខ្លួនមិនបានធ្វើខួបកំណើតឲ្យឈ្មោះ **គគគគគគគ** នៅ LES COCKTAIL ហើយក៏មិនបានទិញទឹកអប់ឲ្យឈ្មោះ **គគគគគគគ** ដូចការអះអាងរបស់ប្រពន្ធខ្លួនដែរ ។ នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០១៥ ឈ្មោះ **គគគគគគគ** បានពឹងខ្លួនឲ្យជួយធ្វើខ្សែកឲ្យ ព្រោះ លក្ខណៈលក់តាមអនឡាញ (Online) ។ ខ្លួនសុំបដិសេធទាំងស្រុងចំពោះការចោទប្រកាន់របស់

ប្រពន្ធខ្លួន ព្រោះខ្លួនគ្រាន់តែរាប់អានជាមួយឈ្មោះ **គគគគគគគ** ជាលក្ខណៈមិត្តភក្តិធម្មតា មិនមានទំនាក់ទំនងស្នេហានោះទេ ។ ខ្លួនសុំបញ្ចូលភស្តុតាងផ្សេងៗតាមរយៈមេធាវីខ្លួននៅពេលក្រោយ ។

**បានឃើញ** : លិខិតដកពាក្យបណ្ដឹងចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ របស់ឈ្មោះ **កកកកក** ភេទស្រី អាយុ ២៦ ឆ្នាំ ។

**បានឃើញ** : ឯកសារផ្សេងទៀតនៅក្នុងសំណុំរឿងនេះ ។

## យល់ឃើញថា

-តាមចម្លើយដើមបណ្ដឹងឈ្មោះ **កកកកក** និងភស្តុតាងផ្សេងៗ បង្ហាញថា ឈ្មោះ **ខខខខខ** ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត ។

-អំពើរបស់ឈ្មោះ **ខខខខខ** ជាបទល្មើស **ផិត** តាមមាត្រា ៧ នៃច្បាប់ស្ដីពីឯកពន្ធភាព ។

-ឈ្មោះ **កកកកក** ជាសហព័ទ្ធរបស់ឈ្មោះ **ខខខខខ** បានសុំដកពាក្យបណ្ដឹង និងសុំកុំឲ្យចោទប្រកាន់លើឈ្មោះ **ខខខខខ** ។ ការស្នើសុំនេះ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្ដឹងអាជ្ញាបានតាមមាត្រា ៨ នៃច្បាប់ស្ដីពីឯកពន្ធភាព ។

## ហេតុដូច្នេះសម្រេច

តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៥១៩០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ទុកឥតចាត់ការចាប់ពីពេលនេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០១៦

**ជ. ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ អយណ

# លិខិតជូនដំណឹង

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ជម្រាបមកលោក **កកកក** អាយុ ៦២ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅ ផ្ទះលេខ ១២ ផ្លូវ ៣៧២ ភូមិ ៤ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ ................ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ករណីគ្រោះថ្នាក់ចរាចរណ៍ នៅចំណុចផ្លូវ ២០៥ កែងផ្លូវ ៣៧៤ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ នោះយើងបានសម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាសម្រេចលេខ ................ អយណ ចុះថ្ងៃទី.......... ខែមេសា ឆ្នាំ២០១៦ រួចហើយ ។

រាជធានីភ្នំពេញ , ថ្ងៃទី ខែមេសា ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

---

(១) - ជូនដំណឹងដោយមាត្រា ៦ និង មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

លេខ......................ចុះថ្ងៃទី..........
ខែ....................ឆ្នាំ......................
សំណុំរឿងព្រហ្មទណ្ឌលេខ ..........
ចុះថ្ងៃទី.......ខែ ឧសភា ឆ្នាំ ២០១៦

# សេចក្ដីសុំប្ដឹងតវ៉ា

ឆ្នាំពីរពាន់..........................................ខែ..............................ថ្ងៃទី.......................................
វេលាម៉ោង.....................................................................................................................................។

យើង.......................................................ក្រឡាបញ្ជី អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញឈ្មោះ:.........................................................................................................................
ចូលមកចំពោះមុខយើង នៅការិយាល័យក្រឡាបញ្ជីនៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយ សុំប្ដឹង............................និង......................................................លេខ..........................................
ចុះថ្ងៃទី..........................ខែ..............................ឆ្នាំ..........................ត្រង់ចំណុចៈ............................
........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................
........................................................................................................................................................

ឈ្មោះនេះទទួលថានឹងធ្វើពាក្យបណ្ដឹងបន្ថែម ឲ្យទាន់ពេលវេលា។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្ដីនេះ ឲ្យឈ្មោះ.......................................................................
ស្ដាប់ហើយ ឲ្យចុះហត្ថលេខា ឬ "ផ្ដិតមេដៃ" ជាមួយយើង។

**អ្នកប្ដឹង** **ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

លេខ......................ចុះថ្ងៃទី..........
ខែ....................ឆ្នាំ......................
សំណុំរឿងព្រហ្មទណ្ឌលេខ ..........
ចុះថ្ងៃទី.......ខែ ឧសភា ឆ្នាំ ២០១៦

## សេចក្តីចម្លងបណ្តឹងតវ៉ា

ឆ្នាំពីរពាន់.............................ខែ....................ថ្ងៃទី........................វេលាម៉ោង..........................
យើង.......................................................ក្រឡាបញ្ជី អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
បានឃើញឈ្មោះ..................................................................................................................
..................................................................................................................................................។
ចូលមកចំពោះមុខយើង នៅការិយាល័យក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយសុំប្តឹង ឧទ្ធរណ៍ និងដីកាតម្កល់រឿងទុកឥតចាត់ការលេខ.......................ចុះថ្ងៃទី...........................
ខែ.............................ឆ្នាំ...........................ត្រង់ចំណុចៈ..........................................................
..................................................................................................................................................
..................................................................................................................................................
..................................................................................................................................................
..................................................................................................................................................
ឈ្មោះនេះទទួលថានឹងធ្វើពាក្យបណ្តឹងបន្ថែម ឲ្យទាន់ពេលវេលា។
ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះ ឲ្យឈ្មោះ..............................................................
.........................................................................ស្តាប់ហើយ ឲ្យចុះហត្ថលេខា ឬ "ផ្តិតមេដៃ" ជាមួយយើង។

**អ្នកប្តឹង** **ក្រឡាបញ្ជី**

..................................................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.........ខែ............ឆ្នាំ.............

**ក្រឡាបញ្ជី**

បានឃើញ
ថ្ងៃទី..........ខែ............ឆ្នាំ................

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
*លេខ                    អ.យ.ណា*

**ដីកាអម**
**សូមគោរពជូន**
**ឯកឧត្តម អគ្គព្រះរាជអាជ្ញា មហាអយ្យការអមសាលាឧទ្ធរណ៍**

| *ល.រ* | *រាយឈ្មោះលិខិត* | *ចំនួន* | *សេចក្តីផ្សេងៗ* |
|---|---|---|---|
| **០១** | *-សំណុំរឿងព្រហ្មទណ្ឌលេខ ................ ចុះថ្ងៃ ទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។* | *០១ រឿង* | |
| | **សរុប** | *០១ រឿង* | |

*រាជធានីភ្នំពេញ, ថ្ងៃទី          ខែកញ្ញា ឆ្នាំ២០១៥*
**ជ.ព្រះរាជអាជ្ញា**